ព្រះរាជាណាចក្រកម្ពុជា

គង់ សុខហេង

## សំណួរ_ចម្លើយ

# អក្សរសាស្ត្រខ្មែរ

១២



ស្របតាមកម្មវិធីសិក្សាថ្មី

# អារម្ភកថា

ស្វស្តីប្អូនៗសិស្សានុសិស្សថ្នាក់ទី១២ជាទីស្រឡាញ់ ! សៀវភៅកំណែភាសាខ្មែរថ្នាក់ទី១២ថ្មីនេះ ខ្ញុំរៀបចំឡើងដើម្បីបំពេញសេចក្ដីត្រូវការ និងជួយសម្រួលដល់ការសិក្សារបស់ប្អូនៗ ។

ចំពោះរាល់ការឆ្លើយសំណួរ ក៏ដូចជាការបកស្រាយទៅលើខ្លឹមសារនៅក្នុងមេរៀននីមួយៗ ប្រាកដជានៅមានចំណុចខ្វះខាតជាច្រើនដែលពុំទាន់អស់សេចក្ដីទេ ពីព្រោះយើងពុំទាន់មានសៀវភៅគ្រូជាគោលនៅឡើយទេ ដូច្នេះសូមប្អូនៗយកទៅអានដោយការពិចារណាបន្ថែមទៀត ទើបការសិក្សារបស់ប្អូនៗទទួលបានជោគជ័យ ។

ខ្ញុំសូមខន្តីអភ័យទោស ចំពោះរាល់កំហុសឆ្គងទាំងឡាយ ដែលកើតមាននៅក្នុងសៀវភៅនេះ ។

កែសម្រួលជាថ្មី. ថ្ងៃទី២០ ខែវិច្ឆិកា ២០១២

អ្នករៀបរៀង

ធ.ស.ហ

មេរៀនទី ១

# អក្សរសិល្ប៍ខេមរនិយម

## ឥន្ទ្រីយ៍រូបារម្មណ៍ក្នុងកំណាព្យ

*១- ឥន្ទ្រីយរូបារម្មណ៍ គឺជារូបារម្មណ៍ដែលកើតពីពាក្យសំដី ឃ្លោង ឃ្លា ប្រយោគរបស់កវីនិពន្ធ ធ្វើឱ្យរំភើបចំពោះគ្រឿងវិញ្ញាណទាំងឡាយដូចជា ចក្ខុ សោតៈ ឃានៈ ជិវ្ហា កាយៈ គឺវិញ្ញាណទាំង៥របស់អ្នកអាន ឬអ្នកស្តាប់ ។* ឥន្ទ្រីយរូបារម្មណ៍មាន ៖

- ចក្ខុរូបារម្មណ៍
- សោតរូបារម្មណ៍
- ឃានរូបារម្មណ៍
- ជិវ្ហារូបារម្មណ៍
- កាយរូបារម្មណ៍

### លំហាត់

ចូរស្រាវជ្រាវអត្ថបទដែលមានបង្ហាញពីចក្ខុរូបារម្មណ៍ សោតរូបារម្មណ៍ ឃាននិងជិវ្ហារូបារម្មណ៍ និងកាយរូបារម្មណ៍ ។

## ចម្លើយ

### សោតរូបារម្មណ៍ និង ចក្ខុរូបារម្មណ៍

រួចនេននស្តាប់ជាក់ភ្ញាក់ព្រើតប្រើង ភ្នែកគន់សម្លឹងទៅមាត់ទ្វារ
យល់ទាវឈរស្ងប់ដើររេរា ស្ទុះស្ទារចូលក្នុងស្លុងចេញក្រៅ។
(ទុំទាវ)

### ឃានរូបារម្មណ៍

ទឹកអប់ត្រឡប់ធុំគន្ធរស សាប៊ូផ្ទុតផុតជ្រះសន្លាង
ក្រអូបសាប៊ូក្លិនដោយយ៉ាង ដោយយល់សំណាងសាមណេរ
នេន។ (ទុំទាវ)

### កាយរូបារម្មណ៍

ដល់ដួលដាក់អង្គទ្រង់វិយោគ ទ្ទញយំឱនឈ្ងោកគួរអាណិត
អនាថត្រដាក់ហើយល្ងាចឥត លោកណាជួយផិតជីវិតខ្ញុំ។
(ទុំទាវ)

## លក្ខណៈជាតិនៃអក្សរសិល្ប៍

១. អក្សរសិល្ប៍មានលក្ខណៈជាតិ គឺអក្សរសិល្ប៍ទាំងឡាយណា ដែលទ្រទ្រង់នូវតម្លៃពិសេសរបស់ជាតិមួយ ដែលខុសស្រលះពីជាតិដទៃតាំងពីជំនឿ ទំនៀមទម្លាប់ ប្រពៃណី សាសនា អាកប្បកិរិយាជាដើម ។

ឬ *លក្ខណៈជាតិនៃអក្សរសិល្ប៍ គឺជាលក្ខណៈពិសេសរបស់ជាតិមួយ លេចធ្លោខុសពីជាតិដទៃ ដែលស្តែងចេញតាមរយៈអក្សរសិល្ប៍* ។

### លំហាត់

ចូរបង្ហាញលក្ខណៈជាតិនៃអក្សរសិល្ប៍ ដែលស្តែងចេញឡើងក្នុងវគ្គដកស្រង់ ។ (វគ្គដកស្រង់ពីរឿងភូមិតិរច្ឆាន ទំ.១២) ។

### ចម្លើយ

លក្ខណៈជាតិក្នុងវគ្គដកស្រង់នេះ គឺ

- ប្រជាជនខ្មែរគោរពព្រះពុទ្ធសាសនា (ព្រះវិហារព្រះកែវមរកត)
- ប្រជាជនខ្មែរជឿទៅលើវត្ថុសក្តិសិទ្ធិ (បន់ស្រន់ព្រះអង្គដងកើ)
- ជឿលើបាតុភូតធម្មជាតិ (រន្ទះបាញ់ព្រះវិហារព្រះកែវមរកត ...ជំនឿថានឹងកើតចលាចល ឬមានកើតហេតុទុរភិក្សក្នុងស្រុក) ។



# សិក្សាអត្ថបទរឿងទុំទាវ

## សំណួរ

១. តើអត្ថបទដកស្រង់ខាងលើនេះស្ថិតក្នុងចលនាអក្សរសិល្ប៍បែបណាមួយ? ចូរអ្នករកអំណះអំណាងមកបញ្ជាក់ឱ្យបានច្បាស់-លាស់?

២. តាមរយៈអត្ថបទដកស្រង់នេះ តើកវីបានប្រើវិធីតែងនិពន្ធសំខាន់ៗអ្វីខ្លះ? ចូរបង្ហាញពីវិធីនោះឱ្យបាន៥យ៉ាងតិច ដោយរកឧទាហរណ៍ពីក្នុងអត្ថបទនេះមកបញ្ជាក់ផង ។

៣. ចូរអ្នកបង្ហាញពីលក្ខណៈអក្សរសិល្ប៍តាមរយៈអត្ថបទដកស្រង់នេះ ។

៤. តើក្នុងសម័យកាលនោះ ជនជាតិខ្មែរបានទទួលឥទ្ធិពលពីសាសនាណាខ្លះ? ចូរអ្នកធ្វើការបញ្ជាក់តាមរយៈអត្ថបទនេះ ។

៥. ចូរអ្នកធ្វើការឆ្លុះបញ្ចាំងពីតថភាពសង្គមខ្មែរនាសម័យនោះ ។

៦. ដោយផ្អែកលើវគ្គ "លិនចោងករវិករំលឹករក សម្ដិលីហៅយកមណីចិន្តា លូកយកប្រទាលឆាន់នឹងស្លា សូត្រសាគ្រប់សព្វចប់ជាម្ដង" ចូរអនុវត្តលំហាត់ខាងក្រោម ៖

ក. ដោយសិក្សាពាក្យ១ព្យាង្គ រកទំនាញសូរ គ្មានទំនាញសូរ ព្រមទាំងពីមូលហេតុឱ្យបានច្បាស់លាស់ ។

ខ. ដោយសិក្សាពាក្យ១ព្យាង្គ រកបំពេក អ-អ៊ ឬសូរស្រៈ "អ" សូរស្រៈ "អ៊" និងសូរស្រៈពួក "អ-អ៊" (ក្នុងសូរស្រៈនីមួយៗ

សិក្សាតែ១ពាក្យ) ។

គ. ដោយសិក្សាពាក្យ១ព្យាង្គ រកព្យាង្គធ្ងន់ក្នុងវគ្គ ជាព្យាង្គ ( បិទខ្លី-វែង ឬបើកខ្លី-វែង) ហើយសរសេរជាសូរវិទ្យាអន្តរជាតិ API ដោយប្រាប់ពីទម្រង់និងសទ្ទ ។

**ចម្លើយ**

១. អត្ថបទដកស្រង់ខាងលើនេះស្ថិតក្នុងចលនាអក្សរសិល្ប៍ខេមរនិយម ។

+ **អំណះអំណាងបញ្ជាក់** : បានជាហ៊ានអះអាងដូចនេះព្រោះដំណើររឿងក្នុងវគ្គដកស្រង់នេះ បានបង្ហាញពីជីវភាព និងផ្នត់គំនិតខ្មែរពិតៗដូចជា៖

- ជំនឿទៅលើព្រះពុទ្ធសាសនា ហើយនិយមស្ដាប់ព្រះសង្ឃសម្ដែងធម៌ទេសនា
- ការនិយមសិល្បៈស្មូត្រ
- ជំនឿទៅលើមន្តអាគមគាថា
- ព្រះសង្ឃអាចធ្វើអាជីវកម្មបានក្នុងការផ្គត់ផ្គង់វត្តអារាម
- ចំណែកតួអង្គវិញក៏បង្ហាញពីឈ្មោះដែលមានលក្ខណៈជាខ្មែរដែរ ( ទាវ ទុំ...) ។

២. តាមរយៈអត្ថបទដកស្រង់នេះ កវីបានប្រើវិធីតែងនិពន្ធសំខាន់ៗដូចតទៅ ៖

- **ពណ៌នាវិធី** : កវីរៀបរាប់ដំណើររឿង *"...ដល់ផ្ទះម្ដាយទាវចុះមកឆាប់ ដល់ដីឱនក្រាបប្រណម្យនៅ..."*។
- **សំវាទវិធី** : តួអង្គសន្ទនាគ្នា

*"ទាវរៀបផ្គងស្រេចចាប់កាន់ដើរ ដល់មកជិតស្ទើនឹងនោស្រី ថាហាកនោបងចូរប្រណី ប្រគេនបារីស្លាផាហ៊ុម"។*

- **វចនវិធី :** គឺប្រើពាក្យពេចន៍ចម្រុះ ៖
  + **ពាក្យខ្មែរ :** ច្របាមាត់ ហាក បង ប្រេងម្សៅ...
  + **ពាក្យកម្ចីសៀម :** សាវ ផាហ៊ុម
  + **ពាក្យកម្ចីបាលី សំស្ក្រឹត :** ព្រាហ្មណាចារ្យ សត្យា មន្ត សព្ទ....។
  + **ពាក្យសង្ឃសព្ទ :** ឆាន់
- **រចនាវិធី :** គឺតែងជាពាក្យកាព្យបទពាក្យ៧យ៉ាងពិរោះរណ្ដំ ជាប្រភេទកាព្យនិទាន។
- **និទានវិធី :** គឺប្រើវិធីនិទានបែបបុរសទី៣។

*នេនទុំទទួលគ្រឿងបរិក្ខា ស្រេចស្រាយយកស្លាឆាន់រួចនៅឈប់អង់បន្តិចសែកប្រេងម្សៅ រំលឹកដល់ទៅមន្តសារិកា។*

- **ឯកវាទវិធី :** គឺបានឱ្យតួអង្គទុំមានអារម្មណ៍ជ្រួលច្របល់តែម្នាក់ឯង ដោយក្ដីរំភើបញាប់ញ័រ នៅពេលបានឃើញនាងទាវ។

៣. លក្ខណៈអក្សរសិល្ប៍តាមរយៈអត្ថបទដកស្រង់នេះ ៖

+ **លក្ខណៈជាតិ**

- គោរពពុទ្ធសាសនា (ទុំបួសក្នុងសំណាក់ពុទ្ធសាសនា)
- ចូលចិត្តស្ដាប់ធម៌ទេសនា (ម្ដាយទាវបាននិមន្តទុំទៅសូត្រទេសនាឱ្យស្ដាប់នៅផ្ទះ)
- និយមឱ្យកូនស្រីចូលម្លប់ (នាងទាវចូលម្លប់)

- និយមរៀបចំគ្រឿងរណ្ដាប់បូជាព្រះធម៌ (នាងទាវរៀបចំរណ្ដាប់ផ្សេងៗឱ្យនោយកទៅប្រគេនទុំដើម្បីបានកុសលផលបុណ្យ)
- ចាស់ៗ និងព្រះសង្ឃចូលចិត្តពិសា/ឆាន់ម្លូ ស្លា បារី
- ផ្នែកសិប្បកម្ម ខ្មែរមានសមត្ថភាពផលិតតោក ទឹកអប់សាប៊ូ ផាហ៊ុម ជន្លាប់។

• **លក្ខណៈមនុស្ស** : បង្ហាញពីសកម្មភាព និងចរិតលក្ខណៈរបស់មនុស្សដែលមាននៅក្នុងសង្គម តាមរយៈតួអង្គទុំ និទាវដូចជា៖

- នាងទាវមានចិត្តអន្ទះសារចង់ឃើញរូបសម្រស់ទុំ។
- នាងទាវបង្ហាញចរិតបែបក្មេងសាវ នៅមិនសុខ ឆ្លេឆ្លាពេលឃើញប្រុសកំលោះ។
- ទុំលួចសម្លឹងមើលទាវដោយអារម្មណ៍ព្រឺព្រួច រួចបន្លំដាក់ស្នេហ៍នាងទាវ (មន្តសារិកា)។

• **លក្ខណៈប្រជាជន** : គឺបានបង្ហាញពីផ្នត់គំនិតរបស់ប្រជាជនយើងដែលមានចំណង់ចំណូលចិត្តស្ដាប់រឿងទសជាតក និងចូលចិត្តនិមន្តព្រះសង្ឃទៅផ្ទះរបស់ខ្លួនដើម្បីឱ្យលោកទេសន៍រឿងនានាបានស្ដាប់សម្រាប់ជាគតិក្នុងការអប់រំទូន្មានខ្លួន។

• **លក្ខណៈប្រវត្តិ** : គឺបានលាតត្រដាងពីជីវភាពខ្មែរនាសម័យលង្វែក ដែលជាប្រវត្តិរបស់ខ្មែរសម័យបុរាណមួយដែលមានសុវត្ថិភាព ស្ថិរភាព និងអត្តសញ្ញាណច្បាស់លាស់។

• **លក្ខណៈសង្គម** : គឺបានលើកយកបញ្ហាមនុស្សសម័យលង្វែក

មកចោទនិងដោះស្រាយតាមរយៈតួអង្គទុំនិងទាវ ដែលតំណាងឱ្យយុវជនសម័យលង្វែក ឆាប់មានអារម្មណ៍ជ្រួលច្របល់ក្នុងផ្លូវស្នេហា។ ឥរិយាបថនេះបណ្ដាលមកពីពួកគេស្ថិតនៅក្នុងសម័យកាលមួយដែលហ៊ុមព័ទ្ធដោយប្រពៃណីដ៏តឹងរឹង ហើយគាបសង្កត់នូវបំណងប្រាថ្នារបស់យុវវ័យ ។

៤. ក្នុងសម័យកាលនោះ ជនជាតិខ្មែរបានទទួលឥទ្ធិពលពីសាសនាព្រះពុទ្ធ និងសាសនាព្រាហ្មណ៍ ។

*អំណះអំណាង :*

- **ឥទ្ធិពលព្រះពុទ្ធសាសនា** : នេនទុំ ជាព្រះសង្ឃក្នុងព្រះពុទ្ធសាសនា ដែលចេះស្មូត្រ និងចេះទេសនាមហាវេស្សន្តរជាតកក្នុងគម្ពីរពុទ្ធសាសនាយ៉ាងពិរោះ ។
- **ឥទ្ធិពលព្រាហ្មណ៍សាសនា** : នេនទុំចេះមន្តស្នេហ៍ អាគមគាថាសារិកាលិនថោង ដែលស្ថិតនៅក្នុងគម្ពីរវេទនៃព្រាហ្មណ៍សាសនា *"...រំលឹកទៅដល់មន្តសារិកា លិនថោងករវិករំលឹករក សម្ដិលីហៅយកមណីចិន្ដា..."*។

៥. គតិភាពសង្គមខ្មែរនាសម័យនោះ គឺ៖

- ប្រជាជនខ្មែរនិយមគោរពព្រះពុទ្ធសាសនា
- និយមសិល្បៈស្មូត្រ
- ព្រះសង្ឃអាចធ្វើអាជីវកម្មផ្គត់ផ្គង់វត្តអារាម
- ប្រពៃណីកូនស្រីត្រូវចូលម្លប់ កូនប្រុសត្រូវបួសរៀន
- ខ្មែរអាចផលិតរបស់ប្រើប្រាស់តាមរយៈសិប្បកម្ម( សាប៊ូទឹកអប់ ផាហ៊ុម ជន្លាប់...)

៦. "លិនចោងករវិករំលឹករក សម្ពិលីហៅយកមណីចិន្តា លូកយក ប្រទាលឆាន់នឹងស្លា ស្ងួត្រសាគ្រប់សព្វចប់ជាម្តង" ៖

**ក. រកពាក្យ១ព្យាង្គទំនាញសួរ និងគ្មានទំនាញសួរ**

- ពាក្យទំនាញសួរ : ស្លា
  - + ស្ល = ស + ល > ស + ល៏

    [ខ្យល់បង្ហូរ "អ" + ខ្យល់បង្ហូរ "អ៊" = "អ" ]
- ពាក្យគ្មានទំនាញសួរ : ម្តង
  - + ម + ដ > ម/ដ > ម្ត

    [ខ្យល់ច្រមុះ "អ៊" + ខ្យល់ស្ទះ "អ" = "អ" ]

**ខ. រកបញ្ចេក អ-អ៊ ឬសូរស្រះ "អ" សូរស្រះ "អ៊" និងសូរស្រះពួក "អ-អ៊"**

- សូរស្រះ "អ" : ចោង
- សូរស្រះ "អ៊" : លិន
- សូរស្រះ "អ-អ៊" : (គ្មាន)

**គ. រកព្យាង្គចួនក្នុងវគ្គ**

រក ⊨⊣ យក

- រក [rɔ:k] ទម្រង់ "ពសព" ជាព្យាង្គបិទវែង
  - + [រ] ជាសទ្ទដើមព្យាង្គ
  - + [អ៊] ជាសទ្ទកណ្តាលព្យាង្គ
  - + [ក] ជាសទ្ទចុងព្យាង្គ
- យក [jɔ:k] ទម្រង់ "ពសព" ជាព្យាង្គបិទវែង
  - + [យ] ជាសទ្ទដើមព្យាង្គ

• [អិ] ជាសទ្ទកណ្តាលព្យាង្គ
• [ក] ជាសទ្ទចុងព្យាង្គ



## ការវិវត្តនៃភាសាខ្មែរ

### សំណួរ

១. តើភាសាខ្មែរមានវិវត្តន៍ប៉ុន្មានលើក? ចូរបង្ហាញពីស្ថានភាពភាសាខ្មែរតាំងពីសម័យអាណានិគមបារាំង និងសម័យក្រោយមកទៀត តាមរយៈអត្ថបទនេះ ។

២. ក្នុងភាសាខ្មែរ គេអាចចែកស្នូរស្រៈបានប៉ុន្មានយ៉ាង? តើមានអ្វីខ្លះ?

៣. តើគេអាចស្គាល់មូលភេទ អ-អិ ដោយប្រការណាខ្លះ?

៤. បើយោលទៅតាមអត្ថបទនេះ តើពាក្យខ្មែរអាចបង្កើតដោយវិធីណាខ្លះ? ចូរបង្ហាញពីវិធីនីមួយៗភ្ជាប់ជាមួយឧទាហរណ៍មកបញ្ជាក់ ។

៥. ដូចម្តេចហៅថា វិធីជួនរណ្តំ និងវិធីផ្ទួនជួនរណ្តំ? ចូររកឧទាហរណ៍មកបញ្ជាក់ដោយកត់ស្នូរឱ្យត្រឹមត្រូវ ។

៦. ចូរអ្នកធ្វើការប្រៀបធៀបរវាងវិធីជួនរណ្តំ និងវិធីផ្ទួនរណ្តំ ហើយ វិធីផ្ទួន និងផ្ទួនជួនរណ្តំ ។

### ចម្លើយ

១. ភាសាខ្មែរមានវិវត្តន៍បីលើកមកហើយ គឺ៖
- ភាសាខ្មែរបុរាណតាំងពីកំណាក់កំណើតរហូតមកដល់ស.វ. ១៤
- ភាសាខ្មែរកណ្ដាល ស.វ.១៥ដល់ស.វ.១៩
- និងភាសាខ្មែរបច្ចុប្បន្ន ស.វ.១៩ តរៀងមក។

***ស្ថានភាពភាសាខ្មែរ៖***

- **សម័យអាណានិគមបារាំង** ភាសាខ្មែរបានថយល្បឿននៃវិវត្តន៍របស់ខ្លួន ព្រោះបារាំងបង្ខំឱ្យខ្មែររៀនភាសាបារាំង។ ចំណែកភាសាខ្មែររត់ទៅសំងំក្នុងវត្តអារាម ដែលមានព្រះសង្ឃជួយថែរក្សាទុកឱ្យ។
- **សម័យក្រោយមកទៀត** គឺសម័យឯករាជ្យភាសាខ្មែរបានប្រកាសឱ្យប្រើជាផ្លូវការ។ សម័យនេះមានការបង្កើតពាក្យថ្មីៗជាច្រើន ដើម្បីប្រើការឱ្យទាន់សម័យនិយម។ គេប្រទះឃើញពាក្យបរទេសជាច្រើននៅលាយឡំក្នុងភាសាខ្មែរ គឺពាក្យបាលី សំស្ក្រឹត និងពាក្យបារាំង។

២. ក្នុងភាសាខ្មែរ គេអាចចែកសូរស្រៈបានបីយ៉ាង គឺ សូរពួក "អ" សូរពួក "អ៊" និងសូរពួក "អ-អ៊"។

៣. គេអាចស្គាល់មូលភេទ អ-អ៊ ដោយសារ៖
- ប្រការទី១ : តាមលក្ខណៈខ្យល់នៃព្យញ្ជនៈ

  + ព្យញ្ជនៈពួកអ : កខ ចឆ ដឋណ តថ បផ សហឡអ

  + ព្យញ្ជនៈពួកអ៊ : គឃង ជឈញ ឌឍ ទធន ពភម យរលវ

- ប្រការទី២ : តាមសូរស្រៈ
    + សូរស្រៈពួកអ : អ[ɒ:] អា[a:] អិ[e̥] អី[ɛi] ...
    + សូរស្រៈពួកអ៊ : អ៊[ɔ:] អ៊ា[i:ə] អ៊ិ[i] អ៊ី[i:] ...
- ប្រការទី៣ : តាមលក្ខណៈខ្យល់នៃព្យាង្គ
    + ព្យាង្គពួកអ : ឧ. កា ដើរ...
    + ព្យាង្គពួកអ៊ : ឧ. ទា លើ...

៤. បើយោលទៅតាមអត្ថបទនេះ ពាក្យខ្មែរអាចបង្កើតដោយវិធីកំលាយដោយផ្នត់ដើម និងកំលាយដោយផ្នត់ជែក ។

**+ កំលាយដោយផ្នត់ដើម មានទម្រង់ "ព-" "ពស-" "ពពស-" និង "ពសព-"**

ក. ទម្រង់ "ព-" : កើតមកពីព្យញ្ជនៈទោលតែមួយប៉ុណ្ណោះ ហើយមានផ្នត់ [ក-] [ច-] [ត-] [ប-] [ស-]

ឧ. [ក-] + ជះ > ខ្ជះ
[ត-] + រ៉ុយ > ត្រ៉ុយ

ខ. ទម្រង់ "ពស-" : ប្រើសម្រាប់បង្កើតពាក្យពីរព្យាង្គ ហើយមានផ្នត់ [ក-] [ច-] [ត-] [ប-] [ស-]

ឧ. [ប-] + បោស > បបោស
[ស-] + សិត > សសិត

គ. ទម្រង់ "ពសព-" : ប្រើសម្រាប់បង្កើតពាក្យក្លាយពីរព្យាង្គ ហើយមានផ្នត់ [ក ់ង-] [ច ់ង-] [ប ់ង-] [ស ់ង-] [អ ់ង-] [ក ់ន-] [ក ់ម-] [ប ់ន-] [ប ់ញ-] [ព ់ន-] [ព ់ង-]

[បំម-] [សំម-] [រំម-] [លំម-] [កំញ-]...

ឧ. [កំង-] + វៀច > កង្វៀច

ឃ. ទម្រង់ "ពពស." : ប្រើសម្រាប់បង្កើតពាក្យក្លាយពីរព្យាង្គ ហើយមានផ្នត់ [ក្រ-] [ត្រ-] [ប្រ-] [ស្រ-] ...

ឧ. [ប្រ-] + ចាក់ > ប្រចាក់

**+ កំលាយដោយផ្នត់ដែក មានទម្រង់ "-ព-" "-សព-" "-ស/ព-" និង "-សព/ព-"**

ក. ទម្រង់ "-ព-" : មានផ្នត់ [-ន-] [-ប-] [-ម-]

ឧ. [-ន-] + កើយ > ខ្នើយ

ខ. ទម្រង់ "-ស/ព-" : មានផ្នត់ [-អិ/ន-] [-អិ/ប-] [-អោ/ប-]

ឧ. [-អិន-] + រាប > រនាប

គ. ទម្រង់ "-សព-" : មានផ្នត់ [-អំង-] [-អិំង-] [-អំន-] [-អិំន-] [-អំម-] [-អិំម-] [-អំញ-]

ឧ. [-អំម-] + ត្រូវ > តម្រូវ

ឃ. ទម្រង់ "-សព/ព-": មានផ្នត់ [-អំម/ន-][-អិំម/ន-]

ឧ. [-អំម/ន-] + កក > កំណក

៥. + **វិធីច្នួនរណ្តំ** ជាវិធីដែលកវីប្រើព្យាង្គច្នួនផង រណ្តំផងក្នុងឃ្លាតែមួយ។

ឧ. ពពិតពពិលរមិលមើល

ពិល ⟝⟞ មិល

ពិត ⟝ ពិល (រណ្ដំ "ព")

មិល ⟝ មើល (រណ្ដំ "ម")

+ **វិធីផ្ទួនរណ្ដំ** ជាវិធីដែលកវីប្រើព្យាង្គផ្ទួនផង រណ្ដំផងក្នុងឃ្លាតែមួយ ។

ឧ. គ្រលឹងគ្រលោង

- ផ្ទួន "គ្រ"
- លឹង ⟝ លោង (រណ្ដំ "ល")

+ **វិធីផ្ទួនចួនរណ្ដំ** ជាវិធីដែលកវីប្រើព្យាង្គផ្ទួនផង ចួនផង រណ្ដំផងក្នុងឃ្លា ឬវគ្គជាមួយគ្នា ។

ឧ. កុំខ្ញើកតាមខ្យល់ កុំខ្វល់តាមរលក... ។

-ព្យាង្គផ្ទួន : កុំ តាម

-ព្យាង្គចួន : ខ្យល់ ⟝⟞ ខ្វល់

-ព្យាង្គរណ្ដំ : ខ្ញើក ⟝ ខ្វល់ (រណ្ដំ "ខ្វ")

៦. ប្រៀបធៀបរវាង

- **វិធីចួនរណ្ដំ និងវិធីផ្ទួនរណ្ដំ**

+ វិធីចួនរណ្ដំ : ជាវិធីម្យ៉ាងដែលកវីប្រើព្យាង្គពីរឬច្រើនបន្តបន្ទាប់គ្នាយកមកធ្វើជាព្យាង្គចួនផងនិងព្យាង្គរណ្ដំផង

ក្នុងឃ្លាតែមួយ ។

ឧ. ពិតពិលរមិលមើល

+ វិធីផ្ទួនរណ្ដំ : ជាវិធីម្យ៉ាងដែលកវីប្រើព្យាង្គពីរ ឬច្រើន បន្តបន្ទាប់គ្នាយកមកធ្វើជាព្យាង្គផ្ទួនផង និងព្យាង្គរណ្ដំផង ក្នុងឃ្លាតែមួយ ។

ឧ. គ្រលីងគ្រលោង

សន្និដ្ឋាន : ដូចនេះវិធីចួនរណ្ដំនិងវិធីផ្ទួនរណ្ដំខុសគ្នាត្រង់ថា វិធីចួនរណ្ដំមានព្យាង្គចួន តែគ្មានព្យាង្គផ្ទួនទេ ។ ឯវិធីផ្ទួនរណ្ដំមានព្យាង្គផ្ទួន តែគ្មានព្យាង្គទេ ។

- **វិធីផ្ទួន និងផ្ទួនចួនរណ្ដំ**

+ វិធីផ្ទួន : ជាវិធីម្យ៉ាងដែលកវីប្រើពាក្យឬព្យាង្គតែមួយ ដដែល ៗនៅក្នុងឃ្លាឬវគ្គតែមួយ ។

ឧ. ស្រគុកគុក ទ្រមាកមាក

+ វិធីផ្ទួនចួនរណ្ដំ : ជាវិធីម្យ៉ាងដែលកវីប្រើព្យាង្គពីរ ឬច្រើនយកមកធ្វើជាព្យាង្គផ្ទួនផង ព្យាង្គចួនផង និងព្យាង្គរណ្ដំផងក្នុងឃ្លាឬវគ្គតែមួយ ។

ឧ. កុំខ្ញើកតាមខ្យល់ កុំខ្វល់តាមរលក

# តែងសេចក្តីបែបពិភាក្សា

## ១. និយមន័យ

តែងសេចក្តីបែបពិភាក្សា គឺជាតែងសេចក្តីមួយប្រភេទ ដែលតម្រូវឱ្យអ្នកតែងលើកយកមតិរបស់ប្រធានមកពិចារណា វែកញែករកខុសត្រូវ រកល្អអាក្រក់ សមឬពុំសម មានប្រយោជន៍ឬឥតប្រយោជន៍ ជាគុណឬជាទោស ។ល។ ដើម្បីយកមតិទាំងអស់មកថ្លឹងថ្លែងមើល តើមតិណាសមរម្យជាង ។

ជាទូទៅប្រធានពិភាក្សាគឺមានមតិពុំស្របគ្នា ហើយច្រើនស្ថិតនៅលើទ្រឹស្តីបដិសំយោគ ដែលមាន ៖

-មតិទី១ ឬ មតិស្រប

-មតិទី២ ឬ មតិផ្ទុយ

-មតិសំយោគ ឬ មតិពិភាក្សា

## ២. គន្លឹះដើម្បីស្គាល់ប្រធាន

### ២.១. ការបញ្ចេញមតិ

– គេពោលថា "..............."

– មតិមួយលើកឡើងថា "..........."

– មានទស្សនៈជាច្រើនយល់ថា "..............."

– មានទស្សនៈខ្លះយល់ថា "........" ឯអ្នកខ្លះទៀតថា

"......." ទៅវិញ ។ ល ។

### ២.២. ពាក្យចោទសួរ

- តើអ្នកយល់យ៉ាងណា ?
- តើអ្នកយល់ដូចម្ដេច ?
- តើមតិនេះត្រូវ ឬខុស ?
- តើមតិណាមួយត្រឹមត្រូវជាង ?
- តើមតិណាមួយសមរម្យជាង ?
- តើអ្នកមានយោបល់ដូចម្ដេចដែរ?
- តើមតិនេះគ្រប់គ្រាន់ហើយឬនៅ?
- តើតើទស្សនៈខាងលើ មួយណាត្រូវមួយណាខុស?.....

### ២.៣. ពាក្យបញ្ជាប់

- ចូរពិភាក្សា
- ចូរវែកញែករកខុស ត្រូវ
- ចូរពិចារណា
- ចូរវិនិច្ឆ័យ
- ចូររិះគន់ ។ល ។

## ៣. វិធីសាស្ត្រតែងប្រធានពិភាក្សា

### ៣.១. សេចក្ដីផ្ដើម

-លំនាំបញ្ហា :( ដូចប្រធានពន្យល់ )

-ចំណូលបញ្ហា : ( ដូចប្រធានពន្យល់ )

-ចំណោទបញ្ហា: ចោទសួរទៅលើប្រធាន ( បែបពិភាក្សា ) ។

*** បើប្រធានមានមតិតែមួយត្រូវចោទថា :**

- តើ......................ត្រឹមត្រូវឬទេ ?
- តើ......................សមស្របឬទេ ?
- តើ......................ត្រូវឬខុស ?

*** បើប្រធានមានមតិពីរខ្វែងគ្នា ឬ ផ្ទុយគ្នាក្នុងរឿងតែមួយ យើងគួរចង់ថាមតិទីមួយជាមតិស្រប ឯមតិពីរជាមតិផ្ទុយ ។ យើងត្រូវចោទថា :**

- តើមតិទាំងពីរខាងលើ មួយណាត្រឹមត្រូវជាង ?
- តើមតិទាំងពីរខាងលើ មួយណាខុស មួយណាត្រូវ?

*** បើប្រធានមានមតិពីរក្នុងរឿងពីរផ្សេងគ្នា យើងត្រូវចោទថា :**

- តើមតិទាំងពីរខាងលើនេះ ត្រឹមត្រូវឬទេ ?

## ៣.២. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី
- ពន្យល់ពាក្យពិបាក ឬពាក្យគន្លឹះ
- ពន្យល់ន័យរបស់ប្រធាន

*** បកស្រាយ**

+ **មតិស្រប** : ពន្យល់បកស្រាយបង្ហាញគំនិតគាំទ្រដល់មតិរបស់ប្រធាន (ឬមតិទី១ ប្រសិនបើប្រធានមានមតិពីរ) ព្រមទាំងលើកភស្តុតាង ឬឧទាហរណ៍បញ្ជាក់ឱ្យបានច្បាស់លាស់ ។

– សរុបមតិស្រប (តើពិតជាអ៊ីចឹងមែន)

– សំណួរភ្ជាប់មតិស្របទៅមតិផ្ទុយ (*តើ...ពិតជាអ៊ីចឹងមែនឬ? តើ.......ពិតមែនឬយ៉ាងណា?.....*)

+ **មតិផ្ទុយ** : លើកទស្សនៈពន្យល់ឱ្យលំអៀង ឬឱ្យផ្ទុយពីមតិស្រប (ឬគាំទ្រមតិទី២ ប្រសិនបើប្រធានមានមតិពីរ) និងលើកឧទាហរណ៍បញ្ជាក់ ។

– សរុបមតិផ្ទុយ (តើពិតជាអ៊ីចឹងមែន)

+ **សំយោគមតិ** : គឺជាការផ្សំមតិគ្នា ឬបំពេញគ្នាទៅវិញទៅមករវាងមតិស្រប និងមតិផ្ទុយ ។ (មតិស្រប និងមតិផ្ទុយបំពេញឱ្យគ្នាទៅវិញទៅមក)

+ **មតិពិភាក្សា** : គឺជាការថ្លឹងថ្លែងវិនិច្ឆ័យរវាងមតិស្រប និងមតិផ្ទុយ ដើម្បីប្រមើលមើលរកមតិដែលត្រឹមត្រូវ ។

⇨ អ្នកតែងត្រូវពិចារណាដោយខ្លួនឯងថា តើប្រធាននោះជាសំយោគមតិ ឬជាមតិពិភាក្សា រួចវាយតម្លៃថា ៖

⇨ **បើជាសំយោគមតិ**

– ប្រធានមានមតិមួយ ត្រូវខ្លះ ខុសខ្លះ

– ប្រធានមានមតិពីរ ត្រូវខ្លះ ខុសខ្លះដូចគ្នា (មតិទី១+មតិទី២ ឬ មតិទី១+មតិទី២+មតិបន្ថែម)

⇨ **បើជាមតិពិភាក្សា**

– មតិមួយត្រូវ មតិមួយខុស

**៣.៣. សេចក្ដីបញ្ចប់**

- វាយតម្លៃប្រធាន : មតិប្រធានត្រឹមត្រូវឬទេ ? ត្រូវឬខុស?

-ទស្សនៈផ្ទាល់ខ្លួន : សំណូមពរ ឬមតិចូលរួមក្នុងការអភិវឌ្ឍ ។

## ☝ ចំណាំ

*តែងសេចក្តីបែបពិភាក្សា ចែកចេញជាពីរប្រភេទ គឺ៖*

- ប្រធានពិភាក្សាសុទ្ធ : ប្រធានមានមតិតែមួយ ។
- ប្រធានពិភាក្សាប្រៀបធៀប : ប្រធានមានមតិពីរ ។

*ប្រភេទទាំងពីរនេះ គេអាចចែកជាពីរទៀត គឺ៖*

- ប្រធានពិភាក្សាពេញលេញ
  - ➢ ប្រធានមានមតិតែមួយ ខុសស្រលះ
  - ➢ ប្រធានមានមតិមួយ ត្រូវខ្លះ ខុសខ្លះ
  - ➢ ប្រធានមានមតិពីរ ត្រូវមួយ ខុសមួយ
- ប្រធានពិភាក្សាមិនពេញលេញ
  - ➢ ប្រធានមានមតិពីរជានិច្ច ហើយមតិនីមួយៗ សុទ្ធតែមានហេតុផលត្រឹមត្រូវរៀងៗខ្លួន ។

### ក) ប្រធានពិភាក្សាពេញលេញ

**ក₁. ចំណោទបញ្ហា**

- តើ.......ខាងលើនេះត្រឹមត្រូវដែរឬទេ? ( ប្រធាន
- មានមតិតែមួយ)
- តើ.......ទាំងពីរខាងលើនេះ មួយណាត្រូវមួយណា

ខុស? (ប្រធានមានមតិពីរ)

ក២. មតិពិភាក្សា

- មតិប្រធានមានមួយខុសស្រលះ
- មតិទាំងពីរ មួយត្រូវ មួយខុស

ក៣. មតិសំយោគ

- មតិប្រធានមានមួយ ត្រូវខ្លះ ខុសខ្លះ
- មតិប្រធានមានពីរ ត្រូវខ្លះ ខុសខ្លះ

ខ) ប្រធានពិភាក្សាមិនពេញលេញ

ខ១. ចំណោទបញ្ហា

- តើ.......ទាំងពីរខាងលើនេះត្រឹមត្រូវគ្រប់ជ្រុងជ្រោយដែរឬទេ?

ខ២. មតិសំយោគ

- លើកយកមតិទី១មកបញ្ជាក់ថាមានលក្ខណៈត្រឹមត្រូវម្យ៉ាង ព្រោះ....
- លើកយកមតិទី២មកបញ្ជាក់ថាមានលក្ខណៈត្រឹមត្រូវម្យ៉ាងដែរ ព្រោះ....
- ទោះបីជាមតិទាំងពីរមានលក្ខណៈត្រឹមត្រូវរៀង១ខ្លួនក៏ដោយ តែពុំទាន់ត្រឹមត្រូវពេញលេញដោយខ្លួនឯងឡើយលុះត្រាតែ :
  - ➢ មតិទី១ + មតិទី២
  - ➢ មតិទី១ + មតិទី២ + មតិបន្ថែម

## គោលសំខាន់ៗនៃសាសនាព្រាហ្មណ៍

### សំណួរ

១. តើសាសនាព្រាហ្មណ៍ចែកចេញជាប៉ុន្មានសម័យកាលធំៗ? អ្វីខ្លះ?
២. តើគម្ពីរវេទមានអ្វីខ្លះ? ចូរបង្ហាញមុខងារនៃគម្ពីរនីមួយៗ។
៣. តាមសាសនាព្រាហ្មណ៍ តើអវតាព្រះវិស្ណុមានប៉ុន្មាន? អ្វីខ្លះ?
៤. ចូរបង្ហាញពីបុព្វហេតុនៃទុក្ខតាមលទ្ធិវេទនិយម។
៥. ចូរបង្ហាញពីវិធីបង្កើតសុខៈតាមវេទនិយម។

### ចម្លើយ

១. សាសនាព្រាហ្មណ៍ចែកចេញជាបីសម័យកាលធំៗ គឺ៖
- សម័យវេទនិយម (១៥០០-៥៥០ មុនគ.ស.)
- សម័យព្រាហ្មណ៍និយម (៥៥០ មុនគ.ស. - ស.វ.១០ នៃ គ.ស)
- សម័យហិណ្ឌូនិយម (ស.វ.១០ នៃគ.ស. រហូតមក)

២. គម្ពីរវេទមាន៖
- ឬគវេទ(ឫគ្វេទ): គឺវេទសម្រាប់សូត្របួងសួង សរសើរ

អាទិទេព ដូចជាព្រះឥន្ទ្រ ព្រះរុទ្រៈ ព្រះវាយុ ព្រះអគ្គិ ព្រះអាទិត្យ ព្រះធរណី ព្រះចន្ទ្រ ព្រះវរុណៈ។ល។ ដើម្បីធ្វើឱ្យអាទិទេពពេញចិត្ត ហើយជួយឱ្យបានសម្រេចបំណងផ្សេងៗ។

- **សាមវេទ :** ជាកម្រងអត្ថបទគាថាដែលពួកព្រាហ្មណ៍៖

+ សូត្រសរសើរអាទិទេពទាំងឡាយដូចជាព្រះឥន្ទ្រ ព្រះយម ព្រះសោមៈ ព្រះព្រហស្បតិ៍ ព្រះអគ្គិ ជាដើម។

+ ច្រៀងនៅក្នុងស្រុកភូមិ ពីព្រោះនាំឱ្យកើតជ័យមង្គលសិរីសួស្តី។

+ ច្រៀងតែក្នុងព្រៃ ពីព្រោះនាំឱ្យវៀរចាកចង្រៃអន្តរាយដល់ស្រុកភូមិ។

+ពន្យល់ឱ្យចេះធ្វើបទ ឱ្យចេះផ្លាស់ប្តូរបទក្នុងពេលសូត្រឱ្យជាវែង ជាខ្លី ឬជាដដែលៗ។ អត្ថបទសាមវេទខ្លះទៀតនិយាយពីហេតុអស្ចារ្យផ្សេងៗ និយាយពីរឿងព្រេងរបស់ជនដែលមានឥទ្ធិពលមកលើពួកអរិយយាង ។ល។

- **យជុរវេទ :** គឺជាកម្រងអត្ថបទគាថា ឬមន្ត្រ សម្រាប់សូត្រក្នុងពិធីបូជាយញ្ញ និងសម្រាប់ពន្យល់ឱ្យចេះធ្វើវិត៌ (ពិធីបុណ្យក្នុងសាសនា)។

- **អថើវេទ ឬអថព្វវេទ** : ពុំមែនជាវេទអធិប្បាយពីការបូជា ការបួងសួង ឬសូត្រសរសើរដូចវេទទាំង៣ខាងដើមទេ ផ្ទុយទៅវិញវេទនេះនិយាយពីមន្តអាគម អាគមគាថាសូត្រឱ្យសះស្បើយជំងឺ ឱ្យមានអាយុវែង ឱ្យស្រីស្រឡាញ់

ឱ្យស្ងប់ស្ងួយចិត្ត ឱ្យផុតឧបទ្រពចង្រៃ បណ្ដេញខ្មោចបិសាច ឱ្យបានសុខចម្រើន មានសិរីសួស្ដី ឱ្យឈឺចុកចាប់ឆ្កួតវង្វេង ។ល។

៣. តាមសាសនាព្រាហ្មណ៍ អវតារព្រះវិស្ណុមាន១០ គឺ ៖

- ត្រី មច្ឆៈ
- អណ្ដើក កុមិះ
- ជ្រូកព្រៃ វិរាហៈ
- មនុស្សសិង្ហ នរសិង្ហ
- មនុស្សតឿ វាមនៈ
- បរសុរាម ជាព្រះរាមកាន់ពូថៅ
- មនុស្សទេវៈ ព្រះរាម
- មនុស្សខ្មៅ ក្រឹស្ណ
- ពុទ្ធៈ (ការពិតព្រះពុទ្ធ មិនមែនជាអវតារវិស្ណុឡើយ)
- មនុស្សសេះ កល្កិន ។

៤. តាមលទ្ធិវេទនិយម ទុក្ខកើតឡើងដោយសារ ៖

- កម្មិន ពេលណាអាត្មនដាច់ចេញពីព្រហ្មន ហើយចូលទៅនៅជាមួយធាតុលោកៈពុំបរិសុទ្ធ ពេលនោះមានកម្មិនដែលនាំឱ្យកើតទុក្ខ ។
- សំសារៈ ហើយអាត្មនពុំបានវិលទៅជួបនឹងព្រហ្មនវិញភ្លាមទេ អាត្មនត្រូវវិលវល់ពីជាតិមួយទៅជាតិមួយទៀត ។ ការវិលវល់នៃអាត្មនដូច្នេះហៅថា សំសារៈដែលជាប្រភពនៃទុក្ខ ។

- **អវិជ្ជា** គឺការល្ងង់ខ្លៅមិនយល់ថា អាត្ម័ន និងព្រហ្ម័នជាសភាវៈតែមួយ ហើយមិនដឹងថាត្រូវធ្វើយ៉ាងណា ដើម្បីឱ្យអាត្ម័នអាចទៅជួបព្រហ្ម័នវិញបាន។ ដូច្នេះអវិជ្ជា ជាប្រភពនៃទុក្ខ។

៩. វិធីបង្កើតសុខៈតាមវេទនិយម មានពីរយ៉ាង ៖

- **វិធីបង្កើតសុខៈធម្មតា** គេជឿថាសុខៈកើតឡើងដោយសារអាទិទេព។ ដូច្នេះត្រូវប្រកាន់វណ្ណៈធ្វើពិធីបូជាយញ្ញ រៀនវេទ និងសូត្រមន្តអាគមបំពេញតបៈ។
- **វិធីបង្កើតបរមសុខៈ** ត្រូវអនុវត្តវេទវិធីនេះឱ្យម៉ត់ចត់ដើម្បីសម្រេចមោក្សៈ គឺការរួចផុតទុក្ខទោសពីការវិលកើតវិលស្លាប់ក្នុងសំសារៈ។ សុខៈវិធីដែលព្រាហ្មណ៍ទូន្មានឱ្យអនុវត្តឆ្ពោះទៅរកបរមសុខគឺ ៖

  + សុខវិធីទី១ : វិធីបង្កើតសុខធម្មតា នៅតែអនុវត្តបន្តជាបន្ទាប់បន្សំ

  + សុខវិធីទី២ : ត្រូវបួសជាតាបសឬសី ហើយអនុវត្តឬសីវិធី២ គឺតបៈ និងយោគៈ

  + សុខវិធីទី៣ : ការបង្កើតវិជ្ជា។ វិជ្ជាបរិសុទ្ធ ឬពុទ្ធិខ្ពង់ខ្ពស់ គឺជឿថាមានអាទិទេពជាអ្នកខ្លាំងពូកែសព្វយ៉ាងជាអ្នកបង្កើតលោក និងជឿថាអាត្ម័ននិងព្រហ្ម័នជាសភាវៈតែមួយ។



# រឿងរាមកេរ្តិ៍

## សំណួរ

១. ចូរបង្ហាញពីប្រភពនិងប្រភេទរបស់អត្ថបទដកស្រង់នេះ។

២. ចូរបង្ហាញពីលក្ខណៈព្រាហ្មណ៍និយមនៅក្នុងអត្ថបទដកស្រង់នេះ។

៣. តើអត្ថបទនេះមានតួអង្គណាខ្លះ?

៤. ចូរបង្ហាញពីកាលអាកាសរបស់អត្ថបទនេះ។

៥. ចូរបង្ហាញពីវិធីតែងនិពន្ធ (ពណ៌នាវិធី សំវាទវិធី ឧបមានវិធី បដិវិធី វចនវិធី...) ដែលអ្នកនិពន្ធប្រើក្នុងអត្ថបទដកស្រង់នេះ។

៦. ចូរសង្ខេបអត្ថបទនេះជាពាក្យរាយ។

## ចម្លើយ

១. -អត្ថបទដកស្រង់នេះ មានប្រភពមកពីរឿងរាមកេរ្តិ៍ខ្សែទី២
-ជាប្រភេទអក្សរសិល្ប៍បុរាណ ស្ថិតក្នុងចលនាព្រាហ្មណ៍និយមបែបវីរកថា។

២. លក្ខណៈព្រាហ្មណ៍និយមនៅក្នុងអត្ថបទដកស្រង់នេះគឺ ៖

**+ តួអង្គមានភាពអច្ឆរិយ**

- ព្រះរាមមានលក្ខណៈអស្ចារ្យ ជាអវតារទី៧របស់ព្រះវិស្ណុ ដែលធ្វើឱ្យធម្មជាតិមានការប្រែប្រួល ដូចជាព្រះរាមធ្វើដំណើរដល់ទីណា ធម្មជាតិនៅទីនោះប្រែក្លាយពីអាប់អួរទៅជាស្រស់បំព្រង ហើយសត្វដែលធ្លាប់តែកាចសាហាវ

*ប្រែជាស្ងាត់ឈឹង។ (ស្លឹកខ្លះខ្មៅខ្ចីក្រហម ស្លេកស្លាំ ក្រៀមក្រោម.....សត្វទាំងពួងជាក់ដឹងសព្វាយ......រស់សត្វស្រី តយង់យូង សឹងជាសត្រូវដែល បំបាត់ជីវិតគ្នាមិញ សឹង ប្រែចិត្តជាសម្លាញ់.....គជបុត្រពៅមានដំរីហ៏... កូន ក្របីសក្រែបរពៅខ្លា...)។*

៣. អត្ថបទនេះមានតួអង្គ : ព្រះរាម ព្រះលក្ស្មណ៍ នាងសីតា ឥសីភារទ្វាជ។

៤. កាលអាកាសរបស់អត្ថបទនេះ

- កាល : ដំណើររឿងប្រព្រឹត្តទៅនៅពេលថ្ងៃភ្លឺខ្លាំង និងទៅពេលយប់។ ហើយគឺប្រើពាក្យប្រាប់កាលមួយចំនួន ដូចជា ក្សិណនោះ ថ្ងៃនេះ ពេលព្រឹក ពេលថ្ងៃ...។
- អាកាស : ដំណើររឿងប្រព្រឹត្តទៅនៅតាមដងព្រៃទៅភ្នំចិត្រកូដ អាស្រមឥសីភារទ្វាជ ភ្នំចិត្រកូដ ទន្លេគង្គា ស្ទឹងកាលេគី....។

៥. វិធីតែងនិពន្ធ

- ពណ៌នាវិធី : គឺរៀបរាប់ដំណើររឿង (ស្លឹកខ្លះខ្មៅខ្លះខ្ចី ក្រហម ស្លេកស្លាំក្រៀមក្រោម វិហារសួគ៌ាក្លិនព្រៃផាល...)
- សំភាសវិធី : ការសន្ទនារវាងព្រះរាម និងឥសីភារទ្វាជ : *"ព្រះមុនីអាឧបចារ្យ គ្រែកក្រិះមេត្រី សំណេះសំណាលសួរជា..."*។
- ឧបមាវិធី : គឺប្រៀបធៀបដោយប្រើសន្ធានប្រៀបធៀប លក្ខណៈដូច ៖

*ល្អគយាស់មេឃាយយាយលាយ ដុះដាលឡើងរាយ រូបហេន ប្រៀបភិរម្យ ។*

*ស្ទូវស្បៃងចាំងចែងឯអម្ពរ ផ្ទាំងព្រះចន្ទា ត្រចះក៏ពេញបូរមី ។*

- **បដិវិធី** : គឺបានធ្វើឱ្យដំណើររឿងមានលក្ខណៈផ្ទុយគ្នា ៖
  - + កូនប្រើសបៅមេខ្លា
  - + កូនខ្លាបៅមេប្រើស
- **វចនវិធី** : គឺប្រើពាក្យពេចន៍ចម្រុះ
  - + ពាក្យខ្មែរបុរាណ : រូបហេន
  - + ពាក្យរាជសព្ទ : អគ្គមហេសី ហឫទ័យ ព្រះអនុជា ព្រះបន្ទូល ព្រះបាទ...
  - +ពាក្យបាលីសំស្ក្រឹត : ឫសី សព្វ ពង្សពោធិ មាតា...

៦. សង្ខេបអត្ថបទនេះជាពាក្យរាយ ៖

ដំណើរព្រះរាមចេញចាកពួយុធ្យាសំដៅភ្នំចិត្រកូដ។ ព្រះរាម ព្រះលក្ស្មណ៍ នាងសីតាយាងកាត់ព្រៃព្រឹក្សាស្ងិតស្រពោន ជ្រុះស្លឹកស្រោបំតែកើតហេតុអស្ចារ្យបណ្ដាលឱ្យទីស្ថានប្រែទៅខ្លួនជាទីរីករាយ ។ ព្រះអង្គបានជួបនឹងឥសីពាទ្វាឡដែលទទួលរាក់ទាក់យ៉ាងកក់ក្ដៅហើយចង្អុលបង្ហាញផ្លូវទៅកាន់ភ្នំចិត្រកូដ។ នៅជើងភ្នំនោះបរិយាកាសក៏ប្រែប្រួលដែរ ដូចជាសត្វសាហាវប្រែជាស្លូត កូនខ្លារត់ទៅបៅមេប្រើស កូនប្រើសរត់ទៅបៅមេខ្លាវិញ។

# អក្សរសិល្ប៍ពុទ្ធនិយម

## ពុទ្ធសាសនា

### សំណួរ

១. តើពុទ្ធសាសនាមានកំណើតពីពេលណា? នៅឯណា?

២. តើពុទ្ធសាសនាមានការរីកចម្រើនក្នុងសម័យណា? ហើយចូលមកផែនដីសុវណ្ណភូមិតាមរយៈនរណា? មានអ្វីជាភស្តុតាង?

៣. តើនរណាជាអ្នកបង្កើតពុទ្ធសាសនា? ព្រះអង្គជាជនជាតិអ្វី?

៤. ចូរអ្នករាប់និកាយផ្សេងៗនៃពុទ្ធសាសនាឱ្យបានពីរ ។

៥. ចូរបង្ហាញថាពុទ្ធសាសនាជាសាសនាមនុស្សនិយម ។

៦. តើអ្នកយល់ដូចម្តេចចំពោះពុទ្ធសាសនា?

### ចម្លើយ

១. ពុទ្ធសាសនាមានកំណើតពីស.វ.ទី៦មុនគ.ស. នៅប្រទេសឥណ្ឌា ។

២. ពុទ្ធសាសនាមានការរីកចម្រើនក្នុងរជ្ជកាលព្រះបាទអសោក គឺពុទ្ធសាសនាត្រូវបានផ្សព្វផ្សាយពេញទូទាំងប្រទេសឥណ្ឌា និងទាំង

ក្រៅប្រទេសផង ហើយនាំចូលមកផែនដីសុវណ្ណភូមិតាមរយៈសាមណទូតពីរអង្គព្រះនាមសោណត្ថេរ និងឧត្តរត្ថេរ។ ដោយផ្អែកលើសិលាចារឹកវ៉ូកាញ់ (វៀតណាមខាងត្បូង) ពុទ្ធសាសនាទំនងជាប្រតិស្ឋាននៅស្រុកខ្មែរក្នុងស.វ.២ នៃគ.ស ក្នុងរជ្ជកាលស្តេចហ្វាន់ចេរម័ន ឬស្រីមារៈ។

៣. អ្នកបង្កើតពុទ្ធសាសនាគឺព្រះពុទ្ធសាមណគោតម (ព្រះសិទ្ធត្ថ) ព្រះអង្គជាជនជាតិឥណ្ឌា។

៤. ពុទ្ធសាសនា បែងចែកជាពីរនិកាយគឺ មហាយាន (យានធំ) និងហីនយាន (យានតូច)។ ហើយនិកាយហីនយាន ចែកជា២គណៈទៀត គឺ គណៈមហានិកាយ និងគណៈធម្មយុត្តិកនិកាយ។

៥. បង្ហាញថាពុទ្ធសាសនាជាសាសនាមនុស្សនិយម៖

ពុទ្ធសាសនាជាសាសនាផង ជាទស្សនវិជ្ជាផង។ វាមានលក្ខណៈពិសេសមួយពិសេសដែលបង្ហាញនូវលក្ខណៈ[illegible]ស្សពិតៗក្នុងសង្គម។

ពុទ្ធវចនៈរបស់ព្រះសម្មាសម្ពុទ្ធដែលបានសំដែងទុកមកសុទ្ធតែសំដៅស្វែងរកសេចក្តីសុខឱ្យមនុស្ស ពោលគឺសេចក្តីសុខដ៏ពិតប្រាកដមួយ។ ទ្រឹស្តីសំខាន់ដែលព្រះពុទ្ធបានរកឃើញនោះ គឺចតុរារិយសច្ចៈ ឬ អរិយសច្ចៈ៤ ប្រែមកថាការពិតដ៏ប្រសើរ រួមមាន៖

- ទុក្ខអរិយសច្ចៈ (ទុក្ខជាសេចក្ដីពិតដែលកើតមានដល់មនុស្ស)
- សមុទយអរិយសច្ចៈ (ហេតុនៃទុក្ខ)
- និរោធអរិយសច្ចៈ (ការរំលត់ទុក្ខ)
- មគ្គអរិយសច្ចៈ (ផ្លូវរំលត់ទុក្ខ)

៦. ចំពោះពុទ្ធសាសនា ខ្ញុំយល់ថាជាសាសនាមួយដ៏ល្អផូរផង់សម្រាប់មនុស្សគ្រប់គ្នា ជាសាសនាស្វែងរកសុខសន្តិភាពជូនមនុស្សលោក ព្រោះរាល់ទ្រឹស្ដីរបស់ព្រះពុទ្ធសុទ្ធតែទាក់ទងនឹងជីវិតរស់នៅប្រចាំថ្ងៃរបស់មនុស្សពិតៗ។ ព្រះពុទ្ធអប់រំមនុស្សឱ្យជឿលើខ្លួនឯង "អត្តាហិ អត្តនោ នាថោ" គឺមិនឱ្យជឿលើកម្លាំងក្រៅខ្លួន ឬជឿលើអាទិទេពឡើយ។

*(សិស្សអាចឆ្លើយតាមការយល់របស់ខ្លួនផ្សេងពីនេះ)*



# វិវត្តន៍អក្សរសិល្ប៍ខ្មែរ

## សំណួរ

១. តាមរយៈអត្ថបទនេះតើគេចែកអក្សរសិល្ប៍ខ្មែរជាប៉ុន្មានដំណាក់កាល? គឺអ្វីខ្លះ?

២. តើអក្សរសិល្ប៍សម័យទំនើបមានប៉ុន្មានផ្នែក? ចូររៀបរាប់។

៣. ចូររាប់ឈ្មោះរឿងប្រលោមលោកល្បីៗក្នុងសម័យអាណាព្យាបាលបារាំង ហើយកំពុងបញ្ចូលក្នុងកម្មវិធីសិក្សានាពេលបច្ចុប្បន្ននេះ។

៤. តើអ្នកយល់ដូចម្តេចចំពោះអក្សរសិល្ប៍ខ្មែរក្នុងសម័យសាធារណរដ្ឋខ្មែរ?

៥. ចូរនិយាយអំពីអក្សរសិល្ប៍ខ្មែរក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ហើយពន្យល់ចំណងជើងចម្រៀង "នៅគ្រប់ការដ្ឋានថ្ងៃណាក៏បុណ្យ"។

៦. តើអ្នកមានវិធីណាខ្លះដើម្បីទប់ស្កាត់ការហូរចូលនៃអក្សរសិល្ប៍បរទេស ដែលបង្ហាញពីចំណុចអសកម្ម (អវិជ្ជមាន) ដល់អក្សរសិល្ប៍ខ្មែរ (ផ្នែកភាពយន្តនិងវីដេអូ)?

## ចម្លើយ

១. តាមរយៈអត្ថបទនេះ គេចែកអក្សរសិល្ប៍ខ្មែរជាបីដំណាក់កាល ធំៗ គឺ ៖

- អក្សរសិល្ប៍សម័យបុរាណ
- អក្សរសិល្ប៍សម័យកណ្ដាល
- អក្សរសិល្ប៍សម័យទំនើប

២. អក្សរសិល្ប៍សម័យទំនើបមាន៥ផ្នែក គឺ ៖

- សម័យអាណានិគមបារាំង ( ១៨៦៣-១៩៥៣)
- សម័យសង្គមរាស្ត្រនិយម ( ១៩៥៣-១៩៧០)
- សម័យសាធារណរដ្ឋខ្មែរ ( ១៩៧០-១៩៧៥)
- សម័យកម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩)
- សម័យក្រោយថ្ងៃ៧មករា ១៩៧៩-បច្ចុប្បន្ន

៣. រឿងប្រលោមលោកល្បីៗក្នុងសម័យអាណាព្យាបាលបារាំង ហើយកំពុងបញ្ចូលក្នុងកម្មវិធីសិក្សានាពេលបច្ចុប្បន្ននេះឱ្យបាន៥រឿង ៖

- កុលាបប៉ៃលិន (គ.ស. ១៩៣៦ ឬ ១៩៤៣)
- សុផាត (គ.ស. ១៩៣៨)
- ផ្កាស្រពោន (គ.ស. ១៩៤៩)
- ព្រះវេស្សន្តរ
- ទុំទាវ (គ.ស. ១៩១៥)

៤. ចំពោះអក្សរសិល្ប៍ខ្មែរក្នុងសម័យសាធារណរដ្ឋខ្មែរ ខ្ញុំយល់ថា

មានការរីចម្រើនយ៉ាងខ្លាំង ទោះបីជាមានសង្គ្រាមក៏ដោយ។ គេឃើញមានស្នាដៃនិពន្ធជាច្រើនបានកើតឡើង ព្រោះការតែងនិពន្ធកាន់តែមានសេរីភាពជាងមុន។ ស្នាដៃមួយចំនួនបានមានទំនោរទៅរកចរន្តថ្មីពីរ គឺមួយទ្រទ្រង់នយោបាយថ្មីបែបសាធារណរដ្ឋ និងមួយទៀតទិតៀនរិះគន់បែបថ្មីនេះ។ ស្នាដៃមួយចំនួនបាននិយាយរិះគន់លើកឡើងពីបញ្ហាទឹកដី ប្រវត្តិសាស្ត្រ ព្រឹត្តិការណ៍សង្គមខ្មែរ ពីចលនាតស៊ូ បញ្ញវន្តទាមទារសិទ្ធិសេរីភាព។ល។ ជាហេតុធ្វើឱ្យប្រជាជនកាន់តែទទួលនូវវិបត្តិនិងបញ្ហាកាន់តែធ្ងន់ធ្ងរទៅឡើង។ ភាពទំនើបនិងការចម្លងយកនូវអារ្យធម៌បរទេសស៊ីវិ-ល័យគឺជាឧបសគ្គមួយចំពោះប្រជាជនក្នុងប្រទេស ហើយក៏ជាគ្រោះថ្នាក់មួយចំពោះវិស័យវប្បធម៌និងអារ្យធម៌របស់ជាតិដែលធ្លាប់តែមានភាពទន់ភ្លន់ សូប់ស្ងៀម និងថ្លៃថ្នូរតាំងពីយូរមកហើយ។

៥. ចំពោះអក្សរសិល្ប៍ខ្មែរក្នុងសម័យកម្ពុជាប្រជាធិបតេយ្យបាននៅពួនសម្ងំលាក់ខ្លួន ហើយថែមទាំងមានការខូចខាតផលិតកម្មដែលកើតមកហើយ។ កវីគ្មានសិទ្ធិសរសេរ ឬបញ្ចេញគំនិតសំដែងមនោសញ្ចេតនាផ្សេងៗឡើយ។ ចម្រៀងបដិវត្ត និងបទភ្លេងចម្រៀងជាតិកម្ពុជាប្រជាធិបតេយ្យបានបន្លឺឡើងចេញពីឧគ្ឃោសនសព្ទនៅគ្រប់ទីនានាគ្មានឈប់ឈរក្នុងប្រធានបទដដែលដូចជា៖បង្ហាញពីការប្រយុទ្ធនឹងចក្រពត្តិ ពួកប្រតិកិរិយា និងការប្រយុទ្ធយកភោគផលរហូតដល់បានបីតោនក្នុងមួយហិចតាដោយ

មានប្រព័ន្ធភ្លឺ និងទំនប់ទឹករីកចម្រើនជាសម័យអង្គរទៅទៀត ។

៦. ដើម្បីទប់ស្កាត់ការហូរចូលនៃអក្សរសិល្ប៍បរទេស ដែលបង្ហាញពីចំណុចអសកម្ម (អវិជ្ជមាន) ដល់អក្សរសិល្ប៍ខ្មែរ (ផ្នែកភាពយន្ត និងវីដេអូ) ត្រូវមានវិធានការដូចតទៅ ៖

- ត្រួតពិនិត្យឱ្យបានម៉ត់ចត់មុននឹងអនុញ្ញាតឱ្យធ្វើការចាក់ផ្សាយ ឬធ្វើអាជីវកម្ម ។
- កែសម្រួល ឬកាត់ចោលនូវចំណុចណាដែលមិនល្អ ដែលធ្វើឱ្យប៉ះពាល់ដល់វប្បធម៌ជាតិ ។
- ត្រូវបណ្ដុះទឹកចិត្តស្រឡាញ់វប្បធម៌ជាតិ និងលើកស្ទួយវប្បធម៌ជាតិ តាមរយៈការគាំទ្រស្នាដៃខ្មែរ ។
- យុវជនត្រូវខិតខំរៀនសូត្រយកចំណេះវិជ្ជាដើម្បីបម្រើផលប្រយោជន៍ខ្លួនឯង គ្រួសារ និងសង្គមឱ្យមានភាពរីកចម្រើន ។



# រៀនព្រះវេស្សន្តរ

## សំណួរ

១. ចូរសង្ខេបអត្ថបទខាងលើឱ្យខ្លីល្មមស្តាប់បាន ។

២. ចូរបង្ហាញសិល្បវិធីនិពន្ធ ( ឯកវាទវិធី សំវាទវិធី សន្ទេហវិធី វចនាវិធី ឧបមានវិធី...) ពីក្នុងអត្ថបទខាងលើ ។

៣. តើប្រផ្នូលអ្វីដែលធ្វើឱ្យព្រះនាងមទ្រីព្រួយបារម្ភមុនពេលទៅបេះផលា?

៤. ប្រសិនបើតាជូជកជួបនឹងព្រះនាងមទ្រី តើអាចសុំព្រះរាជបុត្រទាំងពីរ ពីព្រះវេស្សន្តរបានឬទេ? ព្រោះអ្វី?

៥. ចូររកមូលន័យក្នុងអត្ថបទដកស្រង់ខាងលើ ដោយភ្ជាប់ឧទាហរណ៍ផង ។

៦. ដូចម្តេចដែលហៅថាអជ្ឈត្តិកទាន? ពាហិរទាន? ចូររកឧទាហរណ៍ពីក្នុងអត្ថបទខាងលើមកបញ្ជាក់ ។

៧. តាមរយៈអត្ថបទនេះ តើអក្សរសិល្ប៍ពុទ្ធនិយមបានផ្តល់ការអប់រំដូចម្តេចខ្លះ?

## ចម្លើយ

១. សង្ខេបអត្ថបទខាងលើ

ជូជកទៅដល់អាស្រមនៅពេលរសៀល ។ តាជីនៅសំណាក់ដើងភ្នំមួយយប់រង់ចាំព្រឹកស្អែកនឹងចូលទៅសុំបុត្រអំពីព្រះវេស្សន្តរ ។

រាត្រីនោះនាងមទ្រីយល់សុបិននិមិត្តឃើញបុរសម្នាក់ទាបខ្មៅ ស្លៀកពាក់សំពត់អមូតត្រឹមជង្គង់ សៀតផ្កាចារនៅត្រចៀក កាន់អាវុធមុតថ្លា ចូលមកចាប់ផ្ដួលនាងឆ្លៀលយកភ្នែកទាំងពីរ កាត់យកព្រះអង្សាទាំងសងខាង ពុះទ្រូងរូងយកថ្លើមបេះដូងទៅ។ ព្រះនាងតើនឡើងភិតភ័យតក្កមា ទើបព្រះនាងយាងយាត្រាចូលទៅរកព្រះស្វាមីគោះទ្វារអាស្រមបរមកុដិទាំងរាត្រី ។ ព្រះវេស្សន្តរកាត់សប្តិថាជាការល្អទេ ។

ព្រឹកឡើងនាងមទ្រីនាំបុត្រទាំងពីរទៅផ្ញើនឹងស្វាមីរួចចេញទៅបេះផ្លែផល្លាទាំងអារម្មណ៍ពិភាល់យ៉ាងខ្លាំងអំពីសុបិននិមិត្ត ។ ជូជកចូលមកសុំចៅក្រស្នានិងបាជាលី ។ រាជកុមារទាំងពីរភិតភ័យនាំគ្នារត់ទៅពួនឯស្រះឈូក ។ ជូជកចាប់កុមារទាំងពីរទៅចងវាយវាត់នៅចំពោះព្រះភក្ត្រព្រះវេស្សន្តរ ។ ព្រះពោធិសត្វទប់ព្រះទ័យពុំទាន់ ទ្រង់ចាប់ធ្នូសរបម្រុងនឹងប្រហារព្រាហ្មណ៍ចោល តែទ្រង់ទប់បានវិញ ព្រោះទ្រង់តម្រិះឃើញពីប្រពៃណីនៃពោធិសត្វ

ពីបុរាណ ។

២. បង្ហាញសិល្បវិធីនិពន្ធ

- **ឯកវាទវិធី** : ..ជូជកចុកចង្កេះរឹងគាំង ទើបយកដៃគក់បណ្ដើរ គិតបណ្ដើរថា *"ថ្ងៃនេះនាងមទ្រីមកពីព្រៃវិញហើយ មុខជាពុំព្រមឱ្យកូនដល់អញទេ អញដេកនៅទីនេះសិនចុះ.... ។ ....ជូជកភ្ញាក់ឡើងគិតថា "ថ្ងៃនេះប្រហែលជានាងមទ្រីទៅព្រៃហើយ"... ។*

- **សំវាទវិធី** : ការសន្ទនារវាងព្រះវេស្សន្តរ និងនាងមទ្រី :

+ ព្រះវេស្សន្តរសួរថា កោងសា នរណាអុឺះ ! នរណាហ្នឹង?

+ ព្រះនាងមទ្រីទូលថា ខ្ញុំម្ចាស់ព្រះអង្គ សូមទ្រង់មេត្តាប្រោស!

- **សន្ទេហវិធី** : អ្នកអានអាចឆ្ងល់ថា ក្រោយពីជូជកយកជាលីក្រស្នាទៅ តើវាសនាកុមារទាំងពីរនឹងទៅជាយ៉ាងណា? តើនាងមទ្រីមកទាន់ឬទេ?

- **វចនវិធី** : កវីប្រើពាក្យពេចន៍ចម្រុះ

+ ពាក្យបាលី : ជូជកោ កោងសោ...

+ ពាក្យកំចីបាលី សំស្ក្រឹត : មាគ៌ា អស្តង្គត សូរ្យសែង...

+ ពាក្យសាមញ្ញ : ថ្ងៃនេះ សិន សឹម...

+ ពាក្យរាជសព្ទ : មាតា បិតា សូមទ្រង់ព្រះមេត្តាប្រោស

ខ្ញុំម្ចាស់...

- **វចនាវិធី :** កវីតាក់តែងអត្ថបទជាប្រភេទកម្រងកែវ ។
- **ឧបមានវិធី :** ជូជកទូលថា ខ្ញុំព្រះអង្គឮថា ព្រះរាជហឫទ័យរបស់ព្រះអង្គពេញព្រៀបដោយបរិច្ចាគចេតនាដូចជាទន្លេពេញព្រៀបដោយទឹក មិនចេះអស់សព្វកាយ...។

៣. ប្រផ្នូលដែលធ្វើឱ្យព្រះនាងមទ្រីព្រួយបារម្ភមុនពេលទៅបេះផលា គឺព្រះនាងទ្រង់សុបិននិមិត្តថា "បុរសម្នាក់ទាបខ្មៅ ស្លៀកសំពត់អម្ចត់ត្រឹមជង្គង់ សៀតផ្កាចារព្ញដ៏ត្រចៀក កាន់អាវុធមុតថ្លារត់ចូលមកក្នុងបរមសាលា ចាប់ព្រះនាងផ្តួលចុះ ឆ្កៀលយកព្រះនេត្រទាំងពីរ កាត់យកព្រះអង្សាទាំងសងខាង ពុះទ្រូងរូងយកថ្លើមបេះដូងទៅ" ។

៤. ប្រសិនបើតាជូជកជួបនឹងព្រះនាងមទ្រី គាត់ពុំអាចសុំព្រះរាជបុត្រទាំងពីរពីព្រះវេស្សន្តរបានទេ ព្រោះព្រះនាងមទ្រីក៏ដូចជាទឹកចិត្តម្តាយទូទៅដែរ ពុំព្រមឱ្យបុត្រជាទីស្រឡាញ់របស់ខ្លួន ឱ្យទៅធ្វើជាទាសាទាសីរបស់គេបានឡើយ ។

៥. មូលន័យក្នុងអត្ថបទដកស្រង់ខាងលើគឺ បុត្របរិច្ចាគនៃព្រះវេស្សន្តរឱ្យទៅជូជកដើម្បីសន្សំបារមីត្រាស់ជាព្រះពុទ្ធ ។

ឧទាហរណ៍បញ្ជាក់ : ព្រះវេស្សន្តរថា ហៃកូនទាំងពីរជាទីស្រឡាញ់របស់មិតា ចូរកូនមកអាយ ចូរបំពេញបារមីរបស់បិតា ចូរស្រោច

ស្រពហាប្ញទ័យរបស់បិតា ចូរកូនតាំងខ្លួនជាយាននាវាឱ្យបិតានាំសត្វជិះឆ្លងចាកជាតិ ជរា ព្យាធិ មរណៈ ទៅកាន់ត្រើយនាយ គឺព្រះនិព្វានណាំកូន ។

៦. +អជ្ឈត្តិកទានគឺជាទានក្នុងខ្លួន ដែលមានជីវិតបរិច្ចាគនិងអង្គបរិច្ចាគ ។ ឧទាហរណ៍ : សរីរាង្គកាយមាន ដៃ ជើង ភ្នែក ឬ ជីវិតជាដើម ហៅថាទានក្នុងខ្លួន ។

+ពាហិរទាន គឺជាទានក្រៅខ្លួន ដែលមានធនបរិច្ចាគ បុត្តបរិច្ចាគនិងភរិយាបរិច្ចាគ ។ ឧទារហាណ៍ ព្រះវេស្សន្តរបានដាក់ទានជាលីក្រស្នា ដល់ជូជក ។ ( ជាលី ក្រស្នាជាទានក្រៅខ្លួន)

៧. តាមរយៈអត្ថបទនេះ អក្សរសិល្ប៍ពុទ្ធនិយមបានផ្តល់ការអប់រំដូចតទៅ ៖

- ឱ្យចេះបរិច្ចាគទានដល់ទុគ៌តជន
- មានព្រហ្មវិហារធមិចំពោះកូន
- ត្រូវចេះខន្តីអត់ធ្មត់ ដើម្បីសម្រេចបំណង
- ............................................... ។

មេរៀនទី ៤

# សិល្បៈ

## ចលនាអក្សរសិល្ប៍

### សំណួរ

១. តើគេចែកចលនាអក្សរសិល្ប៍ជាប៉ុន្មានចលនា ? ចលនាអ្វីខ្លះ?

២. ដូចម្ដេចហៅថាចលនាព្រាហ្មណ៍និយម ពុទ្ធនិយម ខេមរនិយម និងបរទេសនិយម?

៣. ចូរធ្វើចំណែកថ្នាក់រឿងទាំងនេះតាមចលនាអក្សរសិល្ប៍ ដោយផ្ដល់អំណះអំណាងក្នុងរឿងនីមួយៗឱ្យបានសមស្រប។ រឿងព្រះវេស្សន្ដរ រាមកេរ្ដិ៍ ព្រះអាទិត្យថ្មីរះលើផែនដីចាស់ តេជោយ៉តថៅកែចិត្តចោរ ទុំទាវ មាយើង ចៅស្រទបចេក សព្វសិទ្ធិ ក្រពើ និងអ្នកបរទេះ ចាបស្រុកនិងចាបព្រៃ អារក្សនិងអ្នកស្រែ។

### ចម្លើយ

១. គេចែកចលនាអក្សរសិល្ប៍ជា៤ចលនា គឺ ៖

- ចលនាព្រាហ្មណ៍និយម

- ចលនាពុទ្ធនិយម
- ចលនាខេមរនិយម
- ចលនាបរទេសនិយម

២. -ដែលហៅថា **ចលនាព្រាហ្មណ៍និយម** ជាស្នាដៃអក្សរសិល្ប៍ទាំងឡាយណាដែលមានទំនាក់ទំនងទៅនឹងបែបបទលទ្ធិសាសនាព្រាហ្មណ៍ ។

ឬ ជាស្នាដៃនៃអក្សរសិល្ប៍ដែលមានប្រភព មានជំនឿ មានទ្រឹស្តី និងមានចលនាទាក់ទងទៅនឹងគម្ពីរបែបព្រហ្មញ្ញសាសនានោះឯង ។

-ដែលហៅថា **ចលនាពុទ្ធនិយម** ជាអត្ថបទរឿងរ៉ាវផ្សេងៗដែលទាក់ទងនឹងការលើកយកទ្រឹស្តីពុទ្ធសាសនាធ្វើជាគោល ហើយទ្រឹស្តីទាំងនោះស្ថិតនៅក្នុងគម្ពីរព្រះត្រៃបិដក ដែលអ្នកនិពន្ធលើកយកបញ្ហាបុណ្យបាប ផលល្អអាក្រក់របស់តួអង្គមកចោទ និងដោះស្រាយ ។

ឬ ជាស្នាដៃទាំងឡាយណាដែលបានលើកឡើងពីការតស៊ូរបស់ព្រះពោធិសត្វក្នុងការបំពេញបារមី ដើម្បីបានត្រាស់ជាព្រះពុទ្ធ ។

-ដែលហៅថា **ចលនាខេមរនិយម** ជាស្នាដៃអក្សរសិល្ប៍ដែលបង្ហាញពីបញ្ហាជីវភាពជាក់ស្តែងរបស់មនុស្សក្នុងសង្គម ស្របទៅតាមវប្បធម៌ និងសង្គមធម៌របស់ខ្មែរយើង ។

-ដែលហៅថា **ចលនាបរទេសនិយម** គឺជាអក្សរសិល្ប៍ដែលអ្នកនិពន្ធលើកយករឿងបរទេសផ្សេងៗមកបកប្រែជាភាសាជាតិ ឬ

ក៏និពន្ធដោយចម្លងតាម ដោយរក្សាទុកទំនៀមទម្លាប់ ប្រពៃណី លក្ខណៈរបស់បរទេសសុទ្ធសាធ។

៣. ចំណែកថ្នាក់រឿងតាមចលនាអក្សរសិល្ប៍នីមួយៗ

| ចលនា | ចំណងជើងរឿង | មូលហេតុ |
|---|---|---|
| ព្រាហ្មណ៍និយម | រាមកេរ្តិ៍ | -តួអង្គ : ព្រះរាមជាអវតារ របស់ព្រះវិស្ណុ នាងសីតាជាកំពូលនារីស្អាតជាងគេលើឋានទាំងបី ព្រមទាំងមានយក្សឥសី ស្វា គ្រុឌ ... -តួអង្គព្រះរាមមានភាពអច្ឆរិយ ធ្វើឱ្យធម្មជាតិ និងសត្វម្រឹគប្រែប្រួលខុសពីធម្មតា។ -ដំណើររឿងច្បាំងគ្នារវាងក្រុមព្រះរាមនិងក្រុមយក្ស ប្រកបដោយសិល្បិ៍អភិនិហារយ៉ាងអស្ចារ្យ ហោះហើរប្រើមន្តអាគម... |
| ពុទ្ធនិយម | ព្រះវេស្សន្តរ | -នៅសេចក្តីផ្តើមអ្នកនិពន្ធបានធ្វើបទនមស្សការរំឭកគុណព្រះរតនត្រ័យ។ -តួអង្គ : ព្រះវេស្សន្តរជាពោធិសត្វនាងមទ្រីជាកន្សែសារពេជ្ញ។ |

| | | |
|---|---|---|
| | | -ដំណើររឿងបង្ហាញពីការបំពេញទានបារមីដើម្បីត្រាស់ជាព្រះពុទ្ធ ។<br>-ចុងបញ្ចប់រឿង អ្នកនិពន្ធបានប្រាប់ពីការសជាតិរបស់តួអង្គ គឺព្រះវេស្សន្តរទៅជាព្រះពុទ្ធ នាងមទ្រីទៅជានាងពិម្ពា... ។ |
| | ចៅស្រទបចេក | -រឿងនេះមានលក្ខណៈជាធម្ម-ទេសនា ...<br>-ដំណើររឿងនិយាយពីកម្មផលរបស់ចៅស្រទបចេកដែលបានស្រាតស្បង់ចីពរពីសាមណេរមួយអង្គកាលពីអតីតជាតិ ហើយត្រូវទទួលកម្មព្យេរគ្មានអ្វីស្លៀកពាក់នឹងគេ ។ និងបង្ហាញពីភាពកតញ្ញូរបស់ចៅស្រទបចេកចំពោះម្ដាយ ។ |
| | សព្វសិទ្ធិ | -នៅសេចក្ដីផ្ដើមអ្នកនិពន្ធបានធ្វើបទនមស្សការរំឭកគុណព្រះរតនត្រ័យ។<br>-អ្នកនិពន្ធបានបង្ហាញពីការសរជាតិរបស់តួអង្គ។ (សកុណាញី ទៅជាសុវណ្ណកេសរ ទៅជា នាងពិម្ពា, ឯសកុណាឈ្មោល ទៅជាសព្វសិទ្ធិ ទៅ |

| | | |
|---|---|---|
| | | ជា ព្រះពុទ្ធ...) |
| ខេមរនិយម | ព្រះអាទិត្យថ្មីរះលើផែនដីចាស់ | ដំណើររឿងឆ្លុះបញ្ចាំងតថភាពសង្គមខ្មែរ នៅសម័យសង្គមរាស្ត្រនិយម ពិសេសគឺការតស៊ូរបស់កសិករខ្មែរដើម្បីជីវភាពរស់នៅ។ |
| | តេជោយ៉ត | ដំណើររឿងឆ្លុះបញ្ចាំងពីសង្គមខ្មែរនាសម័យឧដុង្គ ក្នុងរជ្ជកាលស្តេចជ័យ-ចេស្តា។ |
| | ចៅកែចិត្តចោរ | ដំណើររឿងប្រឌិតឡើងនៅទីក្រុងភ្នំពេញ ហើយឆ្លុះបញ្ចាំងពីជីវភាពរស់នៅកម្មករខ្មែរដែលត្រូវពួកនាយទុនជិះជាន់ កេងប្រវ័ញ្ច ។ |
| | ទុំទាវ | ដំណើររឿងឆ្លុះបញ្ចាំងពីសង្គមខ្មែរនាសម័យលង្វែកក្នុងរជ្ជកាលស្តេចរាមាពិសេសបង្ហាញពីទឹកចិត្តស្នេហារបស់យុវជនយុវនារីនៅស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាមដែលបានតស៊ូយ៉ាងប្តូរផ្តាច់រហូតបាត់បង់ជីវិត ។ |
| | មាយើង | ដំណើររឿងឆ្លុះបញ្ចាំងពីលក្ខណៈរបស់ស្ត្រីខ្មែរ (ខាតលក្ខណ៍ និងគ្រប់លក្ខណ៍) ។ |

| | | |
|---|---|---|
| | ក្រពើនិងអ្នកបររទេះ | ដំណើររឿងបង្ហាញពីជីវភាពរស់នៅជាក់ស្ដែងរបស់មនុស្សដោយគ្រាន់តែយកតួអង្គសត្វមកធ្វើជាតំណាងដើម្បីបង្ហាញពីសារជាតិមនុស្សរមិលគុណ.. |
| | ចាបស្រុក និងចាបព្រៃ | ដំណើររឿងបង្ហាញពីជីវភាពរស់នៅជាក់ស្ដែងរបស់មនុស្សដោយគ្រាន់តែយកតួអង្គសត្វមកធ្វើជាតំណាងដើម្បីបង្ហាញពីឥរិយាបថមនុស្សចូលចិត្តបង្កជម្លោះ ខ្វះការយោគយល់ ឬអធ្យាស្រ័យគ្នា...។ |
| | អារក្ស និងអ្នកស្រែ។ | ដំណើររឿងបង្ហាញពីជីវភាពរស់នៅជាក់ស្ដែងរបស់មនុស្សដោយបង្ហាញពីភាពឆ្លាតវាងវៃ ការយល់ដឹងច្បាស់លាស់ពីរដូវធ្វើស្រែចម្ការរបស់អ្នកស្រែ។ |



# រឿង ព្រះអាទិត្យថ្មីរះលើផែនដីចាស់

## សំណួរ

១. តើរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ស្ថិតនៅក្នុងចលនាអក្សរសិល្ប៍អ្វី? ចូរផ្តល់អំណះអំណាង?

២. តើសមមានលក្ខណៈពិសេសអ្វីខ្លះ ដែលនាំឱ្យជីវិតសមបានទទួលលទ្ធផលវិជ្ជមានបែបនេះ? ចូរបង្ហាញពីលក្ខណៈវិជ្ជមានទាំងនោះ ។

៣. ចូរអ្នកបកស្រាយឃ្លា "ព្រះអាទិត្យថ្មីបានរះនៅលើផែនដីចាស់ ហើយរះនៅលើផែនដីនៃអាណានិគមនិយមបារាំង" រកអំណះអំណាងក្នុងអត្ថបទខាងលើមកបញ្ជាក់ ។

## ចម្លើយ

១. រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ស្ថិតនៅក្នុងចលនាអក្សរសិល្ប៍ខេមរនិយម ព្រោះដំណើររឿងបានឆ្លុះបញ្ចាំងពីតថភាពពិតនៅក្នុងសង្គមខ្មែរ នាសម័យសង្គមរាស្ត្រនិយម ដែលទាក់ទងនឹងជីវភាពរស់នៅរបស់ប្រជាជន មានតួអង្គសមជាឧទាហរណ៍ស្រាប់ ។

២. លក្ខណៈពិសេសដែលនាំឱ្យជីវិតសមបានទទួលលទ្ធផលវិជ្ជមានបែបនេះ ៖

- **មានអត្តចរិតស្លូតបូតសុភាពរាបសា ស្មោះត្រង់ គួរឱ្យស្រឡាញ់ មិនយកប្រាក់ជាធំ ។**
- **ចេះស្គាល់តម្លៃការងារ :** សមមិនព្រមយកលុយ៥០០រៀលជាសំណងទេ សមអង្វរឱ្យលោករដ្ឋមន្ត្រីជួយរកការងារឱ្យធ្វើវិញ ។
- **ចេះតស៊ូ អំណត់ព្យាយាម :** សមខិតខំធ្វើការងារដោយគ្មានខ្ជិលច្រអូស ធ្វើឱ្យលោករដ្ឋមន្ត្រីពេញចិត្តពេញថ្លើម ។
- **ចេះយល់កាលៈទេសៈ :** ក្រោយពីស្រុកឯករាជ្យបរិបូរហើយសមបានវិលត្រឡប់ទៅធ្វើស្រែចំការវិញប្រកបដោយជីវភាពធូរធារ ។

៣. បកស្រាយឃ្លា "**ព្រះអាទិត្យថ្មីបានរះនៅលើផែនដីចាស់ ហើយរះនៅលើផែនដីនៃអាណានិគមនិយមបារាំង**"

- ព្រះអាទិត្យថ្មី សំដៅលើសម្តេចនរោត្តមសីហនុ (ឬរបបសង្គមរាស្ត្រនិយម) ។
- រះលើផែនដីចាស់ ហើយរះលើផែនដីនៃអាណានិគមនិយមបារាំង មានន័យថារបបសង្គមរាស្ត្រនិយមបានផ្តួលរំលំរបបអាណានិគមបារាំង ក្រោមការដឹកនាំរបស់អង្គសម្តេចឪ ។

ដូចនេះឃ្លាខាងលើមានន័យថារបបថ្មី ដែលមានឈ្មោះថារបបសង្គមរាស្ត្រនិយម ក្រោមការដឹកនាំដោយអង្គសម្តេចឪបានផ្តួលរំលំពួកអាណានិគមបារាំងចេញពីទឹកដីប្រទេសកម្ពុជា ហើយនាំមកនូវសន្តិភាព និងការអភិវឌ្ឍជូនជាតិមាតុភូមិ ។



# សិល្បៈខ្មែរ

## សំណួរ

១. តើភ្លេងខ្មែរមានប៉ុន្មានប្រភេទ? អ្វីខ្លះ? ចូររៀបរាប់។

២. ដូចម្ដេចដែលហៅថារបាំប្រជាប្រិយ? តើខ្មែរមានរបាំប្រជាប្រិយអ្វីខ្លះ? ចូររៀបរាប់អំពីរបាំទាំងនោះ។

៣. តើ "របាំតន្ដី" មានន័យយ៉ាងដូចម្ដេច? តើរបាំតន្ដីមានប្រភពមកពីណា? មានអ្វីជាភស្ដុតាងបញ្ជាក់ពីប្រវត្តិ និងអត្ថន័យនៃរបាំនេះ?

៤. ចូរអ្នកបង្ហាញពីលក្ខណៈដូចគ្នានិងលក្ខណៈខុសគ្នានៃរបាំគោះអង្រែ របាំយីកេ របាំឆៃយ៉ាំ និងរបាំរាំវង់។ តើរបាំខាងលើនេះបានបង្កប់នូវអត្តសញ្ញាណជាតិយ៉ាងណាខ្លះ?

## ចម្លើយ

១. ភ្លេងខ្មែរមានច្រើនប្រភេទដូចជា ៖

- **ភ្លេងពិណពាទ្យ** : កំដរក្នុងរបាំងបុរាណក្នុងពិធីបួងសួង (បន់ស្រន់លាបំណន់) ក្នុងពិធីសាសនា (បុណ្យកឋិន បំបួសនាគ ពុទ្ធាភិសេក...) ជួនកាលក្នុងពិធីបុណ្យសព។
- **ភ្លេងអារក្ខ** : ប្រគំក្នុងពិធីបញ្ចូលខ្មោច បិសាច អារក្ខ អ្នកតា។
- **ភ្លេងខ្មែរ** : ជាភ្លេងមង្គល។ គេលេងក្នុងពិធីមង្គលការ ពិធីបញ្ចេញម្លប់កូនស្រី។

- **ភ្លេងឆៃយ៉ាំ** : ជាភ្លេងរីករាយជាងគេ គេលេងកំដរក្នុងពិធីបុណ្យកឋិន បុណ្យផ្កា បុណ្យបំបួសនាគ ជាដើម ។
- **ភ្លេងមហោរី** : សម្រាប់កំដរល្ខោនមហោរី ។
- **ភ្លេងកងឆ្នាក់ ឬ ខ្លងខែក** : ជាភ្លេងស្រងេះស្រងោចលន្លង់លន្លោច ។ គេលេងក្នុងពិធីតម្កល់សព ហែសពបូជា ។
- **ភ្លេងគងស្គរ** : ជាភ្លេងស្រងេះស្រងោច សម្រាប់កំដរពេលមនុស្សស្លាប់ និងនៅពេលធ្វើបុណ្យលើកខ្មោច ។
- **ភ្លេងស្គរយោល** : ពីដើមជាវង់ភ្លេងកងទ័ព តែឥឡូវគេយកមកប្រើកំដរពិធីបុណ្យខ្មោច និងកំដរល្បែងប្រដាល់សេរី ។
- **ភ្លេងប៉ីកែវ** : ជាភ្លេងមួយបែបស្ថិតនៅក្នុងវង់ភ្លេងព្រះរាជទ្រព្យ ។

២. ដែលហៅថារបាំប្រជាប្រិយ គឺជារបាំដែលប្រជារាស្ត្រនិយមស្រឡាញ់រាប់អាន ។

ខ្មែរមានរបាំប្រជាប្រិយជាច្រើន ដូចជា ៖

- របាំត្រុដិ
- របាំស្នែងទន្សោង
- របាំគោះអង្រែ
- របាំយីកេ
- របាំឆៃយ៉ាំ
- របាំរាំវង់...

៣. "របាំតន្ត្រី" ឬហៅថារបាំព្រះរាជទ្រព្យ ជារបាំក្បាច់បុរាណខ្មែរ ដែលគេលេងសម្រាប់ថ្វាយស្តេច ហើយគេនិយមលេងតែក្នុងវាំងស្តេច ដូចជាលេងនៅពេលបួងសួង លេងថ្វាយអាទិទេព និងថ្វាយវិញ្ញាណក្ខន្ធស្តេចដែលបានចូលទីវង្គតទៅហើយ ។

និងជាទម្រង់សិល្បៈសក្ការៈ (សិល្បៈទេវៈ) មួយដែលមានវ័យចំណាស់ដ៏យូរលង់ណាស់មកហើយនៅក្នុងចំណោមទម្រង់សិល្បៈសក្ការៈ ហើយក៏ជាទម្រង់សិល្បៈដែលមានតម្លៃពិតខាងស្មារតី និងខាងបច្ចេកទេសកម្រិតខ្ពស់ក្នុងចំណោមទម្រង់សិល្បៈទស្សនីយភាពនៅកម្ពុជា ។

- របាំតន្ត្រីនេះមានប្រភពកំណើតតាំងពីយូរលង់ណាស់មកហើយ ។
- ភស្តុតាងបញ្ជាក់ពីប្រវត្តិ និងអត្ថន័យនៃរបាំនេះ គឺចម្លាក់អប្សរា ចម្លាក់របាំដកស្រង់ពីរឿងរាមកេរ្តិ៍ រឿងមហាភារតៈ និងរឿងព្រេងខ្មែរនៅតាមជញ្ជាំងប្រាសាទនានានៅក្នុងប្រទេសកម្ពុជា ។

៤. លក្ខណៈដូចគ្នានិងលក្ខណៈខុសគ្នានៃរបាំគោះអង្រែ របាំយីកេ របាំឆៃយ៉ាំ និងរបាំរាំវង់ ៖

+ **លក្ខណៈដូចគ្នា** : របាំទាំងនេះបង្ហាញពី ៖
  - ការច្នៃប្រឌិតដ៏ប៉ិនប្រសប់របស់ប្រជាជនខ្មែរ
  - វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ខ្មែរ
  - សិល្បៈបម្រើអារម្មណ៍ប្រជាជន

+ **លក្ខណៈខុសគ្នា** : របាំគោះអង្រែ របាំយីកេ របាំឆៃយ៉ាំ ជារបាំប្រពៃណី ឯរបាំរាំវង់ ជារបាំប្រជាប្រិយ ហើយមានលក្ខណៈដូច

តទៅ ៖

| | |
|---|---|
| របាំគោះអង្រែ | -គេលេងក្នុងពិធីបុណ្យទាន ឬពិធីអ្វីមួយ ដែលជា លក្ខណៈបុណ្យប្រពៃណីរបស់ខ្លួន ។ គេលេងនៅ ពេលសម្រាកពីការងាររបស់ពួកគេដើម្បីបន្ថយនូវបរិយាកាសនឿយហត់ ។ របាំនេះគេនិយម សំដែងបំផុតក្នុងពិធីបុណ្យចូលឆ្នាំ និងរដូវច្រូតកាត់ ដូចជា បុណ្យដារលាន ជាដើម ។<br>-បង្ហាញពីសាមគ្គីភាព និងមុខរបររបស់ប្រជាជនខ្មែរ ។<br>-តាមប្រភពមិនច្បាស់លាស់ថា របាំនេះមានកំណើតមកពីសាសន៍គួយ ខ្លះទៀតថាចម្លងមកពីប្រទេសហ្វីលីពីន ។ |
| របាំយីកេ | -គេលេងនៅពេលមានបុណ្យទានផ្សេងៗ ឬ លំហែពីកិច្ចការស្រែចំការ ហើយមានរបៀបចំឆាកត្រឹមត្រូវ ។<br>-បង្ហាញពីភាពកំសត់ ។<br>-មានប្រភពមកពីជ្វាឬម៉ាឡាយូ ។ |
| របាំឆៃយ៉ាំ | -ជារបាំអឺកធឹកជាងគេ ។ គេលេងនៅក្នុងពិធីបុណ្យទានផ្សេងៗដូចជាបុណ្យផ្កា បុណ្យកឋិនបុណ្យ បំបួសនាគ ជាដើម ។<br>-បង្ហាញពីភាពអធិកអធម ។<br>-តាមការសន្និដ្ឋានថា របាំនេះមានសំណល់ពី |

| | |
|---|---|
| | អរិយធម៌មនុស្សជាន់ដើមលើទឹកដីខ្មែរនេះឯង ។ |
| របាំរាំវង់ | -គេលេងបានគ្រប់រដូវកាល គ្រប់ពិធីទាំងអស់ ទៅតាមចំណង់ចំណូលចិត្តរបស់ប្រជាជន ។<br>- បង្ហាញពីភាពរីករាយរាក់ទាក់ ។ |

របាំខាងលើនេះបានបង្កប់នូវអត្តសញ្ញាណជាតិខ្មែរដូចតទៅ ៖

-បង្ហាញពីភាពទន់ភ្លន់ តែម៉ឺងម៉ាត់ រហ័សរហួន សុភាពរាបសាររបស់ប្រជាជនខ្មែរ ។

-ខ្មែរជាជនជាតិមួយពូកែច្នៃប្រឌិត ។

-បង្ហាញពីការសាមគ្គីគ្នារបស់ប្រជាជនខ្មែរ

-បង្ហាញពីភាពសម្បូរបែបនៃសិល្បៈវប្បធម៌ខ្មែរ ដែលដូនតាខ្មែរបានបន្សល់ទុកមកតាំងពីយូរយារណាស់មកហើយៗ ក៏បង្ហាញពីភាពរុងរឿងនៃអរិយធម៌ខ្មែរដែលមានវ័យចំណាស់មួយនៅអាស៊ីអាគ្នេយ៍ ។

មេរៀនទី ៥

# ល្ខោន

## វិធីបង្ហាញតួអង្គក្នុងរឿងល្ខោន

*១– វិធីបង្ហាញតួអង្គ គឺជាការប្រាប់ឈ្មោះ អាយុ ឋានៈ ប្រភពកំណើតរបស់តួអង្គនីមួយៗនៅក្នុងរឿង ដើម្បីឱ្យអ្នកអាន ឬអ្នកទស្សនាបានស្គាល់ ។*

វិធីបង្ហាញតួអង្គក្នុងរឿងល្ខោនមានបង្ហាញតួអង្គដោយ ៖

- អ្នកនិពន្ធ
- តួអង្គខ្លួនឯង
- តួអង្គផ្សេងទៀត
- ដំណើររឿង



# រឿងតេជោយ៉ត

## សំណួរ

១. ចូរអ្នកធ្វើការសង្ខេបរឿងឆាកទី១៨។

២. ចូរអ្នកធ្វើការវិភាគតួអង្គតេជោយ៉ត ជំទាវស្រែន នាងម៉ែ និង ឧកញ៉ាព្រហ្មស្រី។

៣. តើអត្ថបទនេះជាអត្ថបទអ្វី? អត្ថបទប្រភេទនេះ មានរចនាបថ យ៉ាងដូចម្ដេច?

៤. ចូរអ្នកបង្ហាញពីតួនាទីរបស់តួអង្គនាយតយ និងទិន ក្នុងវគ្គដក ស្រង់នេះ។ តើតួអង្គទាំងពីរខាងលើចាំបាច់ឬទេក្នុងការសំដែង? ហេតុអ្វី?

៥. ដោយផ្អែកតាមឆាកទី១៥ ដល់ទី១៨ ចូរអ្នកធ្វើការសិក្សាអំពី ៖

- អត្ថន័យ : ប្រធានរឿង មូលបញ្ហារឿង គំនិតដឹកនាំ (ឧត្ដមគតិអ្នកនិពន្ធ)។
- អត្ថរូប : វចនវិធី សន្ទេហវិធី វឌ្ឍនវិធី វឌ្ឍមានវិធី និង បដិវិធី។
- អត្ថរស : តថរស សច្ចរស កុសលរស សង្គមរស។

៦. តើរវាងជំទាវស្រែន និងនាងម៉ែ មានលក្ខណៈដូចគ្នា និងលក្ខណៈ ខុសគ្នាយ៉ាងណាខ្លះ? ឧត្ដមភាពរបស់នារីទាំងពីរនេះស្ថិតនៅត្រង់ ណា? ចូរបង្ហាញ។

៧. តើស្ថានភាពជាកត្តាកំណត់លើវីរជន ឬវីរជនជាកត្តាកំណត់លើស្ថានភាព? តើតេជោយ៉តក្នុងវគ្គដកស្រង់នេះ អាចចាត់ទុកជាវីរជនបានដែរឬទេ? ព្រោះអ្វី?

៨. តើសេចក្ដីស្នេហារវាងជំទាវស្រែននិងតេជោយ៉ត បានផ្ដល់ជាផលវិបាកយ៉ាងណាខ្លះ? ហេតុអ្វី?

## ចម្លើយ

១. សង្ខេបរឿងឆាកទី១៨

ជំទាវស្រែនបានទៅចូលរួមបុណ្យខួបតេជោមាស ដែលតេជោយ៉តរៀបចំឡើងយ៉ាងអធិកអធម។ ជំទាវស្រែនចូលទៅថ្វាយបង្គំព្រះពុទ្ធរូប និងរូបសំណាក់តេជោមាសជាស្វាមី។ រំពេចនោះតេជោយ៉តក៏ចូលមកលេបខាយ ដោយប្រាប់ពីវត្ថុធាតុដើមដែលយកមកកសាងរូបសំណាក់តេជោមាស។ ជំទាវស្រែនក៏យល់ប្រស្នានេះ ហើយកោតសរសើរពីវីរភាពរបស់តេជោយ៉ត និងព្រមរៀបការជាមួយតេជោយ៉តក្នុងពេលនោះទៅ។

២. វិភាគតួអង្គតេជោយ៉ត ជំទាវស្រែន នាងម៉ៃ និង ឧកញ៉ាព្រហ្មស្រី

**ក. តេជោយ៉ត**

+ **គុណសម្បត្តិ**

- មេទ័ពខ្លាំងពូកែចេះវិជ្ជាគុន និងក្បួនធ្វើសឹក
- វីរជនស្នេហាជាតិ ហ៊ានពលីជីវិតដើម្បីជាតិមាតុភូមិ
- តស៊ូអំណត់ជំនះនូវការមើលងាយ មើលថោកពីអ្នកដទៃព្រោះតែខ្លួនជាកូនពូងចុងស្រុក

- មនុស្សឆ្លាតវៃ រហ័សរហួន ឆាប់យល់ហេតុការណ៍ និង ល្បិចកលរបស់សត្រូវ

-មានល្បិចខ្ពស់ក្នុងការកម្ចាត់សត្រូវក្រោយខ្នង

-ជាបុរសស្មោះស្នេហ៍ គោរពស្រលាញ់ជំទាវស្រែន ដោយ មិនប្រកាន់ថាជាស្ត្រីមេម៉ាយ

-មិនមែនជាបុរសឱកាសនិយម មិនស្រលាញ់គឺប្រាប់តាមត្រង់ដល់នាងម៉ៃ

- បុគ្គលដែលមានសន្តានចិត្តល្អ ទុកឱកាសឲ្យមនុស្សទាល់ច្រក តួយ៉ាងទុកជីវិតឲ្យនាយទិន

-ជាសិស្សកតញ្ញូ គោរពដឹងគុណជានិច្ចចំពោះតេជោមាស

- ស្រលាញ់យុត្តិធម៌ ស្អប់អំពើពុករលួយ

-ជាមនុស្សដែលយកឈ្នះចិត្តជំទាវស្រែនឲ្យបានដោយសន្តិវិធី ប្រើល្បិចវិធីខ្ពស់។

+ គុណវិបត្តិ

- យកជំទាវស្រែន ដែលជាភរិយារបស់គ្រូធ្វើជាប្រពន្ធ

-មានគំនិតជាចោរហ៊ានលួចកាំជណ្ដើរផ្ទះរបស់ជំទាវស្រែន ដើម្បីសម្រេចសេចក្ដីស្នេហ៍របស់ខ្លួន។

-សម្លាប់ពលទាហានឥតជំនុំ សម្លាប់ស្រីស្នំរបស់ព្រះរាជា និងគ្មានក្ដីមេត្តាចំពោះស្នេហា( នាងម៉ៃ) ។

៥. ជំទាវស្រែន

+ គុណសម្បត្តិ

- ជានារីដែលមានរូបសម្បត្តិស្រស់ស្អាត សម្ផិពិរោះ
- មានភក្តីភាពចំពោះស្វាមី
- មានសមត្ថភាពប្រាជ្ញាខ្ពស់មិនចាញ់បុរសឡើយ
- ជាភរិយាដែលប្រតិបត្តិកិច្ចការផ្ទះបានល្អ
- គោរពប្រតិបត្តិសាសនាបានល្អ
- ជានារីមានសណ្តានចិត្តល្អចំពោះមនុស្សទូទៅ។
+ គុណវិបត្តិ
- ជាស្ត្រីរើសអើងវណ្ណៈ
-ទទួលយកសិស្សរបស់ប្តីឯងធ្វើជាស្វាមី

គ. នាងម៉ៃ

+ គុណសម្បត្តិ
- ជានារីស្អាត មានទ្រព្យសម្បត្តិ និងជាបុត្រីឧកញ៉ាព្រះស្រីទ្វារប្រាសាទ១០
- ស្ត្រីមិនរើសអើងវណ្ណៈ
- មានស្នេហាស្មោះត្រង់
- ក្លាហានហ៊ានសារភាពពីដួងចិត្តពិតប្រាប់គេដោយផ្ទាល់
- មិនមានគំនុំគុំគួនទោះបីជាដឹងថាយ៉ាតមិនស្រលាញ់។
+ គុណវិបត្តិ
- មិនគិតខ្លួនជាស្រី ហ៊ានពោលពាក្យស្នេហាប្រាប់បុរសមុន
- លួចស្រឡាញ់គេតែម្នាក់ឯង

- ចង់បួសព្រោះរឿងស្នេហា

ឃ. ឧកញ៉ាព្រហ្មស្រី

\+ គុណសម្បត្តិ

- ជាសហការីដ៏ស្មោះត្រង់របស់តេជោមាស និងតេជោយ៉ត
- ជួយធ្វើការងារចៅហ្វាយនាយដោយអស់ពីចិត្តពីថ្លើម

\+ គុណវិបត្តិ

- ខ្វះភាពឈ្លាសវៃ

៣. អត្ថបទនេះជាអត្ថបទល្ខោនបាសាក់។ អត្ថបទប្រភេទនេះមានរចនាបថ ដូចតទៅ ៖

- អត្ថបទចែកជាឈុតនិងឆាក។
- នៅខាងដើមអត្ថបទរឿង មានបញ្ជីរាយនាមតួអង្គ និងមុខងារ។
- អ្នកនិពន្ធបញ្ជាក់សកម្មភាព រូបរាង ទឹកមុខ កាយវិការ ឬសំឡេងរបស់តួអង្គក្នុងវង់ក្រចក។
- តួអង្គ : បង្ហាញឈ្មោះ ឬជីវប្រវត្តិខ្លួនដោយខ្លួនឯង។
- ការសំដែង : ប្រព្រឹត្តទៅមានតួក តួរង តួឯកប្រុសស្រី ជាមនុស្ស យក្ស ទេវៈ សត្វជាដើម។ តួអង្គទាំងនោះត្រូវច្រៀងបទផ្សេងៗស្របតាមស្ថានភាពបរិយាកាសនៃរឿងដោយមានភ្លេងប្រគុំកំដរជាមួយផង។ ការរំកិលសាច់រឿងពីឆាកមួយទៅឆាកមួយប្រព្រឹត្តទៅដោយសន្ទឹកស្គរ និងឡោ។

-សាច់ភ្លេង : ល្ខោនបាសាក់ សាច់ភ្លេងដែលនៅរក្សាពណ៌

សម្បុរចិនមានចំនួន២២បទ ខ្មែរបង្កើតបាន២៨បទ ដោយយកបទមហោរីបន្ថែមតាមទម្រង់បាសាក់៨៩បទ បទភ្លេងបារាំងមានចំនួន១៦បទ។

-ពាក្យពេចន៍ : តួអង្គអាចប្រើពាក្យជូន ពាក្យកាព្យកម្រងកែវ ឬពាក្យរាយ។ ក្រៅពីនេះគេបានប្រើរាជសព្ទ និងសង្ឃសព្ទដែរ ។

៤. តួអង្គនាយតយ និងទិន ក្នុងវគ្គដកស្រង់នេះមានតួនាទីជាពល-សេនាបម្រើក្នុងកងទ័ព...។ តួអង្គទាំងពីរនេះពុំចាំបាច់ទេក្នុងការសម្ដែងនេះ ព្រោះគ្រាន់តែជាតួអង្គកំប្លែងប៉ុណ្ណោះ។

៥. ដោយផ្អែកតាមឆាកទី១៥ ដល់ទី១៨ សិក្សាអំពី ៖

+ **អត្ថន័យ**

- **ប្រធានរឿង** : ការរើសអើងជាតិសាសន៍ និងការប្រកាន់វណ្ណៈ។
- **មូលបញ្ហារឿង** : បញ្ហាការព្យាយាមលុបបំបាត់គំនិតរើសអើងជាតិសាសន៍ និងការប្រកាន់វណ្ណៈ។
- **គំនិតដឹកនាំ** : អ្នកនិពន្ធចង់អប់រំមនុស្សកុំឱ្យមានការរើសអើង និងមានការប្រកាន់វណ្ណៈនៅក្នុងសង្គម។

+ **អត្ថរូប**

- វចនវិធី : អ្នកនិពន្ធសរសេរជាពាក្យរាយ ប្រើពាក្យរាជ-សព្ទ ពាក្យសម្ដីរបស់ជនសាមញ្ញ ពាក្យអ្នកស្រុកជាន់កណ្ដាលជាន់ទាប មានលាយឡំជាមួយភាសាបាលីសំស្រ្កឹតតិចតួច។
  - ពាក្យសាមញ្ញ : ខ្ញុំ ចាស ពុក ស្ដីដណ្ដឹង...

- ពាក្យកម្ចីបាលីសំស្រ្កឹត ៖ សុភមង្គល ភរិយា សប្បុរសធមិ បុណ្យ...។
- ពាក្យរដ្ឋបាល ៖ ជំទាវ ឧកញ៉ា តេជោ...។
- ពាក្យកម្ចីបរទេស ៖ ប៉ាក់ឌិន

- **សន្ទេហវិធី** ៖ អ្នកអានអាចឆ្ងល់ថា តើជំទាវស្រែនព្រមទទួលយកតេជោយ៉តធ្វើជាប្តីឬទេ។ តើតេជោយ៉តមានវិធីយ៉ាងណាដើម្បីឱ្យជំទាវស្រែនព្រមស្រឡាញ់។
- **វឌ្ឍមានវិធី** ៖ (ដំណើររឿងកាន់តែតឹងតែងឡើងៗ) តេរជាយ៉តពឹងឧកញ៉ាព្រហ្មស្រីឱ្យចូលស្តីដណ្តឹងជំទាវស្រែនមួយលើកជាពីរលើក តែជំទាវស្រែនបដិសេធរហូត។
- **បដិវិធី** ៖ ដំណើររឿងមានភាពផ្ទុយគ្នាត្រង់ នាងម៉ែស្រឡាញ់តេជោយ៉ត តែតេជោយ៉តស្រឡាញ់ជំទាវស្រែន ។

**+ អត្ថរស**

- **តថរស** ៖ តម្លៃដែលអ្នកនិពន្ធឆ្លុះបញ្ចាំងពីតថភាពពិតក្នុងសង្គមដូចជា៖

  + ប្រព្រឹត្តទៅនៅលើទឹកដីកម្ពុជានាសម័យឧដុង្គ ក្នុងរជ្ជកាលស្តេចជ័យចេស្តា(គ.ស.១៥៧៥-១៥៩៣)

  + មានការរើសអើងប្រកាន់វណ្ណៈ (តេជោយ៉ត ជាជនជាតិភាគតិច...)។

  + គោរពព្រះពុទ្ធសាសនា និងប្រណើបុណ្យទានផ្សេងៗ។
- **សច្ចរស** ៖ នៅក្នុងសង្គមមានការរើសអើងជាតិសាសន៍ប្រកាន់វណ្ណៈ ដូចជំទាវស្រែនដែលពុំព្រមទទួលយកតេជោ

យ៉តពីដំបូងក៏ព្រោះតែតេជោយ៉តជាជនជាតិភាគតិចហើយធ្លាប់ជាអ្នកបម្រើខ្លួន និងជាកូនសិស្សស្វាមីរបស់ខ្លួន...។

- **កុសលរស** : តម្លៃដែលអ្នកនិពន្ធបង្កប់នូវការអប់រំមិនឱ្យមនុស្សរើសអើសវណ្ណៈជាតិសាសន៍ ពណ៌សំបុរ អប់រំឱ្យមានស្មារតីស្នេហាជាតិ...។
- **សង្គមរស** : (ជាតម្លៃដែលលេចចេញពីដំណើររឿង ដែលបានលាតត្រដាងពីសង្គមមនុស្សនៅក្នុងស្នាដៃអក្សរសិល្ប៍ដែលមានលក្ខណៈជាសង្គមមនុស្សពិត១។) សង្គមរសក្នុងរឿងតេជោយ៉ត គឺឆ្លុះបញ្ចាំងពីសង្គមខ្មែរនាសម័យឧដុង្គ ដែលមានការរើសអើងវណ្ណៈ ការប្រកួតប្រជែង ការធ្វើពិធីបុណ្យរំលឹកវិញ្ញាណក្ខន្ធ ពិធីរៀបអាពាហ៍-ពិពាហ៍ ។ល។

៦. លក្ខណៈដូចគ្នា និងលក្ខណៈខុសគ្នារវាងជំទាវស្រែន និងនាងម៉ែ ៖

+ **លក្ខណៈដូចគ្នា** : ជានារីសុភាពរាបសា មានភក្តីភាពចំពោះស្នេហាដូចគ្នា មានសម្រស់ស្អាត។

+**លក្ខណៈខុសគ្នា**

| ជំទាវស្រែន | នាងម៉ែ |
|---|---|
| - ជាស្ត្រីមានប្តីហើយ<br>- គោរពប្រពៃណីជាស្ត្រីខ្មែរបានល្អ<br>- មានប្រាជ្ញាវាងវៃ<br>- ត្រូវបានតេជោយ៉តស្រឡាញ់ | - ជានារីនៅក្រមុំ<br>- បណ្តោយខ្លួនឱ្យស្នេហាដឹកមុខ ភ្លេចតម្លៃជាស្ត្រី<br>- មិនអាចធ្វើឱ្យតេជោយ៉តស្រឡាញ់ |

| | |
|---|---|
| - ក្លាយជាភរិយាតេជោយ៉ត | - ក្លាយជាប្អូនស្រីតេជោយ៉ត |

+ឧត្តមភាពរបស់នាងម៉ែស្ថិតនៅត្រង់ មានភក្តីភាពជ្រាលជ្រៅចំពោះសេចក្តីស្នេហា ចេះភ្ញាក់រលឹកពីការវង្វេងនឹងស្នេហា ហើយយល់ពីតម្លៃពិតនៃសេចក្តីស្នេហា។

+ឧត្តមភាពរបស់ជំទាវស្រែនស្ថិតនៅត្រង់ ជួយកម្ចាត់សត្រូវដែលបម្រុងដណ្តើមរាជ្យ មានឧបាយកលឆ្នើម មានភក្តីភាពជ្រាលជ្រៅចំពោះស្វាមី ព្រមទាំងលះបង់គំនិតរើសអើងពូជសាសន៍ និងវណ្ណៈ។

៧. ស្ថានភាពជាកត្តាកំណត់លើវីរជន ព្រោះថាគេឃើញវីរជននៅពេលប្រយុទ្ធក្នុងសមរភូមិ ពេលធ្វើចម្បាំង ឬការលះបង់ដ៏ធំធេងដើម្បីបុព្វហេតុមនុស្សជាតិ...។

តេជោយ៉តក្នុងវគ្គដកស្រង់នេះ អាចចាត់ទុកជាវីរជនបាន ព្រោះតេជោយ៉តមានភាពអង់អាចក្លាហាន មានមនសិការជាតិខ្ពស់ គោរពស្រឡាញ់អ្នកមានគុណដោយស្មោះ និងចង់ជួយយកអាសារជំទាវស្រែនដោយស្មោះអស់ពីចិត្ត ហើយចេះមានឧបាយកលឱ្យជំទាវស្រែនទទួលយកធ្វើជាប្តីដោយប្រើបញ្ញាញាណ។

៨. សេចក្តីស្នេហារវាងជំទាវស្រែននិងតេជោយ៉តបានផ្តល់ជាផលវិបាកដល់តេជោយ៉តដែលចង់បានជំទាវស្រែនយកមកធ្វើជាភរិយា និងផ្តល់ផលវិបាកសម្រាប់ជំទាវស្រែនក្នុងការទទួលយកតេជោយ៉តមកធ្វើជាស្វាមី ព្រោះដោយសារបញ្ហាជាតិសាសន៍ និងជញ្ជាំងវណ្ណៈ។ តេជោយ៉តជាជនជាតិភាគតិច ហើយធ្លាប់ជាអ្នកបម្រើជំទាវស្រែន និងជាកូនសិស្សស្វាមីរបស់ខ្លួនទៀត...។



# លក្ខណៈពិសេសរបស់ល្ខោន

## សំណួរ

១. តើល្ខោនមានប៉ុន្មានប្រភេទ? អ្វីខ្លះ?
២. តើប្រភេទល្ខោនអ្វីខ្លះ ដែលនៅមានគេសំដែងរាល់ថ្ងៃ?
៣. តើប្រភេទល្ខោនអ្វីខ្លះដែលបានបាត់បង់? ហេតុអ្វី?
៤. ចូរអ្នកបញ្ជាក់ន័យខ្លីៗអំពីល្ខោនអាប៉េ ល្ខោនមហោរី ល្ខោនប្រា-មោទ្យ ល្ខោនខោល ល្ខោននិយាយ ល្ខោនយីកេ ល្ខោនស្រមោល ។

## ចម្លើយ

១. ល្ខោនមានជាងម្ភៃប្រភេទគឺ ៖

- ល្ខោនស្រមោល "ស្បែកធំ"
- ល្ខោនស្រមោល "ស្បែកតូច"
- ស្បែកពណ៌ "ស្បែកសំដែងពេលថ្ងៃ"
- ល្ខោនខោល( ល្ខោនប្រុស ឬល្ខោនពាក់មុខ)
- ល្ខោនព្រះរាជទ្រព្យ
- ល្ខោនមហោរី
- ល្ខោនចាប៉ីរឿង និទានរឿង ខ្សែដៀវ
- ល្ខោនបាសាក់
- ល្ខោនពោលស្រី
- ល្ខោនប្រាមោទ្យ ឬប្រាមោទ័យ

- ល្ខោនអាប៉េ
- ល្ខោនគែន
- ល្ខោនបើកបទ
- ល្ខោនភ្លេងការ
- ល្ខោនតុក្កតា
- ល្ខោននិយាយ
- ល្ខោនចម្រុះ
- ល្ខោនកំណាព្យ
- យីកេ
- អាយ៉ៃរឿង
- ស្បែកសំដែងជារឿង ។

២. ប្រភេទល្ខោនដែលនៅមានគេសំដែងរាល់ថ្ងៃមាន ល្ខោនបាសាក់ ល្ខោនស្រមោល ល្ខោនយីកេ ល្ខោនព្រះរាជទ្រព្យ ល្ខោនមហោរី ល្ខោនចាប៉ីរឿង និទានរឿង ល្ខោននិយាយ អាយ៉ៃរឿង ល្ខោនភ្លេងការ... ។

៣. ប្រភេទល្ខោនដែលបានបាត់បង់មាន ល្ខោនស្បែកពណ៌សម្តែងពេលថ្ងៃ ល្ខោនខោល ល្ខោនខ្សែដៀវរឿង ល្ខោនពោលស្រី ល្ខោនអាប៉េ ល្ខោនប្រាមោទ្យ ល្ខោនគែន ល្ខោនបើកបទ ល្ខោនតុក្កតា ល្ខោនចម្រុះ ល្ខោនកំណាព្យ ល្ខោនស្បែកសម្តែងជារឿង.....។ ព្រោះសព្វថ្ងៃនេះមានការហូរចូលនៃសិល្បៈបរទេសមកស្រុកខ្មែរយ៉ាងគំហុកដែលធ្វើឱ្យកូនខ្មែរជំនាន់ក្រោយ បំភ្លេចវប្បធម៌របស់ខ្លួន ហើយងាកទៅចាប់យកវប្បធម៌បរទេសទាំង

នោះដោយមិនដឹងខ្លួន។

៤. បញ្ចាក់ន័យ

- **ល្ខោនអាប៉េ** : វង់តន្ត្រីល្ខោនអាប៉េមានដើមកំណើតនៅខេត្តកំពង់ចាម(ស្រុកមេមត់) នៅខេត្តតាកែវភាគខាងត្បូង នៅកំពត និងនៅព្រះបរមរាជវាំង។ ទម្រង់ល្ខោនអាប៉េនេះមានប្រជាប្រិយភាពណាស់ដែរ ហើយល្ខោននេះច្រើនសំដែងក្នុងពិធីបុណ្យប្រជាពលរដ្ឋ។ ឧបករណ៍ភ្លេងមាន ស្គរដៃ ស្គរយីកេ ឈិង ទ្រអ៊ូ ក្រាប់។

- **ល្ខោនមហោរី** : ល្ខោននេះមានប្រជាប្រិយភាពក្នុងចំណោមប្រជាជនខ្មែរ។ វង់ភ្លេងមហោរីនេះមានដើមកំណើតបន្ទាប់ពីវង់តន្ត្រីមហោរី គឺកើតនៅក្នុងព្រះបរមរាជវាំងតែម្តង។ ល្ខោននេះអាចសម្តែងរឿងបុរាណខ្លះដូចជាពុទ្ធប្រវត្តិ ព្រះវេស្សន្តរ ក្រុងសុភមិត្រ ប្រវត្តិសាស្ត្រជាតិ និងពពួកសត្វ(ប្រៀបធៀបមកមនុស្ស) និងរឿងកំប្លុកកំប្លែង ទុក្ខសោក ព្រាត់ប្រាសក្នុងបច្ចុប្បន្នកាលនេះផង។ ការសម្តែងគឺមានភ្លេងនាំមុខ បន្ទាប់ពីនោះត្រូវមានអ្នកពោលបន្ថែមបង្ហាញតួអង្គនីមួយៗផង។ ល្ខោននេះច្រើនសំដែងក្នុងពិធីបុណ្យប្រជាពលរដ្ឋ ឬថ្វាយព្រះរាជាទតកំសាន្ត។

- **ល្ខោនប្រាមោទ្យ** ជាទម្រង់ល្ខោនមួយបែបដែលសំដែងរឿងខ្លីៗប្រកបដោយបរិយាកាសរីករាយ មិនសំដែងរឿងកំសត់ព្រាត់ប្រាស ឬការប្រើវេទមន្តច្បាំងគ្នាខ្លាំងក្លាអ្វីឡើយ។ តាមអ្នកស្រាវជ្រាវល្ខោននេះមានវត្តមាននៅលើទឹកដីកម្ពុជាយើងតាំងពីមុនសម័យអង្គរមកម្ល៉េះ។ តែល្ខោននេះទើបតែមានឥទ្ធិពលខ្លាំងនៅសម័យ

ចតុមុខ ។ ការសម្តែងសាច់រឿងនីមួយៗច្រើនមានអត្ថន័យស្នេហា ពោរពេញទៅដោយកាយវិការទន់ភ្លន់ និងពាក្យពេចន៍ផ្អែមល្ហែម ។ ល្ខោននេះច្រើនសម្តែងជូនភ្ញៀវកិត្តិយស និងទស្សនិកជនទូទៅទស្សនាផងដែរ ។

- **ល្ខោនខោល** ជាទម្រង់សិល្បៈម្យ៉ាងដែលតួរាំសុទ្ធតែប្រុស ។ ល្ខោននេះមានចំណាស់មិនខុសពីរបាំឬល្ខោនក្បាច់បុរាណខ្មែរឡើយ ។ ក្រោយអរិយធម៌អង្គរដ៏មហារុងរឿងបានធ្លាក់ចុះ ល្ខោននេះស្ទើរតែបាត់បង់ដូចទម្រង់សិល្បៈដទៃទៀតដែរ ។ ក្រោយមកគេឃើញល្ខោនខោលនេះចាប់កំណើតឡើងវិញនៅវត្តដីស ខេត្តបាត់ដំបង និងវត្តស្វាយអណ្តើក ស្រុកល្វាឯម ខេត្តកណ្តាល ។ កាលដើមឡើយល្ខោនខោលសម្តែងតែរឿង "រាមកេរ្តិ៍" ។ តែក្រោយមក ដោយមានប្រជាប្រិយភាពក្នុងចំណោមមហាជន ល្ខោននេះក៏សម្តែងរឿងដទៃទៀតដូចជារឿងព្រះវេស្សន្តរ រឿងព្រះសុធនកែវមនោរាហ៍...។ ល្ខោននេះច្រើនសម្តែងក្នុងពិធីបុណ្យសាសនានៅតាមវត្តអារាម ឬនៅក្នុងព្រះបរមរាជវាំង ។

- **ល្ខោននិយាយ** ជាទម្រង់សិល្បៈមួយដែលមានប្រភពមកពីអឺរ៉ុប ។ ល្ខោននិយាយច្រើនសំដែងរឿងសម័យទំនើប ទាក់ទងនឹងបញ្ហាវណ្ណៈអ្នកមាន អ្នកក្រ កម្មករនិងនិយោជក ឬរឿងល្បើកផ្សេងៗ ។

- **ល្ខោនយីកេ** ជាសិល្បៈមួយដែលមានដើមកំណើតមកពីជ្វា ឬម៉ាឡាយូ ហើយទំនងជាចូលមកស្រុកខ្មែរតាមរយៈព្រះបាទជ័យវរ្ម័នទី២ ឬតាមរយៈជនជាតិចាម ។ ល្ខោនយីកេសម្តែងរឿងបុរាណក៏បាន រឿងទំនើបក៏បាន ។ គេសម្តែងល្ខោនយីកេនៅពេលមានបុណ្យ

ទានតាមភូមិ ឬតាមវត្តអារាម ឬនៅពេលទំនេរពីការងារស្រែចម្ការ ។

- ល្ខោនស្រមោល មានពីរប្រភេទ គឺសិល្បៈស្បែកធំ និងសិល្បៈស្បែកតូចហៅថាអាយ៉ង ។ ល្ខោនស្បែកតូចអាចសំដែងបានក្នុងពិធីបុណ្យទានទូទៅនៅតាមភូមិឬវត្តអារាម ។ ល្ខោននេះមានអាយុមុនសម័យអង្គរឆ្ងាយណាស់ ។ ឯល្ខោនស្បែកធំសំដែងក្នុងពិធីផ្សេងៗ ដូចជា សុំទឹកភ្លៀង ចំរើនព្រះជន្មចៅអធិការ ឬមាតាបិតា ឬជាសពមាតាបិតា ឬចៅអធិការវត្តជាដើម ។ ល្ខោនស្បែកធំត្រូវបានគេអនុញ្ញាតឱ្យសម្ដែងតែរឿងព្រះជិនវង្ស រឿងព្រះលក្សិណវង្ស ស័ង្ខសិល្ប៍ជ័យ ព្រះសុធននាងកែវមនោរាហ៍... និងរឿងសម័យពិសេសរឿងដែលកើតមាននៅក្នុងសង្គមដូចជា ការជិះជាន់កេងប្រវ័ញ្ចរបស់ចៅកែ និងពួកអាណានិគមមកលើប្រជាជនស្លូតត្រង់ ឬការចំអកពេបជ្រាយ រិះគន់ចំពោះអ្នកជិះជាន់ទៀតផង ។



# រឿងថៅកែចិត្តចោរ

## សំណួរ

១. ចូរអ្នកធ្វើការវិភាគតួអង្គហាំ ផានីត យ៉ាន ថៅកែ សៃហ្វ។

២. តើកត្តាអ្វីខ្លះដែលនាំឱ្យហាំសម្រេចចិត្តបើកឡានបុកឡានថៅកែអុងប៉ាងហុងលី? ការសម្រេចចិត្តប្រព្រឹត្តបែបនេះបានជះឥទ្ធិពលចំពោះផ្លូវច្បាប់ ផ្លូវសីលធមិ និងផ្លូវសាសនាយ៉ាងណាខ្លះ?

៣. តាមរយៈតួអង្គហាំ ផានីត សៃហ្វ បានផ្ដល់តម្លៃអប់រំយ៉ាងណាខ្លះ?

៤. ចូរអ្នកធ្វើការបង្ហាញវិធីតែងនិពន្ធនៃអត្ថបទល្ខោនខាងលើនេះ។

៥. ដោយឆ្លុះបញ្ចាំងតាមរយៈសកម្មភាពតួអង្គក្នុងរឿងនេះ ចូរបង្ហាញពីសច្ចរស សង្គមរស តថរស វីររស កុសលរស។

៦. តើអត្ថបទខាងលើ អ្នកនិពន្ធបានបង្ហាញពីប្រធានរឿងអ្វី លើកយកបញ្ហាអ្វីមកចោទនិងដោះស្រាយ ហើយមានគំនិតដឹកនាំ (ឧត្តមគតិរឿង) យ៉ាងដូចម្ដេច?

## ចម្លើយ

១. វិភាគតួអង្គហាំ ផានីត យ៉ាន ថៅកែ សៃហ្វ៖

+ **ហាំ**

**ក-គុណសម្បត្តិ**

-ជាមនុស្សម៉ឺងម៉ាត់គោរពសច្ចធម៌
-ស្រឡាញ់គ្រួសារ ប្រពន្ធ កូន ម្ដាយ
-មានទំនួលខុសត្រូវលើគ្រួសារ
-រិះរកគ្រប់មធ្យោបាយដើម្បីផ្គត់ផ្គង់គ្រួសារ
-មិនចុះញ៉មនឹងការគំរាមកំហែង
-ស្រឡាញ់យុត្តិធម៌

**ខ-គុណវិបត្តិ**

-ដើម្បីជីវភាពផ្ទាល់ខ្លួនហ៊ានប្រព្រឹត្តអំពើទុច្ចរិត
-ជាមនុស្សគិតខ្លី យកប្រាក់ជាធំ
-បន្សល់នូវភាពឈឺចាប់ដល់គ្រួសារ

**+ជាទីត**

**ក-គុណសម្បត្តិ**

-ជាអ្នករៀនសូត្រចេះដឹង
-ស្រឡាញ់យុត្តិធម៌ មិនធ្វើតាមបញ្ជារបស់ពួកនាយទុន
-ចេះពិចារណា ស្គាល់ខុសស្គាល់ត្រូវ ល្អអាក្រក់
-ស្អប់ខ្ពើមអំពើពុករលួយ អយុត្តិធម៌
-ចេះជួយពន្យល់មូលហេតុដល់ពូហាំ

**ខ-គុណវិបត្តិ**

-មានគំនិតជួយមនុស្សដែលប្រព្រឹត្តខុសច្បាប់ឱ្យរត់គេចខ្លួន
-ជួយអ្នកដទៃមិនប្រមាណសមត្ថភាពខ្លួន រហូតត្រូវថៅកែ

បណ្តេញចេញពីការងារ ។

**+ មីងយ៉ាន**

**ក -គុណសម្បត្តិ**

-ស្រឡាញ់ប្តី ចេះព្រួយបារម្ភពីប្តី មិនចង់ឱ្យប្តីជាប់គុក

-ស្រឡាញ់ម្តាយ និងកូន

-ស្រឡាញ់កិត្តិយសគ្រួសារ

-ស្រឡាញ់យុត្តិធម៌ មិនឈ្លក់វង្វេងទឹកប្រាក់

**ខ -គុណវិបត្តិ**

-ភិតភ័យខ្វះការពិចារណា ធ្វើឱ្យប្តីខឹងច្រឡោត

-មិនស្គាល់ធាតុពិតរបស់ថៅកែ

-ជាស្ត្រីទន់ខ្សោយ គិតតែពីយំ

**+ ថៅកែឡាន**

**ក -គុណសម្បត្តិ**

-ជួយផ្តល់ការងារឱ្យកម្មករធ្វើ

-ជួយជាតិ ដូចជាសាងសង់សាលា ធ្វើបុណ្យជាដើម

**ខ -គុណវិបត្តិ**

-ជាថៅកែចិត្តចោរ

-មានគំនិតបំផ្លាញឈ្នានីសអ្នករកស៊ីដូចគ្នា

-ជាមនុស្សអាក្រក់ អាងទឹកលុយ យកលុយទិញក្បាល
អ្នកក្រ

-កេងប្រវ័ញ្ចញើសឈាមកម្មករ

-ជាមនុស្សគ្មានសតិសម្បជញ្ញៈ

-ជាមនុស្សមិនគោរពពាក្យសច្ចៈ

-ប្រមាថយុត្តិធម៌ យកលុយបិទមាត់គេយករួចខ្លួន

+សៃហ្វ

**ក-គុណសម្បត្តិ**

-តាមចាប់ជនល្មើសទាល់តែបាន

**ខ-គុណវិបត្តិ**

-ជាអ្នកកាន់ច្បាប់ តែបំពានលើច្បាប់

-គ្មានយុត្តិធម៌ ទទួលសំណូកពីជនទុច្ចរិតធ្វើបាបអ្នកក្រ។

២. កត្តាដែលនាំឱ្យហាំសម្រេចចិត្តបើកឡានបុកឡានថៅកែអុងប៉ាង ហុងលី ព្រោះហាំទាល់ច្រកក្នុងការរកប្រាក់ផ្តល់ឱ្យគ្រួសារ និងម្យ៉ាងទៀតថៅកែសន្យាផ្តល់ប្រាក់១០០០០រៀលឱ្យហាំប្រសិនបើហាំបើកឡានបុកឡានរបស់អុងប៉ាងហុងលីផងនោះ ហាំក៏សម្រេចធ្វើទាំងបង្ខំចិត្តតែម្តងទៅ។

*ការសម្រេចចិត្តប្រព្រឹត្តបែបនេះបានជះឥទ្ធិពលចំពោះផ្លូវច្បាប់ ផ្លូវសីលធម៌ និងផ្លូវសាសនាដូចជា ៖*

+ **ផ្លូវច្បាប់** : ការសម្លាប់មនុស្សដោយចេតនា ជាអំពើឧក្រិដ្ឋខុសនឹងច្បាប់រដ្ឋ, ត្រូវផ្តន្ទាទោស...។

+ **ផ្លូវសីលធម៌** : ជាទង្វើអមនុស្សធម៌ ឃោរឃៅ គ្មានតម្លៃជាមនុស្ស សង្គមស្អប់ខ្ពើម...។

+**ផ្លូវសាសនា** : ប្រព្រឹត្តផ្ទុយនឹងសីលទី១ នៃនិច្ចសីលរបស់

ពុទ្ធសាសនា គឺ បាណាតិបាតា វេរមណី សិក្ខា បទំ សមា្ទ ទិយាមិ ។ ទោសនេះត្រូវធ្លាក់នរក មានកម្មពៀរ...។

៣. តាមរយៈតួអង្គហាំ ផានីត សែហ្វ បានផ្តល់តម្លៃអប់រំ ៖

- ឱ្យស្អប់ខ្ពើមអំពើអយុត្តិធម៌
- ឱ្យមានកំហឹងឈឺចាប់ចំពោះអំពើស៊ីសំណូក អយុត្តិធម៌
- ឱ្យចេះសាមគ្គីគ្នា ស្រឡាញ់យុត្តិធម៌
- ឱ្យចេះភ្ញាក់រលឹកចំពោះអំពើបោកបញ្ឆោត
- គិតពិចារណាឱ្យបានច្បាស់លាស់ក្នុងការធ្វើអ្វីមួយ
- ឱ្យហ៊ានទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន

៤. វិធីតែងនិពន្ធនៃអត្ថបទល្ខោនខាងលើ ៖

- **អត្ថន័យ** : បង្ហាញពីការទាស់ទែងខ្វែងគំនិតគ្នារវាងតួអង្គដែលមានសមត្ថភាពប្រហាក់ប្រហែលគ្នា។ ដំណើររឿងមានលក្ខណៈតឹងតែង ធូរស្រាលប្រកបដោយជ័យជំនះបរាជ័យ មានស្លាប់ មានរស់ មានកម្សត់លោយគ្នា។ អ្នកអានមិនរំភើបពេក មិនភ័យពេក មិនកើតទុក្ខពេក និងមិនសប្បាយពេក។
- **អត្ថរូប** (ទម្រង់សំណេរអត្ថបទរឿង)

  + ចែកជាឈុតនិងឆាក

  + នៅខាងដើមអត្ថបទរឿង មានបញ្ជីរាយនាមតួអង្គនិងមុខងារ

  + សរសេរជាពាក្យរាយ ជាបទសន្ទនារវាងតួអង្គនិងតួអង្គ (សំវាទវិធី)

- **អត្ថរស** ៖ អ្នកនិពន្ធបញ្ចូលនូវគំនិត យោបល់ ទស្សនៈ ជំហររបស់ខ្លួនទៅក្នុងសកម្មភាពនៃរឿង។ ពាក្យពេចន៍ចរចាដើម្បីជាការរិះគន់ប្រដៅណែនាំ ទូន្មានអ្នកអាន អ្នកទស្សនា។

៥. បង្ហាញ៖

- **សច្ចរស** ៖ រាល់ពេលដែលមានអំពើជិះជាន់ ការកេងប្រវ័ញ្ច ការបោកប្រាស់ អំពើអយុត្តិធម៌...គឺត្រូវតែមានការរើបម្រះ ការតស៊ូប្រឆាំងតបត ការទាមទាររកយុត្តិធម៌...ដូចករណីថៅកែនិងកម្មករ។
- **សង្គមរស** ៖ តម្លៃដែលអ្នកនិពន្ធបានបង្ហាញពីស្ថានភាពសង្គមពោរពេញទៅដោយអំពើពុករលួយ ស៊ីសំណូក និងការប្រកួតប្រជែងរវាងពួកនាយទុនដូចគ្នា។
- **តថរស** ៖ បង្ហាញពីតថភាពពិតចំពោះសង្គមនាសម័យកាលឆ្នាំ១៩៥៦ នៅរាជធានីភ្នំពេញ។ អ្នកនិពន្ធបានបង្ហាញពីអំពើអយុត្តិធម៌របស់អ្នកមានលុយ គឺពួកមូលធនអាចឈ្នះនូវអ្វីៗទាំងអស់ ឈ្នះនូវអំពើយុត្តិធម៌របស់កម្មករ ទាំងអ្នកកាន់ច្បាប់រដ្ឋអំណាច ដូចជាពាក្យបុរាណបានពោលថា *"ចិនបោកក្បាលនឹងប្រាក់ ខ្វាក់ភ្នែកមន្ត្រី" "មានប្រាក់អាចទិញយក្សមកប្រើបាន"*។
- **វីររស** ៖ តម្លៃដែលកើតចេញពីក្រុមកម្មករមានភាពក្លាហាន ហ៊ានតតាំងជាមួយថៅកែដើម្បីជួយអ្នកក្រដូចគ្នា។ ឯហាំសុខចិត្តជាប់គុកដើម្បីទាមទារយុត្តិធម៌...។

- **កុសលរស** : តម្លៃនៃការអប់រំអ្នកអាន អ្នកស្តាប់ឱ្យមានសតិសម្បជញ្ញៈភ្ញាក់រលឹក កុំធ្វើអ្វីតាមកម្លាំងទឹកប្រាក់ ឬកុំធ្វើជាអាយ៉ងនៃទឹកប្រាក់ ។ ហើយត្រូវហ៊ានការពារយុត្តិធម៌ ស្វែងរកយុត្តិធម៌ និងជួយកសាងសង្គមជាតិឱ្យជឿនលឿន... ។

៦. អត្ថបទខាងលើ អ្នកនិពន្ធបានបង្ហាញពីប្រធានរឿងទាក់ទងការកេងប្រវ័ញ្ច និងអំពើអយុត្តិធម៌ ។ បានសេចក្ដីថាអំពើទាំងនោះបានកើតមានក្នុងសង្គមខ្មែរពេលនោះ ដោយមានប្រភពមកពីលុយដែលពួកនាយទុនជាអ្នកបង្កឡើង ។ បញ្ហាដដែលនេះបង្កឱ្យអ្នកក្រីក្រស្ទួតត្រង់រងទុក្ខ ហើយក៏បានប្រែក្លាយជាការតស៊ូទាមទារយុត្តិធម៌ និងលុបបំបាត់ការកេងប្រវ័ញ្ចនេះយ៉ាងសកម្មផងដែរ ។

+ **បញ្ហាចោទ** : ទំនាស់រវាងពូហាំតំណាងអ្នកក្រីក្រ ជាមួយថៅកែ (នាយទុន) ដោយបញ្ហានេះកើតចេញពីលុយ១០០០០រៀល ។

+ **ដំណោះស្រាយ** : គឺថៅកែឈ្នះ ដោយគេយកប្រាក់ទៅស្រាយពោលគឺថៅកែសូកប៉ូលិសយករួចខ្លួន ហើយទម្លាក់កំហុសលើហាំតែម្នាក់ឯង ។ ចំណែកកម្មករដែលមិនគាំទ្រថៅកែ ត្រូវបណ្ដេញចេញពីការងារ ។

+ **គំនិតដឹកនាំ** (ឧត្តមគតិរឿង)

- ឱ្យស្អប់ខ្ពើមអំពើអយុត្តិធម៌
- ឱ្យមានកំហឹងឈឺចាប់ចំពោះអំពើស៊ីសំណូក អយុត្តិធម៌
- ស្រឡាញ់យុត្តិធម៌
- មុននឹងជឿគេ ឬធ្វើអ្វីៗត្រូវចេះគិតពិចារណា
- ខិតខំរៀនសូត្រ ដើម្បីរំដោះពីភាពល្ងង់ខ្លៅ
- ស្រឡាញ់កម្មករ មានចិត្តស្លូតត្រង់ សុចរិត ការពារយុត្តិធម៌
- មិនឱ្យប្រព្រឹត្តអំពើខុសច្បាប់
- ..........................................

មេរៀនទី ៦

# សិលាចារឹកនិងរបាំ



## សិលាចារឹក (ប្រាសាទភិមានអាកាស)

### សំណួរ

១. តើអត្ថបទពាក្យសម្បថនេះ បានតាក់តែងឡើងនៅពេលណា? មានបុគ្គលណាជាអធិបតី? ហើយអ្នកណាជាអ្នកស្បថ?

២. ចូរបង្ហាញពីប្រធានបទនៃអត្ថបទដកស្រង់ មូលន័យ ។

៣. តើខ្លឹមសារនៃអត្ថបទនេះ អាចចែកចេញជាប៉ុន្មានផ្នែក? មានអ្វីខ្លះ?

៤. រកគំនិតអប់រំតាមរយៈអត្ថបទនេះ ។

៥. ចូរអ្នកសាកល្បងអានសិលាចារឹកដែលសរសេរតាមលំនាំខ្មែរបុរាណ និងប្រែជាភាសាខ្មែរទំនើបខាងលើនេះ ។

ក. បង្ហាញពីលក្ខណៈជាតិ ដោយរកអំណះអំណាងជាពាក្យទំនឹមទំនៀម ចំនួនពីរបីឃ្លាដែលមានអត្ថន័យទាក់ទងនឹងខ្លឹមសារនៃអត្ថបទចារឹកនេះ ។

ខ. បកស្រាយពីអត្ថន័យនៃមហាសករាជ ។ ក្រៅពីមហាសករាជ តើជាតិខ្មែរធ្លាប់ប្រើសករាជអ្វីទៀត? ចូរពន្យល់ ។

គ. បង្ហាញពីសំណេរភាសាខ្មែរសម័យទំនើបនិងពន្យល់ពាក្យដែលមានក្នុងអត្ថបទដើម : វ្រះ វ្រាហ្មណាចារ្យិ ចំបាង្គ អំបាល្ល ។

ឃ. ពាក្យ "នេះហ" ត្រូវនឹងសំណេរខ្មែរទំនើបយ៉ាងដូចម្ដេច? បើគិតតាមសូរវិទ្យាអន្តរជាតិ (API) វិញ តើព្យញ្ជនៈខ្យល់ "ហ" ត្រូវនឹងព្យញ្ជនៈខ្យល់ស្ទះ ព្យញ្ជនៈខ្យល់ច្រមុះ ឬព្យញ្ជនៈខ្យល់បង្ហូរ? ហើយ "នេះហ" ស្ថិតក្នុងទម្រង់ណាមួយ (ពស ពពស ពសព ឬ ពពសព)? បើតាមអ្នកធ្លាប់សិក្សាកន្លងមក តើមានពាក្យ១ព្យាង្គណាខ្លះទៀត ដែលមានសូរចុងព្យាង្គដោយខ្យល់ "ហ" នេះ? ចូររកឧទាហរណ៍ឱ្យបានប្រាំពាក្យ (ពាក្យ១ព្យាង្គ) ។

## ចម្លើយ

១. អត្ថបទពាក្យសម្បថនេះ បានតាក់តែងឡើងនៅថ្ងៃ៩កើត ខែភទ្របទ ត្រូវនឹងថ្ងៃអាទិត្យ ក្នុងរវាងមហាសករាជ៩៣៣ (ស.វ. ១១) ។ ពិធីសម្បថនេះធ្វើនៅចំពោះព្រះភក្ត្រព្រះករុណាព្រះបាទសម្ដេចស្រីសូរ្យិវម្មិទេវៈ(សូរ្យវរ្ម័នទី១) ចំពោះមុខព្រះភ្លើង ព្រះរតនៈ និងព្រាហ្មណាចារ្យ ។ ហើយអ្នកសម្បថគឺ តម្រួតរបស់ភាគ ឬតំបន់ថ្នាក់ឯក ទោ ត្រី ចត្វា ។

២. + ប្រធានបទនៃអត្ថបទដកស្រង់នេះគឺពាក្យសម្បថ ។
+ មូលន័យនៃអត្ថបទដកស្រង់គឺ ភាពស្មោះត្រង់ចំពោះការងារ ។

៣. ខ្លឹមសារនៃអត្ថបទនេះ អាចចែកចេញជាពីរផ្នែក ៖

- **ផ្នែកទី១** : ការប្រកាសពាក្យប្ដេជ្ញាចិត្តចំពោះវត្ថុសក្ដិសិទ្ធិរបស់អ្នកសម្បថ៖

+ សុខចិត្តកាត់ដៃ ថ្វាយអាយុចំពោះព្រះករុណាព្រះបាទសម្តេចសូរ្យវរ្ម័នទី១ ។

+ ខំប្រឹងធ្វើការងារគ្រប់បែបយ៉ាងដែលព្រះអង្គបានដាក់ចុះ ។

+ មិនគោរពអ្នកណាក្រៅពីព្រះអង្គឡើយ ។

+ ប្តេជ្ញាចិត្តចេញច្បាំងដោយស្មោះត្រង់អស់ពីចិត្ត ឥតស្តាយជីវិត មិនរត់ចោលគ្នាពេលច្បាំងនោះទេ ។

- **ផ្នែកទី២** : ពាក្យសំណូមពររបស់អ្នកស្បថ៖

+ បើពួកគេស្លាប់នឹងជំងឺបៀតបៀន សូមឱ្យបានទទួលរង្វាន់ជាអ្នកមានភាពកតញ្ញូភក្តីចំពោះអម្ចាស់ ។

+ បើសិនជានៅមានអាយុជីវិតអាចធ្វើការបានដល់ស្លាប់សូមឱ្យគេបានបម្រើការងារនោះដោយអំណាចនៃស្វាមីភក្តិ

+ បើសិនគេទាំងអស់គ្នាបំពេញការងារបានល្អបរិសុទ្ធ តាមពាក្យសច្ចាប្រណិធាននេះ សូមព្រះគម្តែងផ្ទៃក្រោម ទ្រង់បំពេញការងារបានល្អបរិសុទ្ធ តាមពាក្យសច្ចាប្រណិធាននេះ ។

+ សូមឱ្យព្រះគម្តែងផ្ទៃក្រោមទ្រង់មេត្តារាជទានប្រើឱ្យពួកគេបានថែទាំនូវការស្ថាបនាជាកុសលរបស់ស្រុកយើង និងផ្តល់នូវភាពស្ថិតស្ថេរសម្បូររុងរឿងនៃត្រកូលរបស់ពួកគេ ។

៤. គំនិតអប់រំក្នុងអត្ថបទគឺ៖

- មានចិត្តស្មោះត្រង់ចំពោះអ្នកដឹកនាំ និងចំពោះក្រុម ។

- ចេះគោរពពាក្យសច្ចៈចំពោះអ្វីដែលខ្លួនបាននិយាយ ។
- មានទឹកចិត្តស្នេហាជាតិពិតៗ ។
- ហ៊ានលះបង់ជីវិតដើម្បីមាតុភូមិ ។
- មានសេចក្តីក្លាហាន មិនចុះញ៉មនឹងសត្រូវ
- ................................. ។

៥. ក. បង្ហាញពីលក្ខណៈជាតិ នៃអត្ថបទចារឹកនេះ ៖

- គោរពពាក្យសច្ចៈ ( ពាក្យសច្ចៈជាព្រលឹងទី៩ ក្នុងចំណោមព្រលឹងទាំង១០របស់ខ្មែរ) ។
- ជឿលើពាក្យសម្បថ ( ស្បថមុនពេលឡើងកាន់តំណែង)

+អំណះអំណាងជាពាក្យទំនឹមទំនៀមដែលមានអត្ថន័យទាក់ទងនឹងខ្លឹមសារនៃអត្ថបទសិលាចារឹកនេះគឺ៖

- សំដីជាឯក លេខជាទោ ។
- សំដីសជាតិ មារយាទសពូជ ។
- មនុស្សគេយកសំដី ដីរគេយកភ្លុក ។

.......................................... ។

ខ. បកស្រាយពីអត្ថន័យនៃមហាសករាជ ៖

**-មហាសករាជ** កើតឡើងក្នុងរាជព្រះបាទសកៈ ឬសាលី វាហានៈនៅក្នុងប្រទេសឥណ្ឌា ក្នុងព.ស.៦២១ ដោយប្រារព្ធយកជ័យជំនះយ៉ាងសម្បើមរបស់ក្សត្រអង្គនេះជាកេណ្ឌ ។ ប៉ុន្តែក្នុងជំនាន់មុនហៅត្រឹមតែស័ក ឬសករាជប៉ុណ្ណោះ ។ លុះក្រោយមកមានសករាជថ្មីកើតឡើងទៀត ទើបហៅសករាជព្រះចៅសាលីវាហានៈថាមហាសករាជ ។ មហាសករាជ សរសេរអក្សរកាត់ថា "ម.ស" ។

ក្នុងព្រះរាជពង្សាវតាខ្មែរថា ព្រះបាទសម្តេចអរិជ្ជពលពាហ អោព្រះកេតុមាលាសូរ្យវ័ន្ន បានតាំងមហាសករាជ១ក្នុងព.ស. ៦២១ឆ្នាំ។

ព្រះបាទសម្តេចព្រះសិន្ធពរអមរិន្ទ បរមព្រហ្មកិល ( ពញាក្រែក) បានតាំងសករាជ១ក្នុងព.ស១១៨១ឆ្នាំ។ ក្នុងពង្សាវតានគរឈៀងម៉ៃ( លាវ) ថា ព្រះបាទពន្ធមតីក្នុងប្រទេសលង្កា ទ្រង់តាំងមហាសករាជនេះឡើង។ តែបើតាមការពិតនោះគឺព្រះបាទសាលីវាហនទ្រង់តាំងឡើងហើយ ព្រះបាទពន្ធមតីគ្រាន់តែយកទៅប្រកាសប្រើក្នុងប្រទេសខ្លួនប៉ុណ្ណោះ។

ក្រៅពីមហាសករាជ ជាតិខ្មែរធ្លាប់ប្រើសករាជផ្សេងទៀតដូចជា៖

- **ពុទ្ធសករាជ** ជាសករាជដែលរាប់ចំនួនថ្ងៃខែឆ្នាំពីថ្ងៃពុធ ១រោច ខែពិសាខ ឆ្នាំម្សាញ់ក្រោយថ្ងៃដែលព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមសមណគោតមបរិនិព្វានទៅបានមួយថ្ងៃវៀងមក។ ព្រះសម្មាសម្ពុទ្ធទ្រង់បរិនិព្វាននៅថ្ងៃអង្គារ ១៥កើត ខែពិសាខ ឆ្នាំម្សាញ់។ ហេតុនោះបានជារាប់ពីត្រឹមថ្ងៃ១រោច ខែពិសាខ ឆ្នាំម្សាញ់មកជាគេណ្ឌ។ ពុទ្ធសករាជ សរសេរអក្សរកាត់ថា ព.ស ។
- **គ្រិស្តសករាជ** ជាសករាជមួយកើតឡើង ក្រោយពុទ្ធសករាជចំនួន៥៤៣ឆ្នាំ ដោយសាស្តាម្នាក់ឈ្មោះយេស៊ូ ឬយេស៊ូគ្រិស្តជាអ្នកបង្កើតសាសនាគ្រិស្ត។ យេស៊ូកើតនៅអ៊ីស្រាអែលក្នុងសតវត្សទី៦ នៃពុទ្ធសករាជ( ព.ស. ៥៤៣) ទទួលមរណភាពក្នុង ព.ស. ៥៧៤ ក្នុងជន្មាយុ៣០ឆ្នាំ។ គ្រិស្តសករាជរាប់ពីត្រឹមឆ្នាំ

កំណើតយេស៊ូជាកាលកំណត់។ គ្រិស្តសករាជ សរសេរជាអក្សរកាត់ថា គ.ស។

- ចុល្លសករាជ ស្តេចភូមាទ្រង់ព្រះនាមសង្ឃរាជឬហៅថាបុញ្ញសោហានី ជាក្សត្រិយ៍ទី១៩ ក្នុងវង្សសម្មុទ្ទរិទ្ធី ទ្រង់តាំងឡើង(ក្នុងឆ្នាំកុរហើយរាប់ឆ្នាំជាឯកស័ក) ក្នុងព.ស.១១៨២ ដោយយកសុរិយគតិ គឺពេលប្រថ្មបខ្លួននៃព្រះអាទិត្យដែលគោចរចេញអំពីមេសរាសីហើយត្រឡប់ចូលមកមេសរាសីវិញជាកេណ្ឌ។ ឯការដែលប្រើពាក្យថា៖ ឯកស័ក ទោស័ក ត្រីស័ក ចត្វាស័ក បញ្ចស័ក សប្តស័ក អដ្ឋស័ក ឆព្វស័ក សំរិទ្ធិស័ក ប្រកបនឹងឈ្មោះឆ្នាំទាំង១២គឺ ជូត ឆ្លូវ ខាល ថោះ រោង ម្សាញ់ មមី មមែ វក រកា ច កុរ ក៏កើតឡើងក្នុងវេលាដែលកើតចុល្លសករាជនេះដែរ។

ក្នុងព្រះរាជពង្សាវតារខ្មែរថា ព្រះបាទសម្តេចព្រះបទុមសុរិយវង្សបានតាំងចុល្លសករាជ១ ក្នុងកាលពុទ្ធសករាជ១១៨៣ (ថ្ងៃចន្ទ ១២កើត ខែចេត្រ ឆ្នាំកុរឯកស័ក)។

ចុល្លសករាជសរសេរអក្សរកាត់ថា ច.ស.។

គ. បង្ហាញពីសំណេរភាសាខ្មែរសម័យទំនើបនិងពន្យល់ពាក្យដែលមានក្នុងអត្ថបទដើម : វ្រះ វ្រាហ្មាចារ្យ៊ ចំបាង្គ អំបាល្ល។

- វ្រះ = ព្រះ (គុ) ប្រសើរ, ខ្ពង់ខ្ពស់, លើសលន់; ជាចម្បង; ដែលគួរប្រាថ្នា, គួរចង់បាន។
- វ្រាហ្មណាចារ្យ៊ = ព្រាហ្មណាចារ្យ (ន) អាចារ្យក្នុងលទ្ធិព្រាហ្មណ៍។

- ចំបាង្គ = ចំបាំង (ន) សង្គ្រាម, ការច្បាំង, សឹក, ការតយុទ្ធ, ការចូលប្រឡូកគ្នា ។
- អំបាល្ល = អំបាល (និ) ដូចជា, ប្រហែលដូច, ប្រហែលដូចជា។

ឃ. ពាក្យ "នេះហ" ត្រូវនឹងសំណេរខ្មែរទំនើបថា "នេះ"

-បើគិតតាមសូរវិទ្យាអន្តរជាតិ(API) វិញ [nih] ព្យញ្ជនៈខ្យល់ "ហ" ត្រូវនឹងព្យញ្ជនៈ "ខ្យល់បង្ហូរ" ពួក "អ" ។

- ហើយ "នេះហ" [nih] ស្ថិតក្នុងទម្រង់ "ពសព" ។

- បើតាមខ្ញុំធ្លាប់សិក្សាកន្លងមក មានពាក្យ១ព្យាង្គ ដែលមានសូរចុងព្យាង្គដោយខ្យល់ "ហ" នេះជាច្រើន ដូចជា : នោះ[nuh] ជិះ[cih] សេះ[seh] រិះ[rih] ។ល ។



# របាំបុរាណខ្មែរ

## សំណួរ

១. តើរបាំអប្សរាជារបាំអ្វី? គេសំដែងរបាំនេះនៅពេលណា?

២. តើរបាំនេះមានកំណើតតាំងពីពេលណា? តើអ្នកណាជាអ្នកបង្កើតរបាំនេះមុនគេ? ហើយការបង្កើតរបាំនេះប្រព្រឹត្តទៅតាមវិធីណា?

៣. ចូរអ្នកបង្ហាញពីទម្រង់ និងអត្ថន័យនៃការសំដែងរបាំអប្សរា ដោយផ្អែកលើអត្ថបទនេះ ។

៤. ដោយផ្សារភ្ជាប់ទៅនឹងខ្លឹមសារនៃអត្ថបទ ចូរអ្នកធ្វើការឆ្លុះបញ្ចាំងពីលក្ខណៈជាតិសំខាន់ៗដែលមាននៅក្នុងរបាំអប្សរា ។

៥. ចូរអ្នកប្រៀបធៀបរបាំអប្សរានិងរបាំប្រជាប្រិយណាមួយដែលអ្នកធ្លាប់ស្គាល់ ។ តើរបាំទាំងពីរប្រភេទនេះ មានលក្ខណៈពិសេសក្នុងវប្បធម៌ជាតិយ៉ាងណាខ្លះ? ចូរពន្យល់ ។

៦. ចូរអ្នកធ្វើការវិភាគឃ្លានេះ "ថ្វីត្បិតតែរបាំអប្សរា មានចលនាសំដែងមួយៗ បែបយឺតៗ... ប៉ុន្តែលក្ខណៈនេះ បញ្ជាក់ច្បាស់នូវស្ថានភាពសម្បូណ៌សប្បាយនាសម័យកាលនោះ" ។

## ចម្លើយ

១. របាំអប្សរា ជាប្រភេទមួយនៃរបាំព្រះរាជទ្រព្យ ។ គេសំដែងរបាំនេះនៅពេលប្រារព្ធពិធីបុណ្យជាតិ បុណ្យសាសនា មហោស្រពសិល្បៈធំៗ និងពិធីទទួលស្វាគមន៍ភ្ញៀវជាតិ និងអន្តរជាតិ ។

២. របាំនេះមានកំណើតតាំងពីយូរយារណាស់មកហើយ ដែលមានរូបចម្លាក់នៅលើជញ្ជាំងប្រាសាទអង្គរវត្ត។ អ្នកបង្កើតរបាំនេះមុនគេគឺព្រះមហាក្សត្រីយានីស៊ីសុវត្ថិកុសមៈនារីរ័ត្ន នៅឆ្នាំ១៩៦១។
-ការបង្កើតរបាំនេះប្រព្រឹត្តទៅនៅក្នុងឱកាសដែលព្រះមហាក្សត្រីយានីយាងមកធ្វើទស្សនកិច្ចនៅសាលាបឋមសិក្សាសុធារស។ នាយិកាដែលបានរៀបចំពិធីសិល្បៈកុមារបានកាត់ក្រដាសធ្វើជាមកុដពាក់ដូចគ្នានឹងមកុដអប្សរាឆ្លាក់ជាប់នឹងជញ្ជាំងប្រាសាទអង្គរបេះបិទ។ រឿងនេះញ៉ាំងឱ្យព្រះមហាក្សត្រីយានីផ្ដួចផ្ដើមគំនិតបង្កើតរបាំនេះឡើង ដោយប្រសិទ្ធនាមថា "របាំអប្សរា"។

៣. ទម្រង់និងអត្ថន័យនៃការសំដែងរបាំអប្សរា៖

**+ ទម្រង់នៃការសម្ដែង**

- ប្រគំអមជាមួយបទភ្លេងមហោរីព្រះរាជទ្រព្យដែលមានចង្វាក់រាំទន់ភ្លន់។
- កាយវិការទន់ល្វាសល្វន់ គួបផ្សំនឹងដៃចាក់ក្បាច់រាំជើងលើកដាក់ប្រវាសម្ដងៗថ្នមៗ។
- ក្បាលធ្វើចលនារាំងាករេឆ្វេងស្ដាំចុះឡើងៗ។
- ម្រាមដៃអប្សរា ងខ្វង់ ចង្កេះរស់រវើកសមនឹងតួទរាងងស្មើត។
- មកុដអប្សរាមានកំពូល៧ តំណាងឱ្យកំពូលប្រាសាទរចនាក្បាច់ថ្នាំងអំពៅមានសមាមាត្រនឹងសក់វែងប្រះស្មា។
- នៅអមត្រចៀកមានរចនាសក់ក្រងម្ខាងបីសរសៃ។

- ត្រចៀកពាក់រំយោលធ្លាក់ដល់ស្មា ។
- កមានពាក់សុរង ព្រមទាំងរំលេចដោយរំយោលក្បាច់រចនាតាមម៉ូតផ្សេងៗ ។
- ដើមដៃទាំងសងខាងមានពាក់ស្ទំដៃ ហើយកដៃពាក់កង ។
- លើទ្រូងឃើញមានសង្វារខ្វែងពីលើអាវនិងស្ទំចង្កេះមានរំយោលភ្ជាប់ទៅនឹងសំពត់ ។
- ជើងសំពត់មានរចនាជារាងកន្ទុយត្រី ជាយសំពត់នៅត្រង់ចង្កេះផ្នែកខាងឆ្វេងរចនាជាផ្ទត់អង្កាញ់ៗទម្លាក់ពីចង្កេះដល់ដី ។
- ជើងមានពាក់កង និងកងទ្រូដល់ដី ។

**+ អត្ថន័យនៃការសម្តែង**

- របាំអប្សរាមានចលនាសម្តែងមួយៗ បែបយឺតៗ តែជាតំណាងនូវស្ថានភាពសម្បូណ៌សប្បាយ ។
- បង្ហាញភាពផ្អែមល្ហែម ចិត្តសុខស្ងប់ អារម្មណ៍រួសរាយរាក់ទាក់បញ្ជាក់ភាពគ្មានកង្វល់ ។
- ធាតុដើមនៃរបាំអប្សរាសមស្របនឹងអត្ថន័យថារបាំទេពអប្សរ ឬទេវតាដែលគ្មានកង្វល់នឹងជីវិត ។
- ការសម្តែងរបាំអប្សរាបានក្លាយជាប្រពៃណីជាតិ ។
- របាំអប្សរាមានតម្លៃបង្កប់ក្នុងអារម្មណ៍ជនជាតិខ្មែរគ្រប់រូប តំណាងឱ្យដួងព្រលឹងជាតិខ្មែរ ។
- សិល្បករនៃរបាំអប្សរាពិតជាទន់ភ្លន់ សក្តិសមនឹងឬក-

ពាសុភាពរាបសាថ្លៃថ្នូរជាសុភាពនារីខ្មែរពិត។ ។

៤. លក្ខណៈជាតិសំខាន់ៗដែលឆ្លុះបញ្ចាំងតាមរយៈរបាំអប្សរា ៖

- ទឹកមុខញញឹមស្រស់រាយរាក់ទាក់ ទន់ភ្លន់សមសួនថ្លៃថ្នូរ ជាការបង្កប់ក្នុងចិត្តនូវសុខសន្តិភាព មិត្តភាព ភាតរភាព ភាពក្សេមក្សាន្ត។
- ចំពោះក្បាច់របាំគឺជា "ជីវិតលោកធាតុ" កើត ចាស់ ឈឺ ស្លាប់ តែមុននឹងស្លាប់ត្រូវបំពេញតួនាទីមួយដែលមិនអាចខ្វះបានគឺការបន្តពូជ។
- ចំពោះរុក្ខជាតិគឺសំដៅត្រួយ ស្លឹក ផ្កា ផ្លែ(ពេលផ្លែចាស់រួចទុំក៏បែកចេញជាគ្រាប់ធ្លាក់ចុះ ហើយផ្តើមដុះបានជាត្រួយ ស្លឹក ផ្កា ផ្លែ ជាបន្តបន្ទាប់)។
- ក្បាច់របាំបុរាណខ្មែរមិននិយមប្រើក្បាច់ដៃដោយឡែក ឬភ្នែកនិងកដោយឡែកដូចជាក្បាច់ឥណ្ឌាទេ គឺខ្មែរនិយមប្រើដងខ្លួនទាំងមូលតែម្តង ពោលគឺដៃ ជើង ចង្កេះ ក និងក្បាលប្តូកបញ្ចូលគ្នា។
- ខ្មែរអាចបង្កើតបានជាភាសាកាយវិការជំនួសភាសានិយាយបានស្ទើរគ្រប់ពាក្យ គ្រប់មនោសញ្ចេតនាដូចជា៖

+ យំ : ដៃជីបបាំងត្រឹមថ្ងាសឱនមុខបន្តិច(ជូតទឹកភ្នែក) ផ្សំនឹងទឹកមុខ )
+ សើចសប្បាយ អរ : ដៃជីបទាញចេញពីមាត់។
+ ស្រឡាញ់ : យកដៃទាំងពីរមកផ្តោបនឹងដើមទ្រូង។
+ ខឹង : យកដៃឆ្វេងរឹតទ្រូង ទន្ទ្រាំជើងតិចៗ សម្លក់សម្លឹងកន្ទុយភ្នែកឬមើលចំ។

៥. (សិស្សអាចប្រៀបធៀបរបាំអប្សរា ជាមួយរបាំប្រជាប្រិយណាមួយក៏បាន) ។ ឧទាហរណ៍ :

| របាំអប្សរា | របាំរាំវង់ |
|---|---|
| - ជារបាំក្បាច់បុរាណ<br>-ហាត់រៀនតាមក្បួនខ្នាតត្រឹមត្រូវ និងមានក្បាច់ច្រើន(ក្បាច់មូលដ្ឋាន ៤៥០០ក្បាច់)<br>-ឧបករណ៍ភ្លេងបែបបុរាណ<br>-មានទីតាំងពិសេសសំរាប់សម្តែង<br>-សម្លៀកបំពាក់និងគ្រឿងអលង្ការបុរាណ<br>-គេលេងក្នុងពេលប្រារព្ធពិធីបុណ្យជាតិ មហោស្រព សិល្បៈធំៗ និងពិធីទទួលស្វាគមន៍ ភ្ញៀវជាតិ និងអន្តរជាតិផ្សេងៗ ។ | -ជារបាំប្រជាប្រិយ<br>-មានក្បាច់រាំតិច ស្រួលចាំងាយហាត់រៀន<br>-ឧបករណ៍ភ្លេងចម្រុះ<br>-ទីតាំងសម្តែងសាមញ្ញ<br>-សម្លៀកបំពាក់តាមនិយមចូលចិត្ត<br>-គេលេងនៅពេលបុណ្យចូលឆ្នាំ ពិធីជប់លៀង អាពាហ៍ពិពាហ៍ ពិធីបុណ្យទានផ្សេងៗក្នុងគ្រួសារ ។ |

របាំទាំងពីរប្រភេទនេះ មានលក្ខណៈពិសេសក្នុងវប្បធម៌ជាតិដូចជា ៖

- ជាលក្ខណៈសម្គាល់និងអត្តសញ្ញាណជាតិ ។
- បានឆ្លុះបញ្ចាំងពីជីវភាពរបស់ប្រជារាស្ត្រខ្មែរដែលមានតាំងពីសម័យដើមមកម្លេះ ។
- បញ្ជាក់ពីអត្ថិភាពនៃកំណាក់កំណើតទឹកដី ជាតិសាសន៍ ប្រពៃ

ណី សិល្បៈជាដើម ។

- ជាសិល្បៈខ្មែរពិតប្រាកដ ដែលមានប្រវត្តិនិងមូលដ្ឋានជាក់លាក់តាំងពីរបៀបសម្តែងក្បាច់រាំ ឬអត្ថន័យនៃការសម្តែងជាដើម ។

៦. វិភាគល្បះ "ថ្វីត្បិតតែរបាំអប្សរា មានចលនាសំដែងមួយៗ បែបយឺតៗ... ប៉ុន្តែលក្ខណៈនេះបញ្ជាក់ច្បាស់នូវស្ថានភាពសម្បូណ៌សប្បាយនាសម័យកាលនោះ"។ ល្បះនេះមានន័យថាដោយសារតែប្រទេសកម្ពុជាជាប្រទេសមួយដែលភូមិសាស្ត្រអំណោយផលពីធម្មជាតិ មិនក្តៅមិនត្រជាក់ បានកំណត់ដល់ការរស់នៅរបស់ប្រជារាស្ត្រខ្មែរ សម្រួលដល់ការដាំដុះដំណាំកសិកម្មប្រកបទៅដោយភោគផលក្នុងស្ថានភាពសុខដុមរមនា ដែលមានជីវភាពសម្បូណ៌សប្បាយ ។ យ៉ាងនេះហើយបានជារបាំអប្សរាមានចង្វាក់រាំយឺតៗ កាយវិការមួយៗ ស្របទៅតាមផ្នត់គំនិតជាតិខ្មែរដែលតែងតែមានទឹកចិត្តស្ងប់ ស្លោះត្រង់ ទន់ភ្លន់ ប្រកបទៅដោយភាពស្ងប់ក្នុងចិត្ត និងរីករាយ ។



# របាំព្រះរាជទ្រព្យ

## សំណួរ

១. តើរបាំព្រះរាជទ្រព្យ គេអាចចែកតួអង្គសម្តែងជាប៉ុន្មានក្រុម? ចូររៀបរាប់លក្ខណៈសម្តែងនៃក្រុមនីមួយៗ។

២. តើអ្វីទៅដែលហៅថានិមិត្តរូប? តើនិមិត្តរូបសំខាន់ៗតាមរយៈកាយវិការ ការសម្តែងនៃតួអង្គក្នុងរបាំព្រះរាជទ្រព្យនេះ មានចំណុចពិសេសចំពោះលក្ខណៈជាតិយ៉ាងណាខ្លះ?

៣. បើនិយាយពីទម្រង់សិល្បៈខ្មែរ តើរបាំនេះស្ថិតក្នុងទម្រង់ទីប៉ុន្មាន? ហេតុដូចម្តេចបានជាអ្នកយល់បែបនេះ? ចូរអ្នកបកស្រាយដោយបញ្ជាក់ឧទាហរណ៍តាមការស្រាវជ្រាវរបស់អ្នក។

៤. ដោយផ្សារភ្ជាប់ទៅនឹងខ្លឹមសារនៃអត្ថបទខាងលើនេះ ចូរអ្នកធ្វើការប្រៀបធៀបរបាំព្រះរាជទ្រព្យ និងរបាំអប្សរា។

៥. ចូរអ្នកធ្វើការបកស្រាយពីអត្ថន័យនៃការប្រើប្រាស់ឧបករណ៍ភ្លេងខ្មែរ ក្នុងវប្បធម៌ខ្មែរដែលមានឧបករណ៍ : គងវង់ធំ សំភោរ ស្គរធំ ស្គរផ្ទា ស្រឡៃ ឈឹង ក្រាប់។

៦. តាមរយៈកាយវិការសម្តែង "ខ្ញុំ" និមិត្តរូប "ក្លិន" ប្រដូចទៅនឹង "ផ្កា" ក្នុងធម្មជាតិ។ តើនិមិត្តរូបនេះ បានផ្សារភ្ជាប់ទៅនឹងសោភ័ណនៃមនុស្សក្នុងសង្គមយ៉ាងណាខ្លះ?

## ចម្លើយ

១. របាំព្រះរាជទ្រព្យ គេអាចចែកតួអង្គសម្តែងជាបួនក្រុមគឺ៖

- ក្រុមនាង តំណាងឱ្យស្ត្រីភេទ
- ក្រុមនាយរោង តំណាងឱ្យបុរស
- ក្រុមយក្ស តំណាងឱ្យពពួកយក្ស ពួកមារ
- ក្រុមស្វា ពីដើមច្រើនតែកុមារី តែក្រោយមកជ្រើសរើសកុមារាវិញ ។

២. ដែលហៅថានិមិត្តរូប គឺជារូបតំណាង រូបសម្រាប់សំគាល់អ្វីមួយ ។

និមិត្តរូបសំខាន់តាមរយៈកាយវិការសម្តែងនៃតួអង្គក្នុងរបាំព្រះរាជទ្រព្យនេះមានចំណុចពិសេសចំពោះលក្ខណៈជាតិដូចតទៅ៖

- ម្រាមដៃនិងម្រាមចង្អុល ដៃជីបជាប់គ្នា ដែលតំណាងឱ្យត្រួយ ឬផ្កាក្រពុំ ។
- កាយវិការចង្អុល ឬការដុះពន្លក ។
- កាយវិការពត់កដៃ ដោយប្រើម្រាមដៃ៤ង មានសភាពដូចស្លឹក ។
- ម្រាមចង្អុលឬម្រាមកណ្តាលប្រឹង ងស្មើត ឯម្រាមបីទៀតឱនគួបគ្នា គឺការបែកមែក ។
- ម្រាមដៃទាំង៥បីជីបគឺជាផ្កា ។
- ម្រាមកណ្តាលនិងម្រាមមេឱនគួបគ្នា គឺជាផ្លែចាស់ បន្តិចទៀតនឹងត្រូវទុំជ្រុះ ។
- ពេលហោះ អ្នករបាំឆ្វេលចុះឡើងលើកដៃពត់កោងទៅលើនិងម្ខាងទៀតង កោងត្រង់ក្លួយដៃ ដែលជាការប្រឹងហាត់

ពត់ខ្លាំងណាស់ទើបមានលក្ខណៈល្អបណ្ដាច់។

\+ និមិត្តរូបតាមរយៈកាយវិការនៃការសម្ដែងនេះជាតំណាងឱ្យលក្ខណៈជាតិខ្មែរក្នុងការដាំដុះលើវិស័យកសិកម្មដែលជាប្រពៃណីរបស់ដូនតាយើងតាំងពីដើមរៀងមក។

៣. បើនិយាយពីទម្រង់សិល្បៈខ្មែរ របាំនេះស្ថិតក្នុងទម្រង់ទី៥ ក្នុងចំណោមសិល្បៈទាំង៧ គឺ៖

- ស្ថាបត្យកម្ម
- ចម្លាក់
- គំនូរ
- តន្ត្រី
- របាំ
- អក្សរសិល្ប៍
- ភាពយន្ត

៤. ប្រៀបធៀបរបាំព្រះរាជទ្រព្យ និងរបាំអប្សរាក្នុងខ្លឹមសារនៃអត្ថបទខាងលើ៖

\+ **របាំព្រះរាជទ្រព្យ**

- ជាទម្រង់សិល្បៈសក្ការៈ មានវ័យចំណាស់ដ៏យូរលង់មកហើយ។
- មានតួនាទីរាំឧទ្ទិសដល់អាទិទេព ឬរ៉ាថ្វាយទេវៈរាជា។
- តួអង្គមានបួនក្រុម (នាង នាយរោង យក្ស ស្វា)។
- កាយវិការនៃការសម្ដែងប្រព្រឹត្តទៅជានិមិត្តរូប ដែលមាន៖

+ ម្រាមដៃនិងម្រាមចង្អុល ដៃជីបជាប់គ្នា ដៃលតំណាងឱ្យត្រួយ ឬផ្កាក្រពុំ។

+ កាយវិការបង្អុល ឬការដុះពន្លក។

+ កាយវិការពត់កដៃ ដោយប្រើម្រាមដៃ៤ង មានសភាពដូចស្លឹក។

+ ម្រាមចង្អុលឬម្រាមកណ្ដាលប្រើង ងស្មើត ឯម្រាមបីទៀតឱនគួបគ្នា គឺការបែកមែក។

+ ម្រាមដៃទាំង៥បីជីបគឺជាផ្កា។

+ ម្រាមកណ្ដាលនិងម្រាមមេឱនគួបគ្នា គឺជាផ្លែចាស់បន្តិចទៀតនឹងត្រូវទុំជ្រុះ។

+ **របាំអប្សរា**

- ឧប្បត្តិកឡើងដោយព្រះមហាក្សត្រីយានីយាងមកធ្វើទស្សនកិច្ចនៅសាលាបឋមសិក្សាសុធារស។ នាយិកាដែលបានរៀបចំពិធីសិល្បៈកុមារបានកាត់ក្រដាសធ្វើជាមកុដពាក់ដូចគ្នានឹងមកុដអប្សរាឆ្លាក់ជាប់នឹងជញ្ជាំងប្រាសាទអង្គរវត្តបេះបិទ។
- ព្រះមហាក្សត្រីយានីផ្ដួចផ្ដើមគំនិតបង្កើតរបាំនេះឡើងហើយប្រសិទ្ធនាមថា "របាំអប្សរា"។
- របាំអប្សរានេះជាពាក្យផ្សំខ្មែរនឹងសំស្ក្រឹត មានន័យថារបាំទេវៈ របាំទេពអប្សរ ឬរបាំទេវតា។
- បើនិយាយពីគ្រឿងតុបតែងកាយ មកុដអប្សរានិងក្បាច់រាំជាដើម សុទ្ធតែបានចម្លងគំរូអប្សរានៅតាមជញ្ជាំង

អង្គរវត្តទាំងអស់ ។

- មានតម្លៃនិងរក្សាចរិតលក្ខណៈជាខ្មែរ ។
- តាមការសង្កេតមកុដអប្សរាដែលមានតាមជញ្ជាំងអង្គរវត្តត្រូវមានកំពូលប្រាំពីរ ។
- នៅអមត្រចៀក គេរចនាសក់ក្រងម្នាង១បីសរសៃ ត្រចៀកពាក់រំយោលធ្លាក់ដល់ស្មា កមានពាក់សុរង ។
- ដើមដៃទាំងសងខាងពាក់ស្ទំដៃ ហើយកដៃពាក់កង ។
- លើទ្រូងឃើញមានសង្វារខ្វែងពីលើអាវនិងស្ទំចង្កេះ មានរំយោលភ្ជាប់ទៅនឹងសំពត់ ។
- ជើងសំពត់មានរចនាជារាងកន្ទុយត្រី ជាយសំពត់នៅត្រង់ចង្កេះផ្នែកខាងឆ្វេងរចនាជាផ្នត់អង្កាញ់១ទម្លាក់ពីចង្កេះដល់ដី ។
- ជើងមានពាក់កង និងកងទ្រូដល់ដី ។
- ប្រគំអមជាមួយបទភ្លេងមហោរីព្រះរាជទ្រព្យដែលមានចង្វាក់រាំទន់ភ្លន់ ។
- កាយវិការទន់ល្វាសល្វន់ គ្រួបផ្សំនឹងដៃចាក់ក្បាច់រាំ ជើងលើកដាក់ប្រវាសម្តង១ៗ ។
- ក្បាលធ្វើចលនារាំងាករេឆ្វេងស្តាំចុះឡើង១ ។
- ម្រាមដៃអប្សរា ងខ្ចង់ ចង្កេះរស់រវើកសមនឹងគូទរាងងស្មើត ។
- របាំអប្សរាមានចលនាសម្តែងមួយ១ បែបយឺត១ តែជាតំណាងនូវស្ថានភាពសម្បូណ៌សប្បាយ ។

- បង្ហាញភាពផ្អែមល្ហែម ចិត្តសុខស្ងប់ អារម្មណ៍រីករាយ រាក់ទាក់បញ្ជាក់ភាពគ្មានកង្វល់ ។

ទោះបីជារបាំទាំងពីរមានលក្ខណៈសម្តែងមិនដូចគ្នាទាំងស្រុងក៏ពិតមែន តែវាសុទ្ធតែជានិមិត្តរូប ជាតំណាងឱ្យវប្បធម៌ជាតិពិតប្រាកដ ។

៥. អត្ថន័យនៃការប្រើប្រាស់ឧបករណ៍ភ្លេងខ្មែរ ក្នុងវប្បធម៌ខ្មែរដែលមានឧបករណ៍ ៖

- **គងវង់ធំ** ៖ ជាឧបករណ៍មួយប្រភេទដែលមាននៅក្នុងវង់ភ្លេងពិណពាទ្យ ។ វាជាប្រភេទឧបករណ៍គោះដំដើម្បីសូរសំនៀង ។
- **សំភោរ** ៖ ជាឧបករណ៍តន្ត្រីខ្មែរមួយប្រភេទដែលត្រូវបានគេចាត់ចូលទៅក្នុងពពួកក្រុមគោះដំ ។ ឧបករណ៍នេះមានវត្តមានជានិច្ចនៅក្នុងវង់ភ្លេងពិណពាទ្យ ។ សំភោរជាឧបករណ៍តន្ត្រីមួយប្រភេទដែលមានតួនាទីសំខាន់ក្នុងវង់ភ្លេង ពីព្រោះវាជាអ្នកកំណត់ការចាប់ផ្តើមក្នុងពេលប្រគុំម្តងៗ (ចេញមុនឧបករណ៍ដទៃទៀត) ។ វាកំណត់ឱ្យចង្វាក់១ជាន់ ២ជាន់ ឬ៣ជាន់ ដល់បទនានា វាជាមេតំណាងឱ្យឧបករណ៍ដទៃទៀតក្នុងការអុជទៀនធូបឧទ្ទិសដល់ឧបការគុណនៃគ្រូធំតូចទាំងឡាយ ។
- **ស្គរធំ** ៖ ជាឧបករណ៍តន្ត្រីបុរាណមួយប្រភេទដែលមានតាំងពីយូរលង់ណាស់មកហើយ ។ វាមានវត្តមានជានិច្ចនៅក្នុងវង់ភ្លេងពិណពាទ្យ ។ ឧបករណ៍ស្គរធំនេះមានពីរដែលដាក់

ទន្ទឹងគ្នានៅក្នុងពេលសំដែង។ ស្គរធំជាប្រភេទឧបករណ៍នៅក្នុងវង់ភ្លេងពិណពាទ្យ។ ការរៀបចំសំដែងនៅក្នុងវង់ភ្លេងពិណពាទ្យចាំបាច់ត្រូវដាក់ស្គរធំទាំងគូ និងសំភោរនៅខាងមុខឧបករណ៍ដទៃទៀតក្នុងវង់ភ្លេងទាំងមូល ពីព្រោះសំនៀងរបស់ស្គរធំ គឺជាសំនៀងមួយដែលខ្លាំង ហើយសន្ធាប់ជាងគេនៅក្នុងវង់ភ្លេងពិណពាទ្យ។ វាជាប្រភេទឧបករណ៍គោះដំដើម្បីបង្កើតសូរសំនៀង។

- ស្គរថ្ងា ឬស្គរក្លងខែក : វាជាប្រភេទឧបករណ៍គោះដំដើម្បីបង្កើតសូរសំនៀង។ ជាស្គរមួយប្រភេទដែលមានរាងវែងស្មើ ដាសស្បែកទាំង២ខាង។
- ស្រឡៃ : ជាឧបករណ៍តន្ត្រីប្រើខ្យល់ផ្លុំ ដើម្បីបង្កើតសូរសំនៀង។ ស្រឡៃចែកចេញជាពីរគឺស្រឡៃតូច និងស្រឡៃធំ។ វាជាប្រភេទឧបករណ៍នៅក្នុងវង់ភ្លេងពិណពាទ្យ ហើយមានតាំងពីមុនសម័យអង្គរមកម្លេះ ព្រមទាំងជាឧបករណ៍មានកម្រិតខ្ពស់បំផុតដែលមិនសូវមានអ្នកចេះច្រើន ព្រោះឧបករណ៍ទាំងពីរនេះមានការលំបាកប្រើខ្យល់ ប្រើអណ្តាត និងប្រើម្រាមដៃ។
- ឈិង : ជាឧបករណ៍តន្ត្រីខ្មែរមួយប្រភេទដែលត្រូវបានគេចាត់ចូលទៅក្រុមនៃពពួកគ្រឿងគោះទង្គិចឱ្យកើតជាសូរសំនៀង។
- ក្រាប់ : ជាឧបករណ៍ភ្លេងមួយ សម្រាប់គោះបន្ទរចង្វាក់ដូចជាឧបករណ៍ឆាប ឈឹង ប៉ាន់ រឡា។

៦. តាមរយៈកាយវិការសម្តែង "ខ្ញុំ" និមិត្តរូប "ក្លិន" ប្រដូចទៅនឹង "ផ្កា" ក្នុងធម្មជាតិ។ និមិត្តរូបនេះបានផ្សារភ្ជាប់ទៅនឹងសោភ័ណនៃមនុស្សក្នុងសង្គមដូចតទៅ ៖

- ផ្កា : តំណាងឱ្យផ្នែកខាងក្រៅ គឺរូបរាងនៃមនុស្សដែលមានពណ៌សម្បុរផ្សេងៗ ឬហាក់ដូចជាជាតិសាសន៍លាយចម្រុះលើលោកយើងនេះ ។
- ក្លិន : តំណាងឱ្យផ្នែកខាងក្នុង ដែលស្តែងចេញតាមរយៈការប្រព្រឹត្តរបស់បុគ្គលម្នាក់ៗ គឺទាមទារឱ្យការប្រព្រឹត្តនោះបានត្រឹមត្រូវប្រកបទៅដោយវិចារណៈ ឈរលើឧត្តមគតិ កិត្តិយស ឬសតិសម្បជញ្ញៈជាដើម ។
- ដូច្នេះសោភ័ណនៃមនុស្សដែលតំណាងដោយផ្កា ពិតជាមានអត្ថន័យក្នុងការបកស្រាយអំពីខ្លឹមសារជីវិតដ៏មានតម្លៃ គឺមិនអាស្រ័យតែរូបសម្បត្តិនោះទេ។ បានសេចក្តីថាសោភ័ណនៃមនុស្សតំណាងដោយផ្កា ត្រូវផ្តើមចេញពីរូបសម្បត្តិផង និងចរិយាសម្បត្តិផង ពោរពេញទៅដោយសីលធម៌ និងការទទួលខុសត្រូវ នោះទើបជាតម្លៃពិតប្រាកដរបស់មនុស្ស។

**សម្គាល់** : **របាំព្រះរាជទ្រព្យ** បានចុះបញ្ជីជាសម្បត្តិបេតិកភណ្ឌវប្បធម៌អរូបីពិភពលោកកាលពីថ្ងៃទី **៧ វិច្ឆិកា ២០០៣** ។



# ពិធីចូលម្លប់

## សំណួរ

១. តាមរយៈខ្លឹមសារនៃអត្ថបទនេះ តើពិធីចូលម្លប់មាននៅក្នុងខេត្តណាខ្លះ?

២. បើតាមប្រពៃណី តើគេត្រូវឱ្យកូនស្រីនៅវ័យណាដែលត្រូវចូលម្លប់? ហើយរយៈពេលនៃការចូលម្លប់នេះមានការឯកភាពគ្នាឬទេ? ចូររៀបរាប់។

៣. ចូរប្រាប់ពីគ្រឿងរណ្តាប់និងអត្ថន័យនៃគ្រឿងរណ្តាប់នៃពិធីចូលម្លប់ដែលគេនិយមប្រារព្ធធ្វើនៅតាមខេត្តនីមួយៗ។

៤. តើពេលដែលនៅក្នុងម្លប់ គេបានប្រកាន់ត្រណមយ៉ាងណាខ្លះ?

៥. តើស្រូវកញ្ចើតំណាងឱ្យអ្វី? ហើយរណ្តាប់ស្រូវកញ្ចើនេះមាននាទីសំខាន់អ្វីខ្លះចំពោះពិធីចូលម្លប់?

៦. ចូរអ្នកបង្ហាញពីអត្ថន័យនៃពាក្យឬកន្សោមពាក្យ "មេម្លប់ ស្រាស្លឹកម្លូ"។

៧. តើអ្នកយល់យ៉ាងណាចំពោះប្រពៃណីចូលម្លប់របស់ជនជាតិខ្មែរ?

## ចម្លើយ

១. តាមរយៈខ្លឹមសារនៃអត្ថបទនេះ ពិធីចូលម្លប់មាននៅក្នុង៖

- ខេត្តកោះកុង ស្រុកស្រែអំបិល
- ខេត្តកំពង់ចាម ស្រុកបាធាយ

- ខេត្តសៀមរាប ស្រុកសូទ្រនិគម

២. បើតាមប្រពៃណី គេត្រូវឱ្យកូនស្រីចូលម្លប់៖

- ខេត្តកោះកុង ស្រុកស្រែអំបិល : កូនស្រីមានអាយុរហូតដល់១៨ឆ្នាំ គឺគ្រប់ការច្រើនឆ្នាំមកហើយ ។
- ខេត្តកំពង់ចាម ស្រុកបាធាយ : កូនស្រីអាយុហួសវ័យដែលទើបនឹងមានរដូវបន្តិចបន្តួច ។
- ខេត្តសៀមរាប ស្រុកសូទ្រនិគម : កូនស្រីមិនឱ្យយូរ គឺក្រោយពីកូនស្រីមានរដូវដំបូងភ្លាម ។

ហើយរយៈពេលនៃការចូលម្លប់នេះមានការឯកភាពគ្នាទេគឺ៖

- ស្រុកស្រែអំបិល ខេត្តកោះកុង រយៈពេលដែលនៅក្នុងម្លប់ហាក់ដូចជាគ្រាន់តែជាឧបកិច្ចប៉ុណ្ណោះ គឺយ៉ាងយូរបំផុតត្រឹមមួយសីល គឺពីសីលមួយទៅសីលមួយទៀត រយៈពេល៧-៨ថ្ងៃ ឬអាចត្រឹមតែ២ថ្ងៃផងក៏មានដែរ ។
- ស្រុកបាធាយ ខេត្តកំពង់ចាម រយៈពេលនៅក្នុងម្លប់ច្រើនវែងជាងនេះ មាន២-៣ខែជាដើម ឬយូរជាងនេះទៀតផង ។
- ស្រុកសូទ្រនិគម ខេត្តសៀមរាប រយៈពេលដែលនៅក្នុងម្លប់គឺមួយខែជាមធ្យម ។

៣. គ្រឿងរណ្ដាប់និងអត្ថន័យនៃគ្រឿងរណ្ដាប់នៃពិធីចូលម្លប់ដែលគេនិយមប្រារព្ធធ្វើនៅតាមខេត្តនីមួយៗ៖

- រណ្ដាប់ទី១ : គឺស្រូវកញ្ចើ រណ្ដាប់នេះពុំមាននាទីអ្វីពិសេសខ្លាំងនៅតំបន់សូទ្រនិគមក៏ពិតមែន តែនៅតំបន់ពីរទៀតនោះគឺគួរឱ្យចាប់អារម្មណ៍ពិតប្រាកដ ។ ក្នុងពិធីកាត់សក់

បង្អក់ឆ្អប ហើយតមកក្នុងពិធីកោរជុក យើងឃើញហើយថាគេឱ្យសាមីខ្លួនអង្គុយនៅលើកញ្ចើនោះក្នុងកិច្ចសំខាន់ៗខ្លះៗ។ នៅទីនេះវិញប្រការដែលគួរឱ្យសង្កេតកាន់តែមានច្រើនទៅទៀត។ ក្រៅពីវត្ថុនានា មានទៀនធូបជាដើមដែលគេដាក់លើស្រូវកញ្ចើនោះ គេមានដាក់ "ត្រល់" (បើនៅស្រុកស្រែអំបិលមានវត្ថុដូចគ្នាដែរ តែគេហៅថា "តក់") មួយទៀត។ ក្នុងត្រល់នោះគេពុំដាក់ស្រូវទេ គឺគេយកអង្ករទៅញាត់ឱ្យពេញ ទើបគេយកក្រដាសអ្វីមួយទៅរុំបិទមាត់ឱ្យជិត។ មិនតែប៉ុណ្ណោះ គេយកចិញ្ចៀនមួយវង់ទៅចងជាមួយគ្នានោះ។ គេសន្មតថាមុននឹងចេញពីម្លប់ បើស្រាយពីក្រដាសមើលទៅឃើញថាអង្ករចុះស្រក មានន័យថាម្ចាស់ខ្លួនបានប្រព្រឹត្តអំពើអនាចារអ្វីមួយពេលដែលនៅក្នុងម្លប់នោះដូចជាមានប្រុសឈ្លោលជាដើម។ នេះជាការឧបកិច្ចសុទ្ធសាធ ព្រោះអង្ករពុំអាចស្រកឡើយ។ ប្រការសំខាន់ទី២ គឺចាស់ទុំមានឪពុកម្ដាយ ឬអាចារ្យជាដើមនិយាយទៅរកស្រូវកញ្ចើនោះហាក់ដូចជាទៅកាន់មនុស្សម្នាក់ឬទៅរកភូតអ្វីមួយ។ តាមពិតទៅគឺគេគិតថាកញ្ចើរណ្ដាប់នេះជាភូតអ្វីមួយមែន ត្បិតគេហៅថា "មេម្លប់" ទោះបីជាដឹងថាមានរូបរាងឬឥតរូបរាងក៏ដោយ។ រាល់កិច្ចសំខាន់ៗអ្វីមួយដែលត្រូវធ្វើ គេតែងតែប្រកាសប្រាប់មេម្លប់ ពោលគឺនិយាយប្រាប់ស្រូវកញ្ចើនោះឱ្យបានដឹងឮសិន។

- រណ្ដាប់ទី២ : គឺកូនចេកនិងកូនអំពៅ។ ថ្វីត្បិតតែនៅស្រុក

បាធាយពុំឃើញមានប្រើ តែនៅស្រែអំបិលនិងស្លូទ្រនិគម គេចាត់ទុកថាជារណ្តាប់មួយដ៏សំខាន់ ។ ចេកនិងអំពៅនេះ ត្រូវដាំនៅក្នុងបន្ទប់កូនស្រីពេលផ្តើមចូលម្លប់ ហើយត្រូវនៅក្នុងម្លប់នោះមួយរយៈពេលដែលកូនស្រីនោះនៅដែរ ។ សព្វថ្ងៃពុំឮគេបកស្រាយរកន័យអ្វីវែងឆ្ងាយទេ គ្រាន់តែគេនិយាយថាស្នងឱ្យកូនស្រីនោះឯង ។ តែយ៉ាងណាក៏ដោយ ចេកនិងអំពៅជានិមិត្តរូបនៃព្រលឹង ។

- រណ្តាប់ទី៣ : គឺត្បាល់ ត្បាល់នេះពុំឃើញមានប្រើទេនៅស្រុកស្លូទ្រនិគម ប៉ុន្តែចំពោះនៅស្រុកពីរទៀតនោះវិញ គេទុកថាសំខាន់ ។ យើងពុំហ៊ានអះអាងថាត្បាល់នៅស្រុកបាធាយមានន័យដូចគ្នានឹងត្បាល់ប្រើនៅស្រែអំបិលឡើយ ត្បិតឃើញយកទៅប្រើនៅក្នុងកិច្ចពីរដែលហាក់ដូចជាមានន័យខុសគ្នា ។ នៅបាធាយគេប្រើត្បាល់ថ្មតូចល្មមសម្រាប់បុកល័ក្តនៅពេលយប់ ចំណែកនៅស្រែអំបិលវិញ ត្បាល់នោះគឺត្បាល់ឈើធំ ដែលធម្មតាគេប្រើសម្រាប់បុកស្រូវជាដើម ដែលពេលនោះគេទុកឧបកិច្ចទម្រាប់ចោះត្រចៀកក្មេងស្រី បន្ទាប់ពីសំពះព្រះអាទិត្យហើយនៅពេលព្រហាម ។ តែទោះជាយ៉ាងនេះក្តី ក៏យើងនៅតែសង្ស័យថា ត្បាល់ទាំងពីរនេះអាចមានន័យអ្វីមួយចូលគ្នាឬស្របគ្នាដែរ ។ បើត្បាល់បុកល័ក្តនោះសម្រាប់តែបុកល័ក្តសុទ្ធសាធ តើចាំបាច់យកចិញ្ចៀនមួយវង់ទៅចងភ្ជាប់ធ្វើអ្វី? រីឯការចោះត្រចៀកវិញ ទោះជាឧបកិច្ចក៏ដោយ ហេតុអ្វីក៏យកតែម

ត្បាល់ធ្វើជាទ្រនាប់? ម្តេចក៏មិនយកវត្ថុរឹងផ្សេង មានផ្រុញជាដើមមកប្រើ? តាមស្មានមើលទៅប្រហែលពុំមែនជាការចៃដន្យឡើយដែលគេប្រើត្បាល់ ព្រោះជាទូទៅ យើងដឹងថាត្បាល់និងអង្រែមានន័យទាក់ទងនឹងភេទ ក៏អាចថាធាតុញីនិងធាតុឈ្មោល ត្បិតពិធីឆ្លងវ័យជាទូទៅតែងតែទាក់ទងនឹងរឿងនេះ។ គួរកុំភ្លេចថា ពេលខ្លះស្លឹកម្លូក៏គេសន្មតថាស្នងឱ្យ "ខ្វាស" នៃមនុស្សស្រីដែរ។ រីឯចិញ្ចៀនវិញ ក៏ពុំខុសអ្វីពីចិញ្ចៀនដែលគេចងភ្ជាប់ទៅនឹងគ្រល់ដែរ គឺសុទ្ធសឹងមានន័យដូចគ្នា។

៤. ពេលនៅក្នុងម្លប់ គេបានប្រកាន់ត្រណមដូចតទៅ៖

- ម្ហូបអាហារដែលទទួលទានហៅថា "បាយបួស" ពុំមានសាច់ ឬត្រីអ្វីឡើយ។
- ក្រៅពីបាយឬបបរ ច្រើនតែសណ្តែក ល្ង សៀង អំបិល បន្លែ និងផ្លែឈើ។
- ហាមឃាត់ការទទួលទានផុតពីថ្ងៃត្រង់ទៅដូចជាព្រះសង្ឃដែរ។
- ការជាំស្លគឺម្ចាស់ខ្លួនធ្វើដោយខ្លួនឯងក្នុងបន្ទប់នោះតែម្តង។
- មិនឱ្យក្មេងនោះប៉ះឬឃើញពន្លឺព្រះអាទិត្យទេ។
- ពេលយប់ ដើម្បីសំអាតរាងកាយប្រចាំថ្ងៃ គប្បីគេចពុំឱ្យមនុស្សប្រុសឃើញខ្លួនឡើយ។

៥. ស្រូវកញ្ចើតំណាងឱ្យមេម្លប់។ រណ្តាប់ស្រូវកញ្ចើនេះមាននាទីចំពោះពិធីចូលម្លប់ដូចតទៅ៖

- ជាអ្នកជួយបំពេញកិច្ចនៅក្នុងពិធីទៅតាមប្រពៃណី ។
- ជួយសម្រេចជាប្រយោជន៍ដល់អ្នកត្រូវធ្វើកិច្ចក្នុងពិធីចូលម្លប់ ។
- ជានិមិត្តរូបដើម្បីផ្សងរកភាពស្អាតស្អំចំពោះអ្នកត្រូវចូលម្លប់ ។
- ជាកសិណឬតំណាងឱ្យមេម្លប់ ដែលមានតួនាទីជាអ្នកទទួលដឹងឮរាល់ការធ្វើកិច្ចការនៃពីធីចូលម្លប់ ។

៦. អត្ថន័យនៃពាក្យឬកន្សោមពាក្យ៖

- មេម្លប់ : គឺជាស្រូវកញ្ចើជាអ្នកតំណាងឱ្យអ្នកបំពេញកិច្ចក្នុងពិធីចូលម្លប់ ហើយហាក់ដូចជាភូតមួយ( ខ្មោច បិសាច) មាននាទីជាអ្នកទទួលដឹងឮរាល់គ្រប់កិច្ចការដែលគេធ្វើកិច្ចក្នុងពិធីចូលម្លប់ ព្រោះអ្នកធ្វើកិច្ចតែងតែប្រកាសប្រាប់មេម្លប់ ពោលគឺនិយាយប្រាប់ស្រូវកញ្ចើនោះឱ្យបានដឹងឮជាមុនសិន ។
- ស្រា : មាននាទីសំខាន់ដោយគេពុំត្រឹមតែច្រួចឱ្យដូនតាពេលដែលគេប្រកាសក្នុងពិធីចូលម្លប់ប៉ុណ្ណោះទេ គឺគេត្រូវតែដកង់ក្រេបម្នាក់បន្តិចៗតៗគ្នា ។ ផុតពីនោះទៅ គេនាំនាងជាម្ចាស់ខ្លួនព្រមទាំងក្មេងស្រីម្នាក់ទៀតដែលកំដរហើយដែលគេឧបកិច្ចជាប្ដីនោះឱ្យមកអង្គុយនៅកណ្ដាលរង្វង់ចាស់ទុំនិងបងប្អូនជិតខាងដែលមកជួយដឹងឮ ។ ម្ចាស់ខ្លួនក៏ត្រូវតែក្រេបស្រា ចំណែកក្មេងស្រីកំដរនោះក៏គេចពុំបានដែរ ។ ស្រានៅទីនេះពុំមានន័យថាជាភេសជ្ជៈធម្មតា

ឡើយ ហើយការដែលច្រូចស្រាឱ្យខ្មោចផងនិងមនុស្សផឹកខ្លួនឯងផងនោះ ជាការត្រូវរំរូវដឹងឮព្រមព្រៀងជាមួយគ្នារវាងមនុស្សនិងខ្មោច។ ដូច្នោះហើយបានជាពុំមាននរណាគេចមិនផឹកស្រាបានក្នុងកិច្ចនេះ។

- ស្លឹកម្លូ : គេសន្មតថាស្នងឱ្យ "ខ្នាស" ឬអង្គជាត ឬកេរភេទនៃមនុស្សស្រី។

៧. ចំពោះប្រពៃណីចូលម្លប់របស់ជនជាតិខ្មែរខ្ញុំយល់ថាជាការបង្ហាញពីវប្បធម៌ប្រពៃណីជាតិខ្មែរ ដែលបុព្វបុរសបានបន្សល់ទុកតាំងពីបុរាណកាលមកម្ល៉េះ។ វាធ្វើឱ្យយើងស្គាល់ពីអត្តសញ្ញាណជាតិនិងមានមោទនភាពចំពោះវប្បធម៌ជាតិដែលពុំមែនចម្លងពីជាតិសាសន៍ណាមួយឡើយ។

មេរៀនទី ៧

# ប្រពៃណីទំនៀមទម្លាប់



## ប្រពៃណីខ្មែរនាសម័យអាណានិគមនិយម

### សំណួរ

១. ចូរអ្នកបង្ហាញពីអត្ថន័យសំខាន់ៗដែលទាក់ទងនឹងប្រពៃណីទំនៀមទម្លាប់ខ្មែរ :

- តួនាទីសាមីខ្លួនខាងប្រុសមុនពេលមង្គលការ ។
- តួនាទីឪពុកម្ដាយខាងប្រុស ខាងស្រីមុនពេលមង្គលការ ។

២. តើទស្សនៈរបស់ពូស្វាយមីងពតអាចចាត់ទុកជាទស្សនៈតាងឱ្យមាតាបិតាខ្មែរបានដែរឬទេ? ព្រោះអ្វី? ហើយទស្សនៈនេះជាទស្សនៈវិជ្ជមាន ឬអវិជ្ជមាន?

៣. បើតាមទស្សនៈរបស់អ្នកនិពន្ធបានបង្ហាញឱ្យឃើញពីផ្លូវអាណាចក្រនិងពុទ្ធចក្រ ។ តើការបង្ហាញបែបនេះបានជះឥទ្ធិពលទៅលើផ្នត់គំនិតខ្មែរយ៉ាងណាខ្លះ? ហេតុអ្វី?

៤. បើផ្អែកទៅតាមដំណើររឿងនេះ គេអាចចាត់ទុកជាអក្សរសិល្ប៍បែបអ្វី? ចូរអ្នករកអំណះអំណាងគាំទ្រ ។

៥. ចូរបង្ហាញពីលក្ខណៈជាតិ លក្ខណៈមនុស្ស លក្ខណៈសង្គម តាមរយៈរឿងខាងលើនេះ ។

៦. ចូរអ្នកធ្វើការសិក្សាពីសង្គមបរិយាកាស និងគំនិតអ្នកនិពន្ធក្នុងការលើកយកតថភាពនាសម័យអាណានិគមមកឆ្លុះបញ្ចាំង ។

## ចម្លើយ

១. អត្ថន័យសំខាន់ៗដែលទាក់ទងនឹងប្រពៃណីទំនៀមទម្លាប់ខ្មែរ ៖

- តួនាទីសាមីខ្លួនខាងប្រុសមុនពេលមង្គលការ : កូនប្រុសត្រូវទៅនៅបម្រើផ្ទះកូនស្រីរហូតដល់ថ្ងៃរៀបការ ។
- តួនាទីឪពុកម្តាយខាងប្រុស ខាងស្រីមុនពេលមង្គលការ ៖

+ **ម្ដាយឪពុកខាងប្រុស**

- ចាត់មនុស្សស្រីម្នាក់ មិនអភ័ព្វគូឱ្យចូលចែចូវ ។
- រកហោរាមើលវេលាល្អទៅស្តីដណ្ដឹងកូនស្រីលោកមេបា
- បន្ទាប់មកពឹង (អ្នកផ្លូវចៅមហា) ឱ្យទៅស្ដីដណ្ដឹងកូនស្រីលោកមេបា ដោយមានស្លា ម្លូ និងរណ្ដាប់ផ្សេងៗ ព្រមទាំងមាននំចំណី ផ្លែឈើកំដរដៃ គ្រឿងមាសពេជ្រ និងសម្លៀកបំពាក់ទៅជូនខាងស្រី ហើយនាំកូនប្រុសទៅជាមួយផង ។
- អញ្ជើញញាតិ (យាយតា មាមីង បងប្អូន...) ឱ្យមកជួយដឹងឮក្នុងការស្ដីដណ្ដឹងនេះផង ។
- រៀបចំជំនូនជូនលោកមេបាខាងស្រីឱ្យសមស្របតាមឋានៈខ្លួននិងជំនួង ។

+ **ម្ដាយឪពុកខាងស្រី**

- រៀបចំផ្ទះសំបែងរបស់ខ្លួនឱ្យបានសមរម្យ

• អញ្ជើញចាស់ព្រឹទ្ធាចារ្យណាម្នាក់មកធ្វើជា "លោក មេបា" ឱ្យធ្វើជាតំណាងនិយាយជាមួយខាងប្រុស (អ្នកផ្លូវចៅមហា)។

• អញ្ជើញភ្ញៀវដែលត្រូវអញ្ជើញ ដូចជាជីដូនជីតា មា មីង បងប្អូន.. ឱ្យសមតាមកាលៈទេសៈនិងធនធាន។

• រៀបភោជនាហារជូនភ្ញៀវពិសា។

+ **ម្តាយឪពុកទាំងសងខាង** : បន្ទាប់ពីស្តីដណ្តឹងរួចរាល់ហើយគេត្រូវរកអាចារ្យគន់គូរកថ្ងៃពេលារៀបការ។ អ្នកផ្លូវត្រូវយកក្រដាសកំណត់ពេលវេលានិងរណ្តាប់ទៅជូនមេបាខាងស្រី រួចធ្វើពិធីស៊ីស្លាកំណត់។

• នៅទីបញ្ចប់អ្នកផ្លូវសុំឱ្យមេបាបង្ហាប់គ្រឿងបណ្ណាការសព្វសារពើ ដែលត្រូវជូននិងប្រើប្រាស់ក្នុងឱកាសធ្វើមង្គល។

២. ទស្សនៈរបស់ពូស្វាយមីងពតអាចចាត់ទុកជាទស្សនៈតាងឱ្យមាតាបិតាខ្មែរបាន ព្រោះជាទស្សនៈដែលផ្តល់សិទ្ធិសេរីភាពឱ្យកូនស្រីក្នុងការរើសគូស្រករដោយខ្លួនឯង គាត់មិនបង្ខិតបង្ខំឱ្យកូនរៀបការតាមចិត្តគាត់ឡើយ។ នេះជាទស្សនៈដែលត្រូវបានគេទទួលស្គាល់ជាទូទៅនៅសម័យបច្ចុប្បន្ន។

ហើយទស្សនៈនេះយើងចាត់ទុកជាទស្សនៈវិជ្ជមាន។

៣. តាមទស្សនៈរបស់អ្នកនិពន្ធបានបង្ហាញឱ្យឃើញពីផ្លូវអាណាចក្រនិងពុទ្ធចក្រ។ ការបង្ហាញបែបនេះគឺចង់ឆ្លុះបញ្ចាំងឥទ្ធិពលនៃជំនឿដែលជិតជាប់ក្នុងផ្នត់គំនិតប្រជាជនខ្មែរ។

+ **ការបង្ហាញតាមផ្លូវពុទ្ធចក្រគឺ៖**

- គ្មានជំនឿលើខ្លួនឯង (ជឿលើព្រេងវាសនា)
- មានបាបកម្មពីជាតិមុន (សំដីអាចារ្យឆេង)
- អស់សង្ឃឹមក្នុងជីវិតរំលឹកដល់គុណបុណ្យព្រះរតនត្រៃ (តាង៉ែត យាយអ៊ុក នៅពេលយន្តហោះទម្លាក់គ្រាប់បែប នៅវត្តប្រលោម...)

**+ ការបង្ហាញតាមផ្លូវអាណាចក្រគឺ៖**

- មិនត្រូវអណ្តែតអណ្តូងនឹងរឿងមិនពិត
- ជាតិមុនកើតជាអ្វី ហើយជាតិក្រោយជាអ្វី
- រាស្ត្រក្រីក្រសព្វថ្ងៃ គឺត្រូវពួកបារាំង ជប៉ុនជិះជាន់...

+ ការបង្ហាញផ្លូវទាំងនេះ គឺអ្នកនិពន្ធចង់ផ្លាស់ប្តូរផ្នត់គំនិតប្រជារាស្ត្រខ្មែរឱ្យងាកមករកផ្លូវអាណាចក្រឱ្យបានច្រើន គឺយល់ពីមូលហេតុនៃទុក្ខលំបាករបស់ខ្លួន ជឿលើសមត្ថភាពរបស់ខ្លួន ជាពិសេសត្រូវចេះរួបរួមសាមគ្គីដើម្បីកម្ចាត់សត្រូវដែលបំផ្លាញប្រទេសជាតិ ។

៤. បើផ្អែកទៅតាមដំណើររឿងនេះ គេអាចចាត់ទុកជាអក្សរសិល្ប៍ទំនើប បែបប្រលោមលោកខេមរនិយម ព្រោះដំណើររឿងឆ្លុះបញ្ចាំងពីតថភាពប្រជាជនខ្មែរសម័យអាណានិគមបារាំ-ជប៉ុន ។

៥. បង្ហាញពី ៖

**+ លក្ខណៈជាតិ**

- ខ្មែរគោរពពុទ្ធសាសនា ។
- ប្រពៃណីមុនរៀបការ កូនប្រុសត្រូវទៅបម្រើផ្ទះកូនស្រី ។
- ខ្មែរប្រើរទេះគោជាយានជំនិះ ។

- ពេលមានអាសន្ន ប្រជាជនខ្មែរតែងបន់ស្រន់ "ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ" ឱ្យជួយ ។

+ **លក្ខណៈមនុស្ស**

- លីមជាមនុស្សមានទស្សនៈជឿនលឿន មិនផ្តេកផ្តួលលើព្រេងវាសនា ។ ពោលគឺរាល់សកម្មភាពនិងដំណើររឿងជារបស់មនុស្សខ្មែរ ។
- បញ្ហាដែលចោទឡើងក្នុងរឿងបណ្តាលមកពីបញ្ហាស្នេហា ។ លីមត្រូវឃ្លាតឆ្ងាយពីស្រុកក៏ព្រោះស្នេហា ឯនាងហេងត្រូវរត់គេចពីស្រុកកំណើតមកភ្នំពេញ ក៏ព្រោះតែស្នេហា ។

+ **លក្ខណៈសង្គម**

- ពូស្វាយមីងពតតំណាងឱ្យឪពុកម្តាយដែលចេះផ្តល់សិទ្ធិឱ្យកូនក្នុងការជ្រើសរើសគូស្រករ ។
- ប្រទេសខ្មែរស្ថិតក្រោមអាណានិគមនិយមបារាំង-ជប៉ុន ។ ស្ថានភាពសេដ្ឋកិច្ចជាតិមានលក្ខណៈអន់ថយ ជីវភាពប្រជាជនមានការខ្វះខាតយ៉ាងខ្លាំង ។
- ការគ្រប់គ្រងសេដ្ឋកិច្ច និងរដ្ឋបាលប្រទេសជាតិ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកអាណានិគមនិយម ។

៦. សង្គមបរិយាកាសនៃរឿងប្រព្រឹត្តទៅនៅសម័យអាណានិគមនិយមបារាំង-ជប៉ុន និងការលុកលុយនៃពួកចក្រពត្តិអាមេរិក ។ ប្រជាជនខ្មែររស់នៅដោយវេទនា ព្រោះជីវភាពក្រីក្រ ។ អ្នកខ្លះត្រូវព្រាត់ប្រាសគ្នាដោយសារកំណែននៅពោធិចិនតុង និងដោយការទម្លាក់គ្រាប់បែក ។ អ្នកកាន់អំណាចសុទ្ធតែជាពួកវណ្ណៈជិះ

ជាន់ តាំងពីពួកមហាអំណាចជាស៊ីសជប៉ុន បារាំង អាមេរិកាំង និងរដ្ឋអំណាចខ្មែរក្នុងស្រុក ពួកគេគិតតែពីបុណ្យសក្តិ អំណាច និងការសប្បាយផ្តាល់ខ្លួនតែប៉ុណ្ណោះ ។

គំនិតអ្នកនិពន្ធក្នុងការលើកយកតថភាពនាសម័យអាណានិគមមកឆ្លុះបញ្ចាំង ក្នុងបំណង៖

- ឱ្យចេះស្វែងរកបុព្វហេតុពិតនៃទុក្ខវេទនារបស់ប្រជាជនកម្ពុជា ។
- ឱ្យមានស្មារតីសុទិដ្ឋិនិយម មានសម្បជញ្ញៈចំពោះជាតិ ។
- ឱ្យកូនខ្មែរមានកំហឹងឈឺចាប់ ចំពោះពួកអាណានិគម និងអំពើពុករលួយ ជិះជាន់ពីសំណាក់អ្នក មានអំណាចបុណ្យសក្តិ មាសប្រាក់មកលើរាស្ត្រខ្មែរគួរឱ្យអណោចអធម ហើយក្រោកឈរឡើងដើម្បីទាមទារសិទ្ធិសេរីភាព ក្នុងការរស់នៅប្រកបដោយសុភមង្គល ។



# នៅពេលស្លាប់

## សំណួរ

១. តាមប្រពៃណីនៃការស្លាប់ តើជនជាតិខ្មែរបានរៀបចំពិធីជាប៉ុន្មានដំណាក់? អ្វីខ្លះ?

២. តើគេនិយមធ្វើអ្វីខ្លះ?

ក. មុនពេលស្លាប់?

ខ. ពេលស្លាប់?

គ. ក្រោយពេលស្លាប់?

៣. ចូរអ្នកបង្ហាញពីអត្ថន័យនៃ "កោដ្ឋ" ក្នុងទំនៀមទម្លាប់ខ្មែរ ។

៤. តើការប្រើទង់ព្រលឹងមានអត្ថន័យយ៉ាងណាខ្លះចំពោះអ្នកស្លាប់? ចូរបង្ហាញ ។

៥. តើពិធីរំលាយសព មានចំណុចសំខាន់ៗអ្វីខ្លះគួរកត់សម្គាល់?

៦. ចូរអ្នករកលក្ខណៈជាតិតាមរយៈប្រពៃណីនៅពេលស្លាប់ ។

៧. តើការធ្វើពិធីបុណ្យឱ្យអ្នកស្លាប់នៅសម័យចេនឡា និងសម័យអង្គរមានលក្ខណៈយ៉ាងណាខ្លះ?

៨. តើអត្ថបទនេះបានផ្តល់តម្លៃអប់រំយ៉ាងណាខ្លះចំពោះអ្នក?

## ចម្លើយ

១. តាមប្រពៃណីនៃការស្លាប់ ជនជាតិខ្មែរបានរៀបចំពិធីជាបីដំណាក់គឺ ៖

- ពេលជិតស្លាប់ ( ពិធីសូត្រធម៌ )
- ពេលស្លាប់ ( ពិធីបុណ្យសព )
- ក្រោយពេលស្លាប់ ( ពិធីរំលឹកវិញ្ញាណក្ខន្ធ )

២. ពិធីផ្សេងៗ

ក. មុនពេលស្លាប់

- គេនិមន្តព្រះសង្ឃ៤អង្គ ឬ១អង្គក៏បាន មកសូត្រធម៌ឱ្យអ្នកជំងឺជិតស្លាប់ ។ គេត្រូវរកអាចារ្យម្នាក់នៅជួយមើលខុសត្រូវរហូតដល់ដង្ហើមចុងក្រោយ ។

. បងប្អូនកូនចៅមកសុំខមាទោស

. អ្នកជំងឺទន្ទេញធម៌ " ពុទ្ធោ អរហំ " ដោយតាំងស្មារតីឱ្យនឹងនឹកទៅរកអំពើល្អដែលខ្លួនបានធ្វើកន្លងមក ។

. គេនាំគ្នារៀបគ្រឿងបន្ទុងនិងប្រដាប់ប្រដាផ្សេងៗបង្ហាញអ្នកជំងឺ ។

- អាចារ្យលញ់ទៀនកល្ប ទៀនគោល ធ្វើស្លាត្រូយ ទង់ព្រលឹង និងសុពារបាត៦សន្លឹក ។

- ពេលជិតដាច់ខ្យល់ ឬពេលស្លាប់គេដុតទៀនកល្ប

- គេដាក់ទង់ព្រលឹងនៅក្បាលគ្រែអ្នកជំងឺ ព្រោះគេមានជំនឿថាពេលមនុស្សស្លាប់ទៅ ទង់ព្រលឹងនឹងទ្រព្រលឹងរហូតដល់ចាប់កំណើតថ្មី ។

- នៅជុំវិញអ្នកជំងឺមានចងសំពត់ស៤ ព្រះបត់ ។

ខ. ពេលស្លាប់

- អាចារ្យចូលទៅបិទភ្នែក និងមាត់ធ្មេញ ហើយយកសុពារ

បាតទាំង៦សន្លឹកមកដាក់តាមកន្លែងដែលត្រូវដាក់ ។

- អុជទៀនកល្បដាក់ក្បាលគ្រែ ទៀនគោល៥ដើម អុជក្បែរក្បាលស្មានិងជើង។ ទៀនកល្បនៅក្បាលគ្រែ ត្រូវជំនួសដោយចង្កៀងប្រេងកាតវិញ ។
- រៀបទៀនត្បូង ស្រូវពន្លៃមួយល្អី ប្រាក់១បាត សំពត់ស៥ហត្ថ ចេកទុំ១ស្និត ដាក់ចុងជើង
- ខាងក្រោមកន្លែងតំកល់ គេដាក់ដុំថ្ម១ដុំ ទឹកមួយក្អម
- ផោតទង់ក្រពើនៅមុខផ្ទះសព ដើម្បីជាសញ្ញាថាមានមនុស្សស្លាប់ថ្មីៗ
- លើកខ្មោចចំអាសទឹកដោយលាងទឹកអប់ សិតសក់ "ទៅមុខបីដង ទៅក្រោយបីដង" ជានិមិត្តរូបនៃការវិលកើតស្លាប់របស់មនុស្ស ។
- យកសំពត់ស ៤ហត្ថ ទៅស្លៀកអោយខ្មោច រួចចងខ្សែបាសចងត្រង់ក កដៃ និង កជើង ។
- យកប្រាក់កាក់ឬចិញ្ចៀនមាសទៅដាក់ក្នុងមាត់ (បង់មាត់) ជានិមិត្តថាពេលស្លាប់មនុស្សយកអ្វីមិនបានទេ សូម្បីតែ១កាក់ ក៏យកមិនបានផង ។
- យកកំណាត់សំពត់ប្រវែង១ចំអាម៤ជ្រុងគ្របមុខខ្មោច រួចលើកដាក់លើស្នប "សំពត់រុំខ្មោចប្រវែង១២ហត្ថ"។ រួចគេចងខ្សែបាសម្តងទៀត ទើបលើកដាក់ក្តារមឈូស។ គេនិមន្តព្រះសង្ឃបង្សុកូល។ រយៈពេលតំកល់សពអាស្រ័យ

ទៅលើធនធានរបស់គ្រួសារ យូរ ឬឆាប់ ពុំមានកំណត់ឡើយ ។

- ពិធីរំកិលសពចេញពីទីតំកល់
  - ០ បង្វិលពពិលពាជុំ ជុំវិញមឈូស
  - ០ យកទឹកក្នុងក្អមស្រោចរំងាប់ដុំថ្ម រួចទម្លាក់ចោលទៅដីទាំងដុំថ្ម ទាំងក្អមទឹក ជានិមិត្តរូបនៃការបែកធ្លាយរូបរាងកាយ ។
- ពិធីដង្ហែសព
  - ០ ព្រះសង្ឃអភិធម្ម
  - ០ ព្រះសង្ឃមាតិកា
  - ០ អាចារ្យយោគីកាន់ទង់ព្រលឹង
  - ០ ភ្លេងខ្មោចលេងកំដរ (បើសិនជាមាន)
  - ០ អ្នកប្រាចលាជ (ក្មេងស្រីស្លៀកសពាក់ស) បាចលាជទៅឆ្វេងទៅស្ដាំ ដោយទន្ទេញធម៌បណ្ដើរ និងមើលទៅមុខជានិច្ច ។ (គ្រាប់លាជតំណាងឆ្អឹងដែលរាយប៉ាយលើដី) ។
  - ០ អ្នកបួសមុខភ្លើង ក្មេងប្រុសកោរសក់ ពានាស មានខ្សែស្បូវភ្លាំងរុំជុំវិញក្បាល តភ្ជាប់រហូតដល់មឈូស ។ នេះជានិមិត្តរូបជីវិតមនុស្សបន្តគ្នាដូចខ្សែច្រវាក់ ។ ការបួសមុខភ្លើងជាការតបស្នងសងគុណដល់អ្នកស្លាប់ ។
  - ០ អ្នកភ្លុក (អ្នកដុតខ្មោច) ៤នាក់សែងមឈូសយកជើងទៅមុខ ។ (សព្វថ្ងៃគេដាក់ក្នុងរថយន្ត) ។
  - ០ អ្នកទទួលទៀនត្បូង( ធម្មតាជាអ្នកជិតស្និទ្ធនឹងសាកសព)

○ គ្រួសារ ញាតិមិត្តរបស់សព ដង្ហែតាមក្រោយ ។

- ទៅដល់ប៉ាឆា
  ○ ដង្ហែប្រទក្សិណបីជុំប៉ាឆា ជាឧត្តរាពតិ (ពីខាងឆ្វេងនៃប៉ាឆា) រួចដាក់មឈូសលើជើងថ្ករ យកក្បាលទៅទិសខាងលិច ។
  ○ បើកគម្របមឈូស អាចារ្យបើកស្នប បើកកន្សែងគ្របមុខ កូនចៅយកកន្សែងនេះឡើង ដើម្បីបានសេចក្ដីសុខសិរីសួស្ដី ។
  ○ កាត់ចំណងខ្សែបាស រួចនិមន្តព្រះសង្ឃបង្សុកូល ។
  ○ ញាតិមិត្តយកផ្កា ទៀន ធូប ទៅដាក់លើសព សូមខមាទោសជាចុងក្រោយ ។
  ○ អាចារ្យយោគី និងអ្នកភ្លុក៤នាក់យកចន្លុះ១ដើមម្នាក់ដើរព័ទ្ធជុំវិញមឈូសពាជុំ ។ រួចអាចារ្យដុតភ្លើងបូជាសព

ចំពោះបច្ចុប្បន្ន អ្នកខ្លះ ពិសេសអ្នករាជការ គេនិយមថ្លែងសុន្ទរកថាស្ដីពីជីវប្រវត្តិ និងវិយោគកថា ដើម្បីសំដែងពីទុក្ខសោកស្ដាយរបស់ញាតិមិត្ត... ។

- ពេលភ្លើងកំពុងឆេះ
  ○ បំបួសអ្នកបួសមុខភ្លើង (សឹកវិញនៅពេលបូជារួច)
  ○ ទេសនាមុខភ្លើង
- ពេលសពឆេះអស់
  ○ អ្នកភ្លុកយកសំពត់គ្របមឈូស ចោលរំលងភ្លើង៣ដងដើម្បីរំងាប់ចង្រៃឧបទ្រព្យ

- ០ យោគីយកទឹកមន្ត (ទឹកសំបួរ) មួយផ្តិល អ្នកភ្ជុកកាន់ក្អមទឹកមួយដើរប្រទក្សិណពាជុំដូចមុនហើយរំលត់ភ្លើង ។
- ០ បាចគ្រាប់ស្រូវ ល្ងរ...លើគំនរធ្យូងដើម្បីប្រារព្ធពិធីប្រែរូប (នេះជាសំណាបនៃជីវិត) ។ ពិធីប្រែរូបប្រព្រឹត្តទៅបីដង ។
- ០ គ្រួសារសពរើសធាតុមកលាងនឹងទឹកម្ទូរ ទឹកសំបួរមាសនិងទឹកដូងខ្ចី ។ ពេលរើសបើអ្នកណារើសបានកាក់ ឬធ្មេញចាត់ទុកជាអ្នកមានសំណាង ត្រូវថែរក្សាឱ្យបានល្អ
- ០ យកធាតុដាក់ក្នុងកោដ្ឋ រួចយកទៅដាក់ក្នុងផ្ទះ ឬវត្ត ឬចេតិយ ។
- ០ វេលាយប់និមន្តព្រះសង្ឃសូត្រមន្តទេសនា បញ្ចូនមគ្គផល ។ ព្រឹកឡើងយកចង្ហាន់ទៅប្រគេនលោកបញ្ចប់ពិធី ។

**គ. ក្រោយពេលស្លាប់ កូនចៅ ឬសាច់ញាតិនៃសពធ្វើបុណ្យរំលឹកវិញ្ញាណក្ខន្ធ ៖**

- គម្រប់៧ថ្ងៃ ឬ១០០ថ្ងៃ
- គម្រប់មួយខួប គេធ្វើបុណ្យឧទ្ទិសកុសលឱ្យទៀតដូចមុន ពិធីនេះអាចធ្វើរៀងរាល់ឆ្នាំ ទៅតាមលទ្ធភាពគ្រួសារ ។

៣. អត្ថន័យនៃ "កោដ្ឋ" ក្នុងទំនៀមទម្លាប់ខ្មែរ ៖

- "កោដ្ឋ" : ជង្រុក ។ របស់សម្រាប់ដាក់សព, ដាក់ធាតុ ។
- កោដ្ឋ មានពីរខ្នាត ៖ ខ្នាតធំសម្រាប់ដាក់សព ឯខ្នាតតូចសម្រាប់ដាក់អដ្ឋិធាតុ ។ សពដែលដាក់ក្នុងកោដ្ឋបានទាល់តែបុគ្គល

ជាព្រះមហាក្សត្រ ព្រះមហាក្សត្រិយានី ឬមន្ត្រីទាំងឡាយដែលមានឋានន្តរសក្តិជាសម្តេច ឬស្មើនឹងសម្តេច។ ចំណែកប្រជាជនប្រើកោដ្ឋតូចៗដាក់អដ្ឋិធាតុបាន។

៤. ការប្រើទង់ព្រលឹងមានអត្ថន័យថា អ្នកស្លាប់ទៅទង់ព្រលឹងនេះឯងនឹងទ្រព្រលឹងរហូតដល់ពេលចាប់ភពថ្មី។

៥. ពិធីរំលាយសព មានចំណុចសំខាន់ៗគួរកត់សម្គាល់ដូចតទៅ៖

- ទៅដល់ប៉ាឆា
  - ដង្ហែប្រទក្សិណបីជុំប៉ាឆា ជាឧត្តរាពតិ (ពីខាងឆ្វេងនៃប៉ាឆា) រួចដាក់មឈូសលើជើងថ្កុរ យកក្បាលទៅទិសខាងលិច។
  - បើកគម្របមឈូស អាចារ្យបើកស្នប បើកកន្សែងគ្របមុខ កូនចៅយកកន្សែងនេះឡើង ដើម្បីបានសេចក្តីសុខសិរីសួស្តី។
  - កាត់ចំណងខ្សែបាស រួចនិមន្តព្រះសង្ឃបង្សុកូល។
  - ញាតិមិត្តយកផ្កា ទៀន ធូប ទៅដាក់លើសព សូមខមាទោសជាចុងក្រោយ។
  - អាចារ្យយោគី និងអ្នកភ្លុក៤នាក់យកចន្លុះដើមម្នាក់ ដើរព័ទ្ធជុំវិញមឈូសពាជុំ។ រួចអាចារ្យដុតភ្លើងបូជាសព

ចំពោះបច្ចុប្បន្ន អ្នកខ្លះ ពិសេសអ្នករាជការ គេនិយមថ្លែងសុន្ទរកថាស្តីពីជីវប្រវត្តិ និងវិយោគកថា ដើម្បីសំដែងពីទុក្ខសោកស្តាយរបស់ញាតិមិត្ត...។

- ពេលភ្លើងកំពុងឆេះ

○ បំបួសអ្នកបួសមុខភ្លើង (សឹកវិញនៅពេលបូជារួច)
○ ទេសនាមុខភ្លើង
- ពេលសពឆេះអស់
○ អ្នកភ្លកយកសំពត់គ្របមឈូស ចោលរំលងភ្លើងពាដង ដើម្បីរំងាប់ចង្រៃឧបទ្រព្យ
○ យោគីយកទឹកមន្ត (ទឹកសំបួរ) មួយផ្តិល អ្នកភ្លកកាន់ក្អមទឹកមួយដើរប្រទក្សិណពាជុំដូចមុន ហើយលត់ភ្លើង ។
○ បាចគ្រាប់ស្រូវ ល្ងរ...លើគំនរធ្យូងដើម្បីប្រារព្ធពិធីប្រែរូប (នេះជាសំណាបនៃជីវិត) ។ ពិធីប្រែរូបប្រព្រឹត្តទៅបីដង ។
○ គ្រួសារសពរើសធាតុមកលាងនឹងទឹកម្ទូរ ទឹកសំបួរមាស និងទឹកដូងខ្ចី ។ ពេលរើសបើអ្នកណារើសបានកាក់ ឬ ធ្មេញចាត់ទុកជាអ្នកមានសំណាង ត្រូវថែរក្សាឱ្យបានល្អ
○ យកធាតុដាក់ក្នុងកោដ្ឋ រួចយកទៅដាក់ក្នុងផ្ទះ ឬវត្ត ឬ ចេតិយ ។
○ វេលាយប់និមន្តព្រះសង្ឃសូត្រមន្តទេសនា បញ្ជូនមគ្គផល ។ ព្រឹកឡើងយកចង្ហាន់ទៅប្រគេនលោកបញ្ចប់ពិធី ។

៦. លក្ខណៈជាតិតាមរយៈប្រពៃណីនៅពេលស្លាប់ ៖
- ខ្មែរនិយមយកសាកសពទៅបូជា.
- ខ្មែរប្រើតន្ត្រីកំដរតាំងពីកើតរហូតដល់ស្លាប់ (ភ្លេងពិណ-ពាទ្យ ភ្លេងក្លងខែក...)

- នឹកអាលោះអាល័យដល់បុគ្គលដែលស្លាប់ទៅ (យំ)
- ឬសមុខភ្លើង កោរសក់ ស្លៀកសពាក់ស កាន់ទុក្ខ
- ប្រារព្ធពិធីបុណ្យខួបដើម្បីរំលឹកវិញ្ញាណក្ខន្ធ (៧ថ្ងៃ ១០០ ថ្ងៃ ១ឆ្នាំ...)

៧. ការធ្វើពិធីបុណ្យឱ្យអ្នកស្លាប់នៅសម័យចេនឡា និងសម័យអង្គរ មានលក្ខណៈដូចតទៅ ៖

+ **នៅសម័យចេនឡា**

- ការរំលាយសព
  - បូជា រួចយកធាតុដាក់ក្នុងកោដ្ឋ ហើយបោះចោលក្នុងទឹកជ្រៅ
  - យកទៅដាក់ចោលក្នុងព្រៃឱ្យសត្វស៊ី
- កាន់ទុក្ខដោយ :
  - កោរសក់ ហើយយំស្រែកយ៉ាងខ្លាំង
  - អត់បាយអស់រយៈពេល៧ថ្ងៃ

+ **នៅសម័យអង្គរ**

- ការរំលាយសព
  - រុំសពនឹងកន្ទេល និងក្រណាត់ រួចសែងយកទៅចោលក្នុងព្រៃស្ងាត់ ទុកឱ្យសត្វស៊ី ។
  - បូជាភ្លើង
- កាន់ទុក្ខគ្មានស្លៀកពាក់សទេ គ្រាន់តែកោរសក់ ឬកាត់សក់ចំពោះស្រី ។

៨. អត្ថបទនេះបានផ្តល់តម្លៃអប់រំដូចតទៅ ៖

- ឱ្យដឹងពីប្រពៃណីទំនៀមទម្លាប់ខ្មែរនៅក្នុងពិធីបុណ្យនីមួយៗ។
- ឱ្យចូលរួមថែរក្សាប្រពៃណីពីបុរាណកុំឱ្យបាត់បង់។
- ឱ្យចេះដឹងគុណអ្នកមានគុណ។



## ពិធីចម្រើនអាយុ

**សំណួរ**

១. តើអ្វីទៅដែលហៅថាពិធីចម្រើនអាយុ?

២. តើការធ្វើពិធីចម្រើនអាយុភាគច្រើនគេត្រូវធ្វើឱ្យមនុស្សវ័យណា? ហើយគេប្រារព្ធធ្វើពិធីនេះឡើងដើម្បីអ្វី?

៣. តើពិធីចម្រើនអាយុនេះ ទាមទារឱ្យតែអ្នកជិតស្និទ្ធ( សាច់ឈាមបង្កើត) ជាអ្នកផ្តើមប្រារព្ធជូនចំពោះសាមីពិធី ឬក៏អ្នកដទៃបំពេញកិច្ចនេះជូនបានដែរ? ហេតុអ្វី?

៤. ចូរអ្នកកំណត់អត្ថន័យនៃ៖

- បុណ្យបច្ច័យបួន
- ឆាកមហាបង្សុកូល
- ចន្ទសុក្រគិរីសូត្រ

៥. តើពិធីចម្រើនអាយុនិងពិធីបុណ្យខួបថ្ងៃកំណើតដូចគ្នាដែរឬទេ? ចូរពន្យល់ ។
៦. ចូរអ្នកធ្វើការឆ្លុះបញ្ចាំងពីចំណុចសំខាន់ៗដែលជាគំនិតអ្នកនិពន្ធមានក្នុងអត្ថបទនេះ ។
៧. តាមរយៈពិធីចម្រើនអាយុនេះ ចូរអ្នកបង្ហាញឱ្យឃើញពីអត្ត-សញ្ញាណជាតិខ្មែរ ។

## ចម្លើយ

១. ដែលហៅថាពិធីចម្រើនអាយុគឺជាពិធីមួយដែលគេឧបកិច្ចថា សាមីពិធីដែលច្រើនជាមនុស្សចាស់នោះខ្លាចស្លាប់ ហើយកើតជាថ្មីវិញ ក្នុងបំណងឱ្យអ្នកនោះរស់បានយូរតទៅទៀត និងជាពិធីដែលធ្វើឡើងដើម្បី "លើករាសី" សម្រាប់ឆ្នាំថ្មីផងដែរ ។
២. ធ្វើពិធីចម្រើនអាយុ គេច្រើនធ្វើជូនមនុស្សដែលមានវ័យចំណាស់ ដើម្បីចម្រើនអាយុកាលដែលថាបុគ្គលដែលជាមាតាបិតា ជីដូនជីតា ក្នុងបំណងជាកិច្ចដឹងគុណផងដែរ ។ ប៉ុន្តែពិធីនេះធ្វើបានគ្រប់វ័យនិងវណ្ណៈមនុស្ស ហើយមិនចាំបាច់គោរពតាមថ្ងៃខែឆ្នាំកំណើតឡើយ គឺច្រើនធ្វើពេលចូលឆ្នាំ ដោយអាចមុនមួយថ្ងៃ ឬថ្ងៃទី៣ ។
៣. ពិធីចម្រើនអាយុនេះ មិនទាមទារឱ្យតែអ្នកជិតស្និទ្ធ(សាច់ឈាមបង្កើត) ជាអ្នកប្រារព្ធជូនចំពោះសាមីពិធី អ្នកដទៃក៏អាចបំពេញកិច្ចនេះជូនសាមីពិធីបានដែរ ព្រោះបុគ្គលដែលគេធ្វើពិធីជូនក៏ជាចាស់ទុំ ជាចាស់ព្រឹទ្ធាចារ្យដែលគេគ្រប់គ្នាគោរពស្រឡាញ់នៅភូមិស្រុករបស់គេ ។
៤. អត្ថន័យនៃ៖

- **បុណ្យបច្ច័យបួន** ៖ គឺក្នុងន័យថាសាមីពិធីស្លាប់ហើយកើតវិញដោយគេរៀបចំបន្ទុំងសម្រាប់ព្រះសង្ឃទស់ ហើយក៏មានពិធីស្រោចទឹកជូនសាមីពិធី ។
- **ឆាកមហាបង្សុកូល** ៖ គឺរៀបរាប់អំពីដំណើរជីវិតរបស់មនុស្សដែលមានការចាប់បដិសន្ធិនិងការកើតតាមរយៈព្រះសង្ឃឆាកទាញសំពត់ដែលគេគ្របពីលើសាមីពិធីឱ្យលេចខ្លួនឡើង ប្រៀបបីដូចជាកើតឡើងវិញ ។
- **ចន្ទសុក្រគិរីសូត្រ** ៖ គឺរៀបចំវត្ថុឧបកិច្ចផ្សេងៗមានមឈូសជាដើម កំណត់ថាសាមីពិធីស្លាប់ ហើយព្រះសង្ឃសូត្រធម៌ឆាកទាញសំពត់ស្នបពីលើសាមីពិធីដែលក្នុងន័យបញ្ជាក់ថា សាមីពិធីបានរស់រានមានជីវិតជាថ្មី ។ បន្ទាប់មក គឺការស្រង់ទឹកជូនសាមីពិធី ។

៥. ពិធីចម្រើនអាយុនិងពិធីបុណ្យខួបថ្ងៃកំណើតមិនដូចគ្នាទេ ព្រោះ

- **ពិធីចម្រើនអាយុ** ធ្វើតាមបែបបទប្រពៃណីសាសនាខ្មែរ មានរយៈពេលវែង មានអត្ថន័យបង្កើនអាយុវែងឆ្ងាយបន្តទៀត ។ ជាពិសេសគេប្រារព្ធពិធីនេះឡើងជូនមនុស្សដែលមានវ័យចំណាស់ភាគច្រើន( តាមខ្លឹមសារអត្ថបទ) ។
- **ពិធីបុណ្យខួបកំណើត** គឺជាពិធីមួយសម្រាប់រំឭកដល់ថ្ងៃខែនិងឆ្នាំកំណើតរបស់សាមីពិធីដែលគេប្រារព្ធឡើងរយៈពេលខ្លី ហើយអញ្ជើញសាច់ញាតិ មិត្តភក្តិ មកលៀងភោជនាហារបន្តិចបន្តួចដោយមានពិធីកំសាន្តខ្លះដែរ ។ សាមីពិធីក្នុងពិធីនេះគេមិនគិតពីវ័យឡើយ( តាមស្ថានភាព

ជាក់ស្ដែងតាំងពីទារក កុមារា កុមារី យុវជន យុវតី បុរស ស្ត្រី តាយាយ) ។

៦. គំនិតអ្នកនិពន្ធអត្ថបទពិធីចម្រើនអាយុ គឺក្នុងបំណងឆ្លុះបញ្ចាំងពីប្រពៃណីទំនៀមទម្លាប់ខ្មែរដ៏ល្អ ដែលបងប្អូនកូនចៅ សាច់ញាតិតែងតែធ្វើពិធីកតញ្ញូកតវេទិតាជូនចំពោះបុគ្គលដែលជាទីគោរព មានមាតាបិតា ជីដូនជីតា ចាស់ព្រឹទ្ធាចារ្យជាដើម ។ ដូចឃ្លាមួយដែលអ្នកនិពន្ធបាននិយាយថា៖ "ទោះបីក្នុងចិត្ត(អ្នកប្រារព្ធពិធី) ពុំប្រាកដថាធ្វើទៅច្បាស់ជាបានអាយុច្រើនមែន ក៏អ្នកទាំងនោះធ្វើជូនគាត់ជាកិច្ចដឹងគុណដែរ ។ រីឯសាមីពិធីដែលជាមនុស្សចាស់នោះយ៉ាងហោចណាស់ក៏មានចិត្តសោមនស្សរីករាយដោយឃើញកូនចៅជិតឆ្ងាយបង្ហាញការគោរពដឹងគុណមកខ្លួន" ។

៧. តាមរយៈពិធីចម្រើនអាយុនេះ បង្ហាញឱ្យឃើញពីអត្តសញ្ញាណជាតិខ្មែរដូចតទៅ៖

- ប្រពៃណីកតញ្ញូចំពោះអ្នកមានគុណ
- ជំនឿសាសនាធ្វើបុណ្យកុសល
- សាមគ្គីកសាងកុសល... ។

## ភាព្យប្រាម្មណ៍វិធី

១. វិធីបំភ្លើស ៖ ជាវិធីដែលអ្នកនិពន្ធប្រើពាក្យសំដីឱ្យលើសពីការពិត តែក្នុងគោលបំណងបង្ហាញសច្ចភាពណាមួយឱ្យមានកម្រិតខ្ពស់ ឬទាបបំផុតប៉ុណ្ណោះ ។

២. វិធីពង្វាង ៖ ជាវិធីដែលកវីចេះនិយាយពង្វាងដោយប្រើកន្សោមពាក្យក្នុងការសំគាល់បញ្ញត្តិណាមួយ ។

៣. វិធីត្រឡប់ ៖ ជាបដិរូបមួយបែបដែលស្ថិតនៅត្រង់ការប្រើពាក្យឆ្លុះគ្នា ហើយន័យសេចក្ដីផ្សេងគ្នា ។

### សំណួរ

១. តើអត្ថបទកាព្យ "មើលផែនដីខ្មែរ" តែងជាបទអ្វី? ចូរនិយាយពីធាតុសំខាន់ៗនៃបទនេះផង ។

២. ចូរសង្ខេបអត្ថបទកាព្យ "មើលផែនដីខ្មែរ" ។

៣. ចូរបង្ហាញរូបារម្មណ៍វិធីក្នុងកំណាព្យ "មើលផែនដីខ្មែរ" នេះ ។

៤. តើអត្ថបទកាព្យ "មើលផែនដីខ្មែរ" នេះនិយាយពីអ្វី?

៥. ដូចម្ដេចដែលហៅថាចំណាច់ច្នួន? ផ្ទួន? រណ្ដំ? ចូរលើក ឧទាហរណ៍ក្នុងអត្ថបទខាងលើមកបញ្ជាក់ផង ។

៦. ចូរសង្ខេបអត្ថបទកាព្យខាងលើជាពាក្យរាយ ។

៧. តើអត្ថបទកាព្យនេះនិយាយពីអ្វី?

## ចម្លើយ

១. អត្ថបទកាព្យ "មើលផែនដីខ្មែរ" តែងជាបទកាកគតិ ។

***ធាតុសំខាន់ៗនៃបទនេះ***

ក. <u>រង្វាស់កាព្យឬកាព្យមាត្រ</u>

- ១វគ្គមាន៧ឃ្លា
- ១ឃ្លាមាន៤ព្យាង្គ

ខ. <u>គំនូសតាង</u>

☝ **បទកាកគតិ បែបទី១**



គ. <u>ចំណាប់ចូន</u>

+ ចូនក្នុងវគ្គ

៣៤ យ១ |═══| ៣៤ យ២

៣៤ យ៣ |═══| ៣៤ យ៥ |═══| ៣៤ យ៦

+ ចូនឆ្លងវគ្គ

៣៤ យ៧ វ១ |═══| ៣៤ យ៣ វ២

✌ បទភាកគតិ បែបទី២




-ចំណាប់ចូន

+ ចូនក្នុងវគ្គ

៣៤ យ១ |═══| ៣៤ យ២

៣៤ យ៣ |═══| ៣៤ យ៥ |═══| ៣៤ យ៦

៣៤ យ៤ |═══| ៣២ យ៥

+ ចួនឆ្លងវគ្គ

ព៤ ឃ៧ វ១ ⟷ ព៤ ឃ៣ វ២

ឃ. ចង្វាក់ : បទនេះមានចង្វាក់ស្មើ មិនលើកមិនដាក់តែរន្ថើនៗ មានទំនងដូចជាដំណើរក្អែក ហើយទម្លាក់លើព្យាង្គទី២គ្រប់ឃ្លា។

ង. បរិយាកាស : បទនេះគេប្រើសម្រាប់ពណ៌នា ទីកន្លែង តួអង្គ ធម្មជាតិ ពិសេសគេយកបទនេះទៅប្រើក្នុងពិធីផ្ដើមរឿង។ ពេលខ្លះកវីយកបទនេះទៅប្រើក្នុងការសំដែងទុក្ខសោកផងដែរ។

ច. របៀបសូត្រ : បទកាកគតិមានរបៀបសូត្រ១២បែបគឺ៖

| | |
|---|---|
| -បែបក្អែកលោតទី១ | -បែបត្រៃលក្ខណ៍ |
| -បែបក្អែកលោតទី២ | -បែបកាកកាត់ត្រើយ |
| -បែបពណ៌នា | -បែបក្មេង |
| -បែបទំនួញ | -បែបភូមិធមិភូមិសុខ |
| -បែបពិលាប | -បែបផ្ដាញ់មារ |
| -បែបក្អែកបួល | -បែបសាងព្រះផ្នួស |

២. សង្ខេបអត្ថបទកាព្យ "មើលផែនដីខ្មែរ" :

ផ្ទៃមេឃភ្លឺស្រឡះទេតែអ្វីៗហាក់ខ្មៅងងឹតប្រកបដោយភាពអាប់អួរអ្វីទាំងអស់បានប្រែក្លាយផ្ទុយស្រឡះពីធម្មជាតិ។ បក្សីប្រែជាដើរម្រឹគទាំងឡាយប្រែជាហោះហើរខ្មុមក្លាយទៅជា

ផ្ទះផ្កាវីកខុសរដូវកាលស្មៅស្រពោន ស្វិតក្រួសថ្មប្រែជាក្រៀមក្រំ សត្វហ៊ឹងគីង្គក់ឡើងបុណ្យ ឡើងសក្តិស្មើនឹងចន្ទ្រា។ បញ្ហាទាំងនេះបណ្តាលមកពីពួកបនក្សត់ចិត្តឫស្យាធ្វើបាបរាស្ត្រខ្មែរ គ្មានត្រាប្រណី។

៣. រូបារម្មណ៍វិធីក្នុងកំណាព្យ "មើលផែនដីខ្មែរ"

+ **បដិវិធី** : មេឃភ្លឺខ្មៅជិត...ស្ទឹងជនស្ងួតចៃស...

+ **វិធីបំផ្លើស**

វេស្សវ័ណអង់អាច អាងឫទ្ធិអំណាច ប្រឹងលើកតំកើង
ហ៊ឹងនិងគីង្គក់ ពីភក់ចំបើង ឱ្យរុងរឿងថ្កើង
ឡើងស្មើចន្ទ្រា។

+ **ឧបមានវិធី**

ភ្លើងគឺចិត្តកាច នៃពាលកំណាច បនក្សត់ឫស្យា
មានពិសពើតស្អិត ជាងភ្លើងធម្មតា សុទ្ធធាតុហិង្សា
ឆេះទាំងកាយចិត្ត។

+ **ជីវរូបារម្មណ៍**

ផ្កាវីកខុសកាល ទឹកសោចពេញវាល ស្មៅស្រពោនស្វិត
ក្រួសថ្មក្រៀមក្រំ យំសោកអាណិត ត្រកួនព្រលិត
លេងឫទ្ធិឡើងទ្រើង។

+ **សោតរូបារម្មណ៍**

ស្រណោះផ្គរលាន់ ផ្គរស្រែករន្ទាន់ ប្រាប់ដាអំណោយ
ហ៊ីងក្អាត់មិនស្តាប់ លុះស្លាប់ថ្លោះធ្លោយ បែរងាកមើលក្រោយ
កោះត្រើយហួសឆ្ងាយ ។

៤. អត្ថបទកាព្យ "មើលផែនដីខ្មែរ" នេះនិយាយពីជីវិតប្រជាជនខ្មែរ ដែលរងទុក្ខវេទនានៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានពួកប៉ុល ពត កាប់សម្លាប់និងធ្វើទុក្ខទោសប្រជាជនគ្មានត្រាប្រណី ដោយប្រើឱ្យធ្វើការទាំងយប់ថ្ងៃ ទាំងភ្លៀងផ្គរ រងាញ្ញាក់ញ័រ...និងហូបពុំឆ្អែត ។។

៥. + **ចំណាច់ច្ចួន** : ជាពាក្យទាំងឡាយដែលមានព្យាង្គកើតឡើងដោយស្វរស្រៈដូចគ្នា ឬព្យញ្ជនៈប្រកបដូចគ្នា ឬស្វរស្រៈ និងព្យញ្ជនៈប្រកបដូចគ្នា ។

ឧ. កំណើត ⟝⟞ កើត

+ **ផ្ទួន** : គឺជាព្យាង្គតែមួយដែលកវីប្រើច្រើនដងក្នុងឃ្លា ឬវគ្គ ។

ឧ. បុណ្យ ☰ បុណ្យ

+ **រណ្តំ** : គឺជាការប្រើព្យញ្ជនៈតែមួយ ឬស្រៈតែមួយ ដដែលៗច្រើនដងក្នុងឃ្លា ឬវគ្គ ។

ឧ. ស្នេហ៍ ⟝⟞ ស្នង

៦. សង្ខេបអត្ថបទកាព្យខាងលើជាពាក្យរាយ :

+ អត្ថបទ "មើលផែនដីខ្មែរ" (មើលចម្លើយទី២)

+ អត្ថបទ "អូននៅបង្កើយ"

ព្រលឹងមាសអើយ អូននៅជិតបង្កើយតែហាក់ដូចជានៅឆ្ងាយពីគ្នាណាស់...... *(សិស្សសាកល្បងហាត់សង្ខេបដោយខ្លួនឯង)*....................។

៧. អត្ថបទកាព្យនេះនិយាយអំពី ៖

+ អត្ថបទ "មើលផែនដីខ្មែរ" និយាយអំពីភាពប្រែប្រួលក្រឡាប់ចាក់ សាហាវយង់ឃ្នងដែលកើតមានឡើងនៅសម័យប៉ុលពត និងទុក្ខវេទនា ការឈឺចុកចាប់ខ្លោចផ្សា រងទុក្ខទោស ធ្វើការធ្ងន់ គ្មានពេលសម្រាក គ្មានអាហារហូបចុកគ្រប់គ្រាន់ គ្មានទីជម្រកត្រឹមត្រូវ គ្មានសិទ្ធិសេរីភាពក្នុងការនិយាយស្តី ។

+ អត្ថបទ "អូននៅបង្កើយ" និយាយសេចក្តីខ្វល់ខ្វាយរបស់បុរសម្នាក់ចំពោះសេចក្តីស្នេហា ដែលនៅជិតបង្កើយ តែហាក់ដូចជានៅឆ្ងាយពីគ្នា ។



# ការសុំសន្តោសប្រណី

## សំណួរ

១. តើអត្ថបទខាងលើដកស្រង់ពីរឿងអ្វី? អ្នកនិពន្ធឈ្មោះអ្វី?

២. ចូរសង្ខេបអត្ថបទកាព្យខាងលើឱ្យទៅជាពាក្យរាយ ។

៣. ចូរស្រង់ឈ្មោះតួអង្គក្នុងអត្ថបទដកស្រង់ខាងលើដោយប្រាប់មុខងារ និងឋានានុក្រមផង ។

៤. តើសៀមបានសារភាពដូចម្តេចខ្លះ? ហើយសន្យាដូចម្តេចខ្លះដែរចំពោះមុខប្រជារាស្ត្រខ្មែរ?

៥. តើអត្ថបទខាងលើបានបង្ហាញពីអំណាចមហាក្សត្រខ្មែរបែបណាខ្លះ?

៦. តើអត្ថបទខាងលើសរសេរជាបទអ្វី? ចូរបង្ហាញជាគុសំខាន់ៗនៃបទកំណាព្យនេះ ។

## ចម្លើយ

១. អត្ថបទខាងលើដកស្រង់ពីរឿងតេជោដំឌិន ។ អ្នកនិពន្ធឈ្មោះ តាមាស ។

២. សង្ខេបអត្ថបទកាព្យខាងលើឱ្យទៅជាពាក្យរាយ ៖

ព្រះវាំងណា ជាឧបរាជនៃនគរសៀមបានសរសេរសំបុត្រ

មកអង្វរករស្ដេចខ្មែរព្រះនាមបុទុមសូរវង្ស ឱ្យលើកលែងទោសដល់ស្ដេចសៀមព្រះនាមសុរិយា ។ ព្រះវាំងណាសន្យាដាក់នគរសៀមជាចំណុះនគរខ្មែរ ហើយនិងថ្វាយសួយសារអាករដល់នគរខ្មែរថែមទៀតផង ។

ព្រះរាជាខ្មែរក៏យល់ព្រមចំពោះសំណើនេះ ហើយមានព្រះទ័យសប្បាយរីករាយក្រៃលែង ។ ព្រះអង្គក៏ជំនុំនឹងអស់ពួកមន្ត្រីដើម្បីកំណត់យកសួយសារអាករពីស្ដេចសៀម ។

៣. តួអង្គក្នុងអត្ថបទដកស្រង់មាន ៖

- ព្រះបុទុមសូរវង្ស : ព្រះរាជាខ្មែរ
- តេជោដំឌិន : មេទ័ពខ្មែរដ៏ល្បី
- ព្រះចៅសុរិយា : ស្ដេចសៀម, ត្រូវតេជោដំឌិនចាប់បាន
- ព្រះវាំងណា : ឧបរាជនៃនគរសៀម, អ្នកផ្ញើសំបុត្រសុំឱ្យស្ដេចខ្មែរលើកលែងទោសដល់ស្ដេចសៀម
- ព្រះនាងមហាយិកា : បុត្រីព្រះវាំងណា

៤. សៀមបានសារភាពពីកំហុសរបស់ខ្លួនដែលបានឈ្លានពានទឹកដីខ្មែរ ហើយសន្យាចំពោះមុខប្រជារាស្ត្រខ្មែរថានឹងដាក់នគរសៀមជាចំណុះនគរខ្មែរ ព្រមទាំងនាំសួយសារអាករមកថ្វាយនគរខ្មែរ

ថែមទៀតផង។

៥. អត្ថបទខាងលើបានបង្ហាញពីអំណាចមហាក្សត្រខ្មែរមានឫទ្ធានុ-ភាពខ្លាំងអស្ចារ្យ ដែលធ្វើឱ្យស្តេចសៀមបាក់បបខ្លបខ្លាច ហើយសុំចុះចាញ់។ ព្រះអង្គធ្វើឱ្យប្រទេសជាតិមានបូរណភាពទឹកដី ប្រជារាស្ត្ររស់នៅដោយសុខសន្តិភាពបរិបូណ៌។

៦. អត្ថបទខាងលើសរសេរជាបទពាក្យ៩។

**ធាតុសំខាន់ៗនៃបទកំណាព្យនេះ**

**ក-រង្វាស់កាព្យឬកាព្យមាត្រ**

-១វគ្គមាន៤ឃ្លា

-១ឃ្លាមាន៩ព្យាង្គ

**ខ-គំនួសតាង**



**គ-ចំណាប់ចួន**

+ចួនក្នុងវគ្គ

-ព៩ ឃ១ ⟝⟞ ព៣ ឃ២

-ព៩ ឃ២ ⟝⟞ ព៩ ឃ៣ ⟝⟞ ព៣ ឃ៤

+ចួនឆ្លងវគ្គ

ព៩ ឃ៤ វ១ ⟝⟞ ព៩ ឃ២ វ២

**ឃ-ចង្វាក់** : ទម្លាក់សំឡេងលើព្យាង្គទី៣និងទី៦ គ្រប់ឃ្លា។

**ង-បរិយាកាស** : បទនេះប្រើសម្រាប់សំដែងមនោសញ្ចេតនា ឬ ការឆ្លើយឆ្លងលេបខាយ ស្តីបន្ទោស គំហកគំហឹន។

**ច-របៀបស្មូត្រ** : បទពាក្យ៩មានរបៀបស្មូត្រ១បែបគឺ បែបរាស់។



# ប្រពៃណីអាពាហ៍ពិពាហ៍របស់ខ្មែរ

## សំណួរ

១. តើដំណាក់កាលធំៗនៃអាពាហ៍ពិពាហ៍ខ្មែរមានអ្វីខ្លះ?

២. តើគេជ្រើសរើសមនុស្សប្រភេទណា ដើម្បីចូលទៅស៊ើបសួរ (ចៃចូវ) ព័តិមានខាងកូនក្រមុំ?

៣. ចូររៀបរាប់ចំណុចសំខាន់ៗក្នុងថ្ងៃសំពះ ។

៤. តើទំនៀមរៀបចំដោតផ្កាស្លាពា ទាក់ទងទៅនឹងរឿងអ្វី?

៥. ចូររាប់ឈ្មោះបទចម្រៀងក្នុងពិធីរៀបអាពាហ៍ពិពាហ៍ឱ្យបាន៥ បទ ដោយបញ្ជាក់ថា បទនោះច្រៀងក្នុងពិធីអ្វី?

៦. តើអ្នកយល់ដូចម្តេចចំពោះប្រពៃណីរៀបមង្គលការរបស់ដូនតាខ្មែរយើង?

## ចម្លើយ

១. ដំណាក់កាលធំៗនៃអាពាហ៍ពិពាហ៍ខ្មែរមាន ៖

+ **មុនពេលរៀបការ** (មានបីដំណាក់កាល)

- **ពិធីចៃចូវ**
- **ពិធីស្ដីដណ្ដឹង**

- ពិធីជូនកំណត់

+ ពេលរៀបការ ( មានបីថ្ងៃ)

- ថ្ងៃចូលរោង
- ថ្ងៃស៊ីស្លាកំណត់
- ថ្ងៃសំពះ

+ ក្រោយពេលរៀបការ

២. ដើម្បីចូលទៅស៊ើបសួរ ( ចៃចូវ) ព័ត៌មានខាងកូនក្រមុំ គេជ្រើសរើសមនុស្សម្នាក់ ដែលទុកចិត្ត មិនអភ័ព្វ ដែលគេឱ្យឈ្មោះថា អ្នកឃ្នាយ ឬមេអណ្ដើក ហើយធ្លាប់ស្និទ្ធស្នាលនឹងគ្រួសារខាងស្រី ។

៣. រៀបរាប់ចំណុចសំខាន់ៗក្នុងថ្ងៃសំពះ ។

- អាចារ្យនាំកូនប្រុសទៅថ្វាយបង្គំរានទេវតា ដោយត្រូវអង្គុយបែរមុខទៅទិសខាងកើត ចាំយកពេលាទៅទីនោះ ។
- នាំកូនប្រុសទៅសំពះផ្កាស្លានៅលើផ្ទះការ ។
- សាមីខ្លួនខាងស្រី យកទឹកមួយផ្តិលមកលាងជើងឱ្យកូនកំលោះ ព្រមទាំងជូនស្លាមួយម៉ាត់ផង ។
- កូនកំលោះត្រូវសំពះស្លាព្រះពរ " មួមូរពាត្រួយ " ដែលនៅលើខ្នើយ ។ បន្ទាប់មកអ្នកផ្លូវស្រីម្នាក់អុជទៀនដុតនៅលើកាន់ទៅអញ្ជើញកូនស្រីឱ្យចេញមកផ្ទឹម ។

- ឯអ្នកភ្លេងច្រៀងរាំបើកវាំងនន ។ កូនស្រីចេញមកអង្គុយខាងឆ្វេងកូនកំលោះ ដើម្បីសំពះផ្ទឹម ។
- គេធ្វើពិធីបង្វិលពពិលនៅជុំវិញស្វាមីភរិយា ។
- អាចារ្យសូត្រឱ្យពរផ្កាស្លា ។ ពួកមេបា និងញាតិមិត្តចងដៃកូនប្រុសស្រីដោយអំបោះព្រមទាំងឱ្យពរសព្ទសាធុការរៀង១ខ្លួន។
- គេស្រាយផ្កាស្លាកណ្តាល និងផ្កាស្លាពៅចែកញាតិមិត្តបាចដើម្បីឱ្យពរជ័យសេរីមង្គល។
- ចប់ពិធីហើយសាមីខ្លួនប្រុសស្រីងើបអង្គុយ បែរមុខរកគ្នាហើយគេវាយខ្មោះឱ្យកូនប្រុស តោងជាយស្បៃកូនស្រីដើរចូលក្នុងបន្ទប់ ។

៤. ទំនៀមរៀបចំដោតផ្កាស្លា៣ ទាក់ទងទៅនឹងរឿងដើមកំណើតទំនៀមផ្កាស្លាបី( បុរស៤នាក់រៀនយុទ្ធសិល្ប៍៤មុខ) ដកស្រង់ចេញពីសៀវភៅប្រជុំរឿងព្រេងខ្មែរភាគ៩។ រឿងនេះនិយាយពីបុរស៤នាក់ចេះសិល្ប៍សាស្ត្រផ្សេងពីគ្នា ដណ្តើមស្រីម្នាក់ធ្វើជាប្រពន្ធ។ បន្ទាប់មកចៅក្រមក៏កាត់ក្តីឱ្យ នាងនោះបានទៅអ្នកចេះហែលទឹក ឯបុរសដែលមិនបាននាងនោះ ត្រូវចាត់ទុកជាឪពុក ជាម្តាយ និងជាបងប្រុស ហើយដើម្បីដឹងគុណដល់ខ្លួន អ្នកទាំងបីសំណូមពរឱ្យមានអ្វីទុកជាតំណាងមង្គលតទៅមុខ ដើម្បីឱ្យកូនប្រសារគំនាប់

ឪពុកម្ដាយ និងបងក្នុងគ្រានេះផង។ គេក៏នាំគ្នាចាត់ចែងរកផ្កាស្លាមួយខ្លួបមកចែកជាបីចំណែកតំណាងឱ្យអ្នកទាំងបី។ ទំនៀមនេះក៏ជាប់រហូតដល់សព្វថ្ងៃ។

៥. រាប់ឈ្មោះបទចម្រៀងក្នុងពិធីរៀបអាពាហ៍ពិពាហ៍ឱ្យបាន៥បទ

- បទចំបក់រោយ លេងក្នុងពិធីរាប់ផ្លែឈើ
- បទប៉ុកពើក លេងក្នុងពិធីកំដរមេបាពិសាស្លាម្លូ
- បទសារិកាកែវ លេងក្នុងពិធីកាត់សក់
- បទត្រពាំងពាយ លេងក្នុងពិធីនាំកូនក្រមុំទៅងូតទឹក
- បទបាយផាត់ជាយ-លេងក្នុងពិធីរាំបើកវាំងនន
- បទលោមនាង លេងក្នុងពិធីកាត់ខាន់ស្លា

៦. ចំពោះប្រពៃណីរៀបមង្គលការរបស់ដូនតាខ្មែរយើង ខ្ញុំយល់ថាជាប្រពៃណីមួយដ៏ល្អ ព្រោះវាបង្ហាញពីអត្តសញ្ញាណជាតិខ្មែរដែលមានពិធីជាច្រើនសម្បូរបែបរបស់ដូនតាយើង។ ហើយពិធីនេះហើយដែលធ្វើឱ្យខ្មែរមានលក្ខណៈពិសេសខុសពីជាតិសាសន៍ដទៃ និងមានអរិយធម៌រុងរឿង។

មេរៀនទី ៩

# ទំនាក់ទំនងរវាងអក្សរសិល្ប៍ខ្មែរ និងបរទេស

## រឿងរាមាយណៈឥណ្ឌា

**សំណួរ**

១. ចូរប្រាប់ឈ្មោះតួអង្គសំខាន់ៗក្នុងកាន្ឌទី១ និងកាន្ឌទី២ ។

២. តើអត្ថបទដកស្រង់ក្នុងកាន្ឌទី១ និងកាន្ឌទី២ និយាយពីអ្វី?

៣. ចូរប្រៀបធៀបអត្ថបទដកស្រង់ក្នុងកាន្ឌទី១ និងកាន្ឌទី២ ទៅនឹងអត្ថបទដកស្រង់ដែលអ្នកបានសិក្សាក្នុងមេរៀនមុនក្នុងរឿងរាម-កេរ្តិ៍ ខ្សែទី១ និងខ្សែទី២ ។

៤. តើរាមកេរ្តិ៍ និងរឿងរាមាយណៈ មានទំនាក់ទំនង និងឥទ្ធិពលទៅលើគ្នាដូចម្តេចខ្លះ?

៥. តើតួអង្គព្រះរាមក្នុងរឿងរាមកេរ្តិ៍ខុសពីព្រះរាមក្នុងរឿងរាមាយណៈដូចម្តេចខ្លះ?

**ចម្លើយ**

១. តួអង្គសំខាន់ៗ

+ កាន្ទទី១

- ព្រះបាទទសរថ នៃនគរអយុធ្យា - ឥសី សិដ្ឋមុនី
- ព្រះទេពមុនី - ព្រះសុយញ្ញមុនី
- ព្រះកស្សបមុនី - ព្រះឫស្យស្រឹង្គមុនី
- ព្រះជនកសុរិយាវង្ស នៃនគរមិថិលា
- ព្រះចៅនគរពារាណសី
- ព្រះបាទអស្វបតី គ្រងរាជ្យកេកយៈជនបទ
- ព្រះចៅលោមបាទ គ្រងនគរអង្គតរាស្ត្រ
- ព្រះចៅមគធរាស្ត្រ - ព្រះព្រហ្ម
- ទសកណ្ឋរាវណៈ - ព្រះនារាយណ៍
- ព្រះនាងកៅសល្យា មហេសីទី១នៃព្រះបាទទសរថ
- ព្រះនាងកៃកេយី មហេសីទី២នៃព្រះបាទទសរថ
- ព្រះនាងសុមិត្រា មហេសីទី៣នៃព្រះបាទទសរថ
- ព្រះរាមលក្ស្មណៈ ( ព្រះលក្ស្មណ៍)
- ព្រះសុត្រុឃ្នន៍ - ព្រះភរតៈ
- សុគ្រីវៈ( សុគ្រីព) - វាំលីន ( ពាលី)
- ហនុមាន - នលៈ
- តារៈ - គន្ធមាទន៍
- សព្វ - មៃន្ទៈ
- ទ្វិវិនៈ - ឥសីវិស្វាមិត្រ
- មារិចៈអសុរៈ - សុវាំហុអសុរៈ
- យក្ខិនីតារកា - យក្សសុកេតុ

- យក្សកាកនាសូរ
- ស្តេចសុមតី
- ព្រះស្ដាននន្ទមុនី
- នាងអហល្យា
- ព្រះឥសូរ
- នាងឧរមិលា
- ព្រះស្រីធរវជ្រះ
- ព្រាហ្មណ៍ជមទគ្និ
- សេដ្ឋីសត្យមុនី
- គោតមឫសី
- ព្រះគោតមព្រហ្ម
- សម្ដេចទេវរាជសុរិយវង្ស
- នាងសីតា
- នាងមានទវី
- បរសុរាម ឬរាមបរសុ

+កាន្ទទី២

- ព្រះរាម
- នាងកៃកេយី
- ព្រះលក្ស្មណ៍
- កូខ័ន
- ឥសីវាល្មីកិ
- ព្រះសុត្រុឃ្ន័
- ព្រះវិសិដ្ឋមុនី
- នាងកោសល្យា
- ក្រុងខរ
- នាងទាសី មន្ថរា
- ព្រះបាទទសរថ
- នាងសីតា
- ឥសភរទ្វាជះ
- ព្រះភរតះ
- ព្រះបាទអស្វបតិ
- ព្រះទេវមុនី
- នាងសុមិត្រា
- រាវណះ

២. អត្ថបទដកស្រង់

+ ក្នុងកាន្ទទី១ និយាយអំពី ព្រះបាទទសរថធ្វើពិធីបូជាសេះស ចំពោះព្រះអគ្គីដើម្បីសុំបុត្រ ហើយបានបុត្រដូចបំណង គឺមហេសីទី១ កៅសល្យា បានបុត្រឈ្មោះព្រះរាម មហេសីទី២ឈ្មោះកៃ-

កេយី មានបុត្រឈ្មោះភរត និងមហេសីទី៣ឈ្មោះនាងសុមិត្រា បានបុត្រឈ្មោះលក្សណៈ និងសុត្រុឃ្ន័ ។

+ ក្នុងកាន្ឌទី២ និយាយអំពីនាងកៃកេយីដែលជំទាស់នឹងព្រះបាទទសរថមិនឱ្យព្រះរាមឡើងគ្រងរាជ្យ ដោយយកពាក្យសន្យាមករារាំង កាលពីព្រះអង្គធ្លាប់បានព្រះភរតៈជួយច្បាំងឱ្យព្រះអង្គឈ្នះលើស្តេចអាទិត្យសុរិយាកាលពីលើកមុន ហើយសន្យានឹងឱ្យព្រះភរតៈឡើងគ្រងរាជ្យ ។

៣. ប្រៀបធៀបអត្ថបទដកស្រង់ក្នុងកាន្ឌទី១និងកាន្ឌទី២ ទៅនឹងរឿងរាមកេរ្តិ៍ ខ្សែទី១និងខ្សែទី២ ៖

| រាមាយណៈ | រាមកេរ្តិ៍ |
|---|---|
| -មានឈ្មោះចំណងជើងកាន្ឌ គឺកាន្ឌទី១ឈ្មោះថា "ពាលកាន្ឌ" និងកាន្ឌទី២ឈ្មោះថា "អយោធ្យាកាន្ឌ" ។ | -គ្មានឈ្មោះចំណងជើងខ្សែទេ គឺគ្រាន់តែដាក់ថាខ្សែទី១ និងខ្សែទី២ ។ |
| -អ្នកនិពន្ធបានរៀបរាប់ពីប្រវត្តិកំណើតនៃព្រះរាជវង្សានុវង្សរបស់ព្រះរាមរហូតដល់ព្រះរាមប្រសូតដឹងក្តីធំខ្លួននៅជាមួយឥសីវិស្វាមិត្រ បង្ក្រាបនាងយក្ខិនីតារកា ។ | -ពុំបានប្រាប់សាវតាប្រវត្តិព្រះរាមឡើយ ។ អ្នកអានមើលទៅឆ្ងាយបន្តិចទើបដឹងថា ពីប្រវត្តិគ្រួសារព្រះរាម ។ រឿងចាប់និយាយភ្លាមព្រះរាមធំដឹងក្តី ហើយត្រូវជួយបង្ក្រាបយក្សឈ្មោះកាកនាសូរដែលបំផ្លាញហោមពិធីរបស់ឥសីពិស្វាមិត្រ ។ យើងពុំបានដឹងថាយក្សក្អែក |

| | |
|---|---|
| -ប្រាប់ប្រវត្តិផ្នួសររបស់ព្រះបាទជនក នៃក្រុងមិថិលា ។<br>-នាងគមម្នាក់ឈ្មោះមន្ថរា ជាអ្នកញុះញង់នាងកៃកេយីដើម្បីជំទាស់នឹងព្រះរាមមិនឱ្យសោយរាជ្យ ។ | នេះភេទស្រី ឬប្រុសផង ។<br>-មិនមានប្រាប់ប្រវត្តិផ្នួទេ<br><br>-នាងកៃកេសីខ្លួនឯងជាអ្នកជំទាស់មិនឱ្យព្រះរាមសោយរាជ្យ |

៤. រាមកេរ្តិ៍ និងរឿងរាមាយណៈ មានទំនាក់ទំនងនិងឥទ្ធិពលទៅលើគ្នាទៅវិញទៅមកក្នុងទំនាក់ទំនងសង្គម តាំងពីការរស់នៅក៏ដូចជាការទទួលនូវឥទ្ធិពលមួយចំនួនក្នុងនៅប្រពៃណី ទំនៀមទម្លាប់ ជំនឿ សាសនា ដែលធ្លាប់បានអនុវត្តកន្លងមកនៅក្នុងសង្គមខ្មែរក៏ដូចជាក្នុងអក្សរសិល្ប៍មានដូចជា ការប្រារព្ធពិធីបូជាយញ្ញ (រាមកេរ្តិ៍ខ្មែរ) របស់ឥសីពិស្វាមិត្រ ការរៀបចំពិធីរចត់ព្រះនង្គ័ល ពិធីរាជាភិសេកព្រះរាជាឡើងគ្រងរាជ្យ និងពិធីដទៃទៀតដែលអនុវត្តតាមលទ្ធិព្រាហ្មណ៍ អរិយធមិពីប្រទេសឥណ្ឌាតាំងពីយូរយារណាស់មកហើយ ហើយដូនតាយើងបានរៀបចំច្នៃប្រឌិតតាក់តែងឡើងទៅតាមលក្ខណៈជាតិជាមូលដ្ឋាននៃវប្បធមិអរិយធមិរបស់ខ្លួន សម្រាប់ទ្រទ្រង់នូវខឿនអក្សរសិល្ប៍បុរាណក្នុងគោលខេមរនិយមផង និងគោលមនុស្សនិយមផង ពុំមែនជាលក្ខណៈអស្ចារ្យហួសពីលក្ខណៈមនុស្សដូចរឿងរាមាយណៈឡើយ ។

៥. តួអង្គព្រះរាមក្នុងរឿងរាមកេរ្តិ៍ ខុសពីព្រះរាមក្នុងរឿងរាមាយណៈដូចតទៅ ៖

- រឿងរាមកេរ្តិ៍ខ្មែរ អ្នកនិពន្ធបានរៀបរៀងឱ្យព្រះរាមមានលក្ខណៈសមស្របទៅតាមមនុស្សនិយម ដោយពុំបានទ្រទ្រង់លើកតម្កើងជាអាទិទេពដែលគ្មានកំហុសឆ្គងនោះឡើយ។ ពីខ្សែ១-៣ ព្រះរាមមានលក្ខណៈល្អស្អាតបរិសុទ្ធ ប្រកបដោយវិចារណញ្ញាណ ខន្តី មេត្តា ករុណា សន្តោស កាន់ពាក្យសច្ចៈ។ ខ្សែ៤-១០ ព្រះរាមមានលក្ខណៈជាមនុស្សផុងខ្លួនចាញ់កលយក្ស ទៅជាចេះយំខ្សឹកខ្សួល មានកំហឹងប្រើឧបាយយ៉ាងកំឡៅ។ ខ្សែ៧៥-៨០ ព្រះរាមមានអាកប្បកិរិយាអន់ថយរហូតដល់ខ្សោយជាងមនុស្សសាមញ្ញ ទាំងខាងផ្លូវកាយ វាចា ចិត្ត សន្ទនារឿងជាមួយកូនក្មេង ចេះប្រើឧបាយកលបញ្ឆោតនាងសីតា។
- ចំណែករឿងរាមាយណៈវិញ អ្នកនិពន្ធបានទ្រទ្រង់លក្ខណៈនិងសកម្មភាពព្រះរាមតាំងពីដើមដល់ចប់ថាជាតួអង្គប្រកបដោយវិមល (ប្រាសចាកនូវបាប មន្ទិលនានា) ហើយជាតំណាងអាទិទេពវិស្ណុអវតារចុះមកសង្គ្រោះមនុស្សលោកឱ្យផុតពីការវាតត្បាតចង្រៃនៃពួករាក្សសៈដែលជាយក្សអាក្រក់មានទោសទណ្ឌកម្ម ត្រូវប្រហារចោលដោយធ្នូសរព្រហ្មាស្ត្រ។ ព្រះរាមប្រហារយក្សក្តី សុទ្ធសឹងតែអនុវត្តទៅតាមទេវតាបញ្ជា ដោយសារពពួកទមិឡចង្រៃនេះមានទោសទណ្ឌដែលបណ្តាលមកពីការរុករាតត្បាតលោកៈ ឬដោយមានបុព្វហេតុកម្មពីជាតិមុន។

#  ទិដ្ឋភាពវប្បធម៌ខ្មែរក្នុងរឿងហង្សយន្ត

## សំណួរ

១. តើរឿងហង្សយន្តមានតួអង្គសំខាន់ៗណាខ្លះ? ចូររៀបរាប់ឈ្មោះ។

២. ហេតុអ្វីបានជាអ្នកនិពន្ធដាក់ឈ្មោះថា ហង្សយន្ត?

៣. តើរឿងហង្សយន្តមានអត្ថន័យដូចម្តេច?

៤. ផ្អែកតាមការស្រាវជ្រាវរបស់ព្រះមហា រស់ ឈុត និងលោកស្រី ឈុន ខុន តើរឿងនេះមានអ្នកនិពន្ធឈ្មោះអ្វី? តែងឡើងនៅឆ្នាំណា? ក្នុងរជ្ជកាលស្តេចណា?

## ចម្លើយ

១. រឿងហង្សយន្តមានតួអង្គសំខាន់ៗ ៖

- ព្រះអាទិត្យវង្សា : ស្តេចសោយរាជ្យនៅនគរទេពបុរី
- ព្រះនាងពិម្ពា : មហេសីព្រះអាទិត្យវង្សា
- សុវណ្ណកុមារ : បុត្រអាទិត្យវង្សានិងនាងពិម្ពា
- ព្រះចៅក្រុងបញ្ចាល
- ព្រះនាងបទុមកេសរ : បុត្រីព្រះចៅក្រុងបញ្ចាល
- ព្រះបាទព្រហ្មទត្ត : ស្តេចនៅក្រុងពារាណសី

- ចៅក្រីស្នកុមារ : បុត្រសុវណ្ណកុមារ និងនាងបទុមកេសរ
- យាយមាលា
- នាយសំពៅ

២. បានជាអ្នកនិពន្ធដាក់ឈ្មោះថា ហង្សយន្ត ព្រោះអ្នកនិពន្ធមានគំនិតស្រមើលស្រមៃច្នៃប្រឌិតទៅតាមលក្ខណៈវិទ្យាសាស្ត្រដោយចង់បានយានមួយដែលអាចហោះហើរលើអាកាសបានដូចដែលគំនិតអ្នកនិពន្ធប្រឌិតឡើង ហើយគំនិតនេះត្រូវបានសង្គមសម័យទំនើបសម្រេចបានដូចគំនិតអ្នកនិពន្ធតាំងពីបុរាណដែលលោកស្រមៃចង់បានពិតមែន។

៣. អត្ថន័យ រឿងហង្សយន្ត ៖

**+ អត្ថន័យនៃចំណងជើងរឿង**

- ហង្ស : ជាពាក្យបាលី ឯ "ហំសា" ជាពាក្យសំស្រ្កឹត គឺសំគាល់លើសត្វស្លាបមានសណ្ឋានបែបក្ងានព្រៃដែលជាយានជំនិះព្រះព្រហ្ម។
- ចំណែកឯ "យន្ត" ជាពាក្យបាលី ហើយ "យន្ត្រ" ជាពាក្យសំស្រ្កឹតសំគាល់អ្វីដែលជាគ្រឿងចក្រ។

**+ អត្ថន័យនៃសាច់រឿង**

រឿងហង្សយន្តមានអត្ថន័យសំខាន់ត្រង់ថា អ្នកនិពន្ធបានតាក់តែងឡើងប្រកបដោយគំនិតច្នៃប្រឌិត ដោយបង្កើតយាន

ជំនិះគ្មានវិញ្ញាណឱ្យហោះហើរលើអាកាសដោយគ្រឿងយន្ត បានជាងរឿងដទៃដែលអ្នកនិពន្ធច្រើនបង្កើតភាពអច្ឆរិយៈក្នុងការហោះហើរដោយការប្រើមន្តអាគមសិល្ប៍សាស្ត្រ។ និមិត្ត-កម្មនេះគឺវាមានអត្ថន័យខ្ពស់ដល់ស្នាដៃសិល្បៈរបស់ខ្មែរជំនាន់នោះ គឺអ្នកនិពន្ធមានគំនិតឱ្យតម្លៃលើអត្ថន័យរឿងមិនត្រឹមតែលក្ខណៈសាសនា ឬអស្ចារ្យប៉ុណ្ណោះទេ ពោលគឺជារបបគំហើញថ្មីមួយក្នុងឧត្តមគតិអ្នកនិពន្ធដែលបម្រើឱ្យដល់តម្លៃវប្បធម៌សិល្បៈផង និងរំលេចដោយគំនិតវិទ្យាសាស្ត្រផង។

៤. ផ្អែកតាមការស្រាវជ្រាវរបស់ព្រះមហា រស់ ឈុត និងលោកស្រី ឈុន ខុន រឿងនេះមានអ្នកនិពន្ធឈ្មោះចៅយមបុណ្យភក្តិ ឧកតែងឡើងនៅគ.ស.១៦៦៨ ក្នុងរជ្ជកាលស្តេចជ័យចេស្តារាមាឥស្សរសុរិយោវង្ស។



# ការបកស្រាយន័យសុភាសិត

## លំហាត់

ចូរបកស្រាយសុភាសិត ៖

- ចេះពីរៀន មានពីរក
- ងើយស្កក ឱនដាក់គ្រាប់
- ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ
- ស្រឡាញ់កុំទៅញ៉ឹក រលឹកសឹមទៅម្តង

## ចម្លើយ

*ក) ចេះពីរៀន មានពីរក*

+ចេះពីរៀន : មានន័យថាចំណេះអ្វីក៏ដោយគឺសុទ្ធតែកើតមកពីការរៀនទាំងអស់ ដូច្នេះត្រូវខិតខំស្រវាស្រទេញ រៀនសូត្រគ្រប់មុខវិជ្ជាទាំងអស់ ។

+មានពីរក : មានន័យដើម្បីឱ្យមានទ្រព្យសម្បត្តិ ឬរបស់របរអ្វីៗត្រូវខិតខំធ្វើការងារឱ្យអស់ពីកម្លាំងកាយចិត្ត មិនត្រូវខ្ជិលច្រអូសទេ ។

*ខ) ងើយស្កកឱនដាក់គ្រាប់*

- **ន័យចំ** : សំដៅទៅលើដើមស្រូវទុំ។ កួរស្រូវណាដែលត្រង់ទៅលើគឺគ្មានគ្រាប់ ឬស្កក ។ ចំណែកឯកួរស្រូវណាដែលឱនចុះក្រោម មានគ្រាប់អង្ករ ។

- **ន័យធៀប** : សំដៅលើមនុស្ស។ "ដើយស្កក" ប្រើសម្រាប់មនុស្សដែលគ្មានសុជីវធម៌ ។ "ឱនដាក់គ្រាប់" ប្រើសម្រាប់មនុស្សមានសុជីវធម៌ ។

*ឆ) ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ*

- **ធ្វើស្រែនឹងទឹក** : កសិកម្មទាំងអស់សុទ្ធតែត្រូវការទឹកជាចាំបាច់បំផុត។ ស្រែ (ស្រូវ) ជាដំណាំកសិកម្មដ៏សំខាន់ ជាងគេដែលត្រូវការទឹកមិនអាចខ្វះបាន ព្រោះស្រូវត្រូវការស្រូបទឹកយកទៅចិញ្ចឹមដើម និងផ្លែ ឱ្យទទួលបានទិន្នផលល្អ ។

- **ធ្វើសឹកនឹងបាយ** : សឹកសង្គ្រាមត្រូវមានទុន គឺស្បៀង ជាមូលដ្ឋាន។ ដោយហេតុថាមនុស្សកាលណាស៊ីបាយឆ្អែត មានកម្លាំងកាន់អាវុធ ចូលប្រយុទ្ធនឹងខ្មាំងសត្រូវក្នុងសមរភូមិ។ បើគ្មានបាយទេ កងទ័ពនឹងបាក់កម្លាំង មិនអាចធ្វើសង្គ្រាមបានឡើយ ។

*ឋ) ស្រឡាញ់កុំទៅញឹក រលឹកសឹមទៅម្ដង*

- ស្រឡាញ់កុំទៅញឹក : បើស្រឡាញ់ ឬពេញចិត្តចំពោះអ្នកណា មិនត្រូវទៅផ្ទះគេញឹកញាប់ពេកទេ ព្រោះវានាំឱ្យគេធុញទ្រាន់ ឬរំខានគេ ហើយអាចនាំឱ្យអាក់អន់ចិត្តគ្នាទៅវិញក៏មាន ។

- **រលឹកសឹមទៅម្ដង** : បើនឹកគេខ្លាំងពេក យូរៗទៅលេងម្ដងបានហើយ។ មនុស្សយើងបើកាលណាជួបគ្នាម្ដងៗ រមែងសំដែងសេចក្ដីនឹករលឹកស្រឡាញ់គ្នាណាស់ ហើយក៏គ្មានអ្វីបណ្ដាលឱ្យរការកូស អាក់អន់ចិត្តគ្នាដែរ គឺនៅតែរាប់អានគ្នាបានយូរអង្វែង ។

មេរៀនទី ១០

# អក្សរសិល្ប៍បរទេស

## មរណភាពដ៏ក្លាហានរបស់ហាំលែត

### សំណួរ

១. តើអ្នកនិពន្ធរឿងហាំលែតឈ្មោះអ្វី? ចូរនិយាយពីប្រវត្តិរបស់អ្នកនិពន្ធរូបនេះ ។

២. តើរឿងហាំលែតនិពន្ធនៅឆ្នាំណា? តើសម័យនោះស្ថិតក្នុងបរិយាកាសសង្គមបែបណា?

៣. ចូរបង្ហាញអត្ថរសនៅក្នុងអត្ថបទនេះ ។

៤. តើអត្ថបទនេះបានបង្ហាញខ្លឹមសារសំខាន់ដូចម្តេចខ្លះ?

៥. តួអង្គហាំលែតស្លាប់មែន ប៉ុន្តែឧត្តមគតិរបស់តួអង្គនេះបានទទួលជ័យជំនះយ៉ាងត្រចះត្រចង់ ។ ចូរបង្ហាញតាមរយៈអត្ថបទខាងលើ ។

### ចម្លើយ

១. អ្នកនិពន្ធរឿងហាំលែតឈ្មោះ វីល្លីយ៉ាម សេកស្ពៀរ (William Shakespeare)

## ប្រវត្តិរបស់អ្នកនិពន្ធ វិល្លៀម សេកស្ពៀរ

(William Shakespeare)

- លោកជាអ្នកនិពន្ធដ៏ល្បីជាងគេនៅគ្រប់សម័យកាលនៅក្នុងប្រទេសអង់គ្លេស។ គាត់កើតនៅក្នុងគ្រួសារអ្នកជំនួញនៅស្ត្រាតហ្វ័រដ៍អាវ៉ុន នៅថ្ងៃទី២៣ មេសា ១៥៦៤។
- ឪពុកឈ្មោះ ចន សេកស្ពៀរ (John Shakespeare) ជាអ្នកមានស្តុកស្តម្ភ។
- ម្តាយឈ្មោះ ម៉ារីអាគដែន ជាបុត្រីនៅក្នុងគ្រួសារដែលមានកិត្តិយសឧត្តុង្គឧត្តម។
- ឆ្នាំ១៥៨២ លោកសេកស្ពៀរ បានរៀបការជាមួយនាងអាន ហាតថាវេ (Ann Hathaway)។
- មានកូនបីនាក់។ កូនស្រីច្បងឈ្មោះ Susanna និងកូនភ្លោះ Hamnel និង Judith ។
- ឆ្នាំ១៥៨២-១៥៩២ ជីវភាពរបស់សេកស្ពៀរ មានភាពអាថិកំបាំង។ រយៈពេលនេះគាត់ជាចាងហ្វាងសាលាឯកជនឬសិល្បករនៅតាមខេត្ត។
- គាត់បានមកដល់ទីក្រុងឡុងដ៍នៅឆ្នាំ១៥៩២។ ពេលនោះសេកស្ពៀរបានចូលមកក្នុងមជ្ឈដ្ឋានល្ខោនក្នុងឋានៈជាអ្នកសំដែង។ គាត់បានសរសេររឿងឱ្យក្រុមសំដែង The

king's Men ។ បន្ទាប់មកគាត់មានរោងល្ខោនមួយឈ្មោះ New Globe theatre បានកើតឡើង ។ នៅពេលនោះហើយដែលរឿងទាំងឡាយរបស់គាត់បានលាតត្រដាងចំពោះមុខសាធារណជន ។

- ឆ្នាំ១៦១៦ គាត់បានទៅកាន់ស្ត្រាតហ្វ័រដ័អាវ៉ុនវិញ ហើយក៏ជាឆ្នាំដែលគាត់ស្លាប់ដែរ ។ គេច្រើននិយាយថា ថ្ងៃទី២៣ មេសា ជាថ្ងៃកំណើតផង និងជាថ្ងៃស្លាប់របស់គាត់ផង ។

**ស្នាដៃ**

- រ៉ូមេអូនិងស៊ូលីយែត, ១៥៩៤
- អ្នកជំនួញនៅវេនីស, ១៥៩៤
- សុបិននារាត្រីមួយនៅនិទាឃរដូវ, ១៥៩៤
- រាត្រីទីដប់ពីរ, ១៦០១
- ហាំលែត, ១៦០១
- ហូថេឡោ, ១៦០១
- ម៉ាក់ប៊ែត, ១៦០៥
- ព្រះចៅល្បែរ, ១៦០៧

២. រឿងហាំលែត និពន្ធនៅឆ្នាំ១៦០១ ។

បរិយាកាសសង្គមសម័យនោះស្ថិតក្នុងសម័យមួយដែលមានការប្រែប្រួលពីរបបសក្តិភូមិទៅកាន់របបមូលធននិយម គឺជាសម័យដែលវណ្ណៈគហបតីទើបនឹងកើតឡើងកំពុងប្រឆាំងតបត

នឹងរបបសក្តិភូមិទាំងផ្នែកស្មារតីក៏ដូចជាផ្នែកសេដ្ឋកិច្ច។ មកដល់ ស.វ.១៥-១៦ ប្រទេសអង់គ្លេសបានឆ្លងចូលសម័យកាលមួយថ្មី សម័យវាយកម្ទេចរាល់ទំនាក់ទំនងសក្តិភូមិនិយម ក្នុងនោះវណ្ណៈ អភិជនចាស់ត្រូវបានកម្ទេចចោលទាំងស្រុង ហើយត្រូវជំនួស ដោយវណ្ណៈមួយថ្មីនៅក្នុងត្រកូលគហបតី និងមាននិន្នាការរកមូល ធននិយម។

៣. អត្ថរសនៅក្នុងអត្ថបទនេះ គឺ ៖

- **នាដ្យរស** : តម្លៃដែលលេចចេញពីភាពកំសត់ក្នុងរឿងស្ថិត នៅត្រង់ការប្រយុទ្ធប្រឆាំងរកយុត្តិធម៌រវាងហាំលែតនិង ស្តេចក្លូឌីយ៉ូស ដែលបានបង្កឱ្យមានសោកនាដកម្មដ៏សែន ខ្លោចផ្សានៅលើដែនដីដាណឺម៉ាក។ ទោះបីជានៅទីបញ្ចប់ ហាមលែតត្រូវឈ្នះក៏ពិតមែន ប៉ុន្តែគាត់ត្រូវបាត់បង់មាតា បិតា នារីជាទីស្រឡាញ់ និងជីវិតរបស់ខ្លួនគាត់ផងដែរ។
- **វីររស** : តម្លៃដែលលេចចេញពីវីរភាពអង់អាចក្លាហាន របស់ហាំលែត។ ហាំលែតសុខចិត្តពលីជីវិតខ្លួនដើម្បីសង សឹកឱ្យអ្នកមានគុណ។
- **ទារុណរស** : តម្លៃដែលលេចចេញពីការធ្វើទារុណកម្មនៅ ក្នុងដំណើររឿង ដែលកើតពីការប្រយុទ្ធព្យាបាទ សងសឹក

និងធ្វើទុក្ខទោស ដាក់ទណ្ឌកម្មយ៉ាងកាចសាហាវ រហូតបាត់បង់ជីវិតដោយអយុត្តិធម៌ ។

ឧទាហរណ៍ ៖ ឈុតឆាកគំនុំសងសឹករបស់ហាមលែត ធ្វើឱ្យមានការកាប់សម្លាប់គ្នា ការផឹកថ្នាំពុល... ។

- តថរស ៖ តម្លៃដែលលេចចេញពីតថភាពពិតក្នុងសង្គម ដូចជា ៖

+ ទីកន្លែងនៃរឿង នៅប្រទេសដាណឺម៉ាក អង់គ្លេស

+ ការគ្រប់គ្រងប្រទេសស្ថិតនៅក្រោមអំណាចស្ដេចផែនដី

+ មានបែងចែកវណ្ណៈ ស្ដេច មន្ត្រី អ្នកមាននិងរាស្ត្រជាដើម ។

៤. ខ្លឹមសារសំខាន់ក្នុងអត្ថបទនេះគឺភាពអង់អាចក្លាហានរបស់តួអង្គហាំលែតដែលប្រឹងប្រែងតស៊ូប្រឆាំងជាមួយសត្រូវដែលសម្លាប់ព្រះរាជវង្សានុវង្សរហូតដល់ដំណាក់ឈាមចុងក្រោយ ។

៥. តួអង្គហាំលែតស្លាប់មែន ប៉ុន្តែឧត្តមគតិរបស់តួអង្គនេះបានទទួលជ័យជំនះយ៉ាងត្រចះត្រចង់ ។ ឃ្លានេះមានន័យថា ហាមលែតស្លាប់តែរូបកាយទេ តែវីរភាព និងកេរ្តិ៍ឈ្មោះដ៏អង់អាចក្លាហានរបស់គាត់មិនស្លាប់តាមនោះឡើយ ។ នរណាក៏ទទួលស្គាល់ និងឱ្យតម្លៃទៅលើភាពអង់អាចក្លាហាន ក្នុងនាមជាកូនកតញ្ញូរបស់ហាមល៉ែតដែរ ។



# ដំណើរស្វែងរកនាងសីតា

## សំណួរ

១. ចូរនិយាយពីជីវប្រវត្តិអ្នកនិពន្ធរឿងរាមាយណៈ និងស្នាដៃរបស់លោក ។

២. តើរឿងរាមាយណៈនិពន្ធនៅសម័យណា?

៣. តើកាលអាកាសក្នុងសាច់រឿងនេះ មានតួនាទីអ្វីខ្លះ?

៤. តើប្រផ្នូលនិងការរំឭករឿងដើមក្នុងរឿងមាននៅកន្លែងណា? ចូរបង្ហាញ ។

៥. ចូរបង្ហាញពីអត្ថរសដែលមាននៅក្នុងអត្ថបទ ។

៦. តើភាតរភាពរវាងទេវៈសាគរនិងហនុមាន រវាងហនុមាននិងព្រះរាមកើតឡើងដោយសារអ្វី? មានប្រយោជន៍អ្វីខ្លះ?

## ចម្លើយ

១. ជីវប្រវត្តិអ្នកនិពន្ធរឿងរាមាយណៈនិងស្នាដៃ ៖

ជីវប្រវត្តិរបស់កវីវាល្មីកិក៏មានលក្ខណៈជារឿងព្រេងនិទានដែរ ។ នៅពេលដែលត្រូវឪពុកម្តាយបោះបង់ចោល វាល្មីកិក៏បានក្លាយជាខ្លួនទៅជាចោរព្រៃភ្នំ ។ ក្រោយមកគាត់បានជួបបព្វជិតម្នាក់ទូន្មានឱ្យគាត់វិលមកកាន់ផ្លូវធម៌អាថ៌វិញ ។ វាល្មីកិអនុវត្តតាម

បញ្ហាតាមពាក្យណែនាំ ដោយខំអង្គុយស្ញឹងស្ងាធ៌រាប់ឆ្នាំគ្មានកម្រើក ទាល់តែសោះរហូតដល់សត្វកណ្ដៀរពូនជាដំបូកគ្របខ្លួនជិត (ដូច្នេះហើយបានជាលោកឈ្មោះថាវាល្មីកិ ព្រោះវាល្មីកិ មានន័យថា កូនដំបូក) ។

២. គេមិនបានដឹងថារឿងរាមាយណៈកើតឡើងនៅសម័យកាលណាពិតប្រាកដទេ ប៉ុន្តែនៅរវាងស.វ. ទី ៦-៥ មុនគ.ស. រឿងនេះបានត្រូវពួកអ្នកចម្រៀងចរិចរលើកយកមកច្រៀងតគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ ពីជំនាន់មួយទៅជំនាន់មួយ ។ កវីវាល្មីកិ (ស.វ.៥ មុនគ.ស.) ជាជនទីមួយដែលបានលើកយករឿងរាមាយណៈ មកចងក្រងជាភាសាសំស្ក្រឹត ហើយបានបង្កើតឱ្យមានសិល្បៈក្នុងកំណាព្យ ។

*សម្គាល់ : (បើគិតតាមលទ្ធិព្រហ្មញ្ញសាសនាវិញ យើងអាចសន្និដ្ឋានថា រឿងរាមាយណៈនិពន្ធនៅសម័យព្រាហ្មណ៍និយម (៥៥០មុន គ.ស ដល់ស.វ ទី១០ នៃគ.ស) ។*

៣. កាលអាកាសក្នុងសាច់រឿងនេះ មានតួនាទីបញ្ជាក់អំពីព្រឹត្តិការណ៍ដែលកើតឡើងយ៉ាងតឹងតែង ។ ទីកន្លែងរឿងកើតឡើងនៅកោះលង្កា ដែលជាកោះមួយស្ថិតនៅកណ្ដាលមហាសមុទ្រដ៏ធំធេង ប្រកបដោយកិច្ចការពារយ៉ាងរឹងមាំ ។ រឿងនេះក៏បានកើតឡើងក្នុងពេលយប់ដែលក្រុងលង្កាមានអ្នកយាមការពារយ៉ាងម៉ត់ចត់ ធ្វើ

ឱ្យហនុមានជួបនឹងការលំបាកយ៉ាងច្រើនក្នុងការរកនាងសីតាដែលហនុមានពុំដឹងជាមុនថានាងសីតានៅទីណាផងនោះ ។ ប៉ុន្តែពេលយប់ក៏ជាការងាយស្រួលក្នុងការលាក់ខ្លួនរបស់ហនុមាន ដើម្បីរកនាងសីតា និងលាក់បាំងខ្លួនពីអ្នកយាមល្បាតរបស់ក្រុងលង្កាដែរ ។ ដូចនេះកាលក៏មានតួនាទីសំខាន់ណាស់ដែរក្នុងសាច់រឿង ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ពីសភាពលក្ខណៈនៃសាច់រឿងក្នុងទីកន្លែងនិងពេលវេលាមួយ ។

៤. ប្រផ្នូលនិងការរំឭករឿងដើមក្នុងរឿងនៅត្រង់ ៖

- ប្រផ្នូល : ត្រង់ចំណុចដែលហនុមានទះកំភ្លៀងអ្នកតាចាស់ស្រុក គឺមានប្រផ្នូលថាទីក្រុងលង្កានឹងត្រូវវិនាសក្នុងពេលឆាប់ៗនេះ ។
- រំលឹករឿងដើម : ត្រង់ចំណុចដែលគិរីមេខនកៈនិទានរឿងប្រាប់ហនុមាន "កាលពីព្រេងនាយ......" ។

៥. អត្ថរសដែលមាននៅក្នុងអត្ថបទ ៖

- **អច្ឆរិយរស** : ដំណើររឿងបង្ហាញពីភាពអស្ចារ្យរបស់តួអង្គហនុមានចេះហោះហើរ ប្រែក្រឡា ។ល ។
- **ហាស្សរស** : តម្លៃនៃភាពសប្បាយរីករាយក្នុងដំណើររឿងត្រង់កន្លែងដែលហនុមានទះកំផ្លៀងអ្នកតាចាស់ស្រុកឱ្យបះជើងប្រោង ។

- **វិរបុរស :** តម្លៃស្ថិតនៅលើភាពអង់អាចក្លាហានរបស់ហនុ-មានដែលពុះពារគ្រប់ឧបសគ្គដើម្បីតស៊ូជាមួយការសាកល្បងរបស់ព្រះទេវសាគរ...។

៦. **+ភាតរភាពរវាងទេវៈសាគរនិងហនុមាន** កើតឡើងដោយសារពេញចិត្តនឹងវីរភាពឥតមានពីររបស់ហនុមាន និងជួយហនុមានដើម្បីចងមិត្តភាព។ ទេវសាគរសរសើរហនុមានថាគេក្លាហាន។ មិនតែប៉ុណ្ណោះទេវសាគរបានបញ្ជាឱ្យមេនកៈងើបពីបាតសមុទ្រមកធ្វើកន្លែងសម្រាប់ហនុមានសម្រាក ហើយទេវសាគរក៏បានធ្វើពិសោធឫទ្ធិហនុមានដោយឱ្យនាងសក្សសីកាលាខ្លួនឱ្យធំរារាំងហនុមាន។

**+ភាតរភាពរវាងហនុមាននិងព្រះរាម** កើតឡើងដោយសារការចងសម្ព័ន្ធភាពរវាងព្រះរាមនិងហនុមាន។ ហនុមានបានលះបង់ពុះពារឫក្តផ្តាច់ ដើម្បីយកនាងសីតាមកថ្វាយព្រះរាមវិញ។

**+ភាតរភាពនេះមានប្រយោជន៍ណាស់** ធ្វើឱ្យមិត្តភាពកាន់តែរឹងមាំ និងចេះជួយគ្នាទៅវិញទៅមកក្នុងគ្រាមានការលំបាក ឬមានគ្រោះថ្នាក់ផ្សេងៗដូចជាទេវសាគរជួយហនុមាន ហើយហនុមានជួយព្រះរាមនេះហើយធ្វើឱ្យសម្ព័ន្ធភាពនៃអ្នកទាំងបីកាន់តែរឹងមាំថែមទៀត។



# ប៉ូលវីរហ្សីនី

## សំណួរ

១. តើដំណើររឿងនេះប្រព្រឹត្តទៅនៅប្រទេសណា? ទីកន្លែងណា?

២. តើក្នុងអត្ថបទនេះមាននិយាយពីប្រផ្នូលអ្វីខ្លះ?

៣. ចូរវិភាគតួអង្គប៉ូលនិងវីរហ្សីនីតាមរយៈអត្ថបទនេះ ។

៤. ចូរបង្ហាញពីអត្ថរូបនិងអត្ថរសដែលមាននៅក្នុងអត្ថបទដកស្រង់ខាងលើនេះ ។

៥. តើអ្នកយល់ដូចម្ដេចចំពោះមរណភាពរបស់តួអង្គប៉ូលនិងវីរហ្សីនី?

៦. ប្រសិនបើជួបគ្រោះថ្នាក់ដូចនាងវីរហ្សីនី តើអ្នកធ្វើដូចម្ដេច?

## ចម្លើយ

១. ដំណើររឿងនេះប្រព្រឹត្តទៅនៅលើកោះអ៊ីលដឺហ្វ្រង្ស ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រទេសបារាំងក្នុងឆ្នាំ១៧២៦ ។ គឺនៅលើកោះក្នុងសមុទ្រក្បែរកោះអមប្រឺ ទីក្រុងព័រល្វី ។

២. អត្ថបទនេះមាននិយាយពីប្រផ្នូលពាក្យសំដីរបស់អ្នកចាស់ស្រុកម្នាក់ប្រាប់លោកចៅហ្វាយថា "ពីយប់មិញគេបានឮយ៉ាងថ្លង់នៅក្នុងគំនរភ្នំ និងក្នុងព្រៃនូវស្លឹកឈើដែលបក់បោកយ៉ាងខ្លាំងដោយ

គ្មានខ្យល់បក់សោះ បក្សាបក្សីទាំងឡាយមករកទ្រនំនៅលើគោក ទាំងអស់ សញ្ញាទាំងនេះបង្ហាញជាមុនថានឹងមានខ្យល់ព្យុះសង្ឃរា មកដល់ជាប្រាកដ ។

៣. វិភាគតួអង្គ

+ **ប៉ូល**

- គុណសម្បត្តិ : មិនខ្លាចស្លាប់ ក្លាហាន ធ្វើអ្វីៗគ្រប់យ៉ាង ដើម្បីមនុស្សស្រីជាទីស្រឡាញ់ ស្មោះស្មោះមួយនឹងមួយ ។
- គុណវិបត្តិ : ចរិតឆេវឆាវលោតទៅក្នុងទឹកទាំងប្រថុយប្រ ថាន អាចនាំឱ្យបាត់បង់ជីវិត ។

+ **វីរហ្សីនី**

- គុណសម្បត្តិ : មានគុណធម៌ មិនតក់ស្លុត ស្មោះត្រង់ ហ៊ាន ប្រឈមមុខនឹងឧបសគ្គ ។
- គុណវិបត្តិ : ដោយសេចក្ដីខ្មាសអៀន បែរជាបណ្ដោយខ្លួន ឱ្យបាត់បង់ជីវិត ។

៤. នៅក្នុងអត្ថបទដកស្រង់នេះ

+ អ្នកនិពន្ធបានបង្ហាញពី

- ពណ៌នាវិធី : គឺបានរៀបរាប់ពីទិដ្ឋភាពព្យុះសង្ឃរាដ៏អាក្រក់ ដែលបោកបក់មកលើកប៉ាល់ពីរលកសមុទ្រ ហើយក៏រៀប រាប់ផងដែរពីសកម្មភាពរបស់ប៉ូលដែលចច្រប់គ្រប់ទីកន្លែង

អនុស្សាវរីយ៍ រវាងប៉ូលនិងវីរហ្សីនីកាលនៅជាមួយគ្នា ។

- សំវាទវិធី : ការសន្ទនារវាងតាចាស់ស្រុកជាមួយលោកចៅហ្វាយ ។
- ឯកវាទវិធី : បុរសកម្មករនៅលើកប៉ាល់និយាយម្នាក់ឯង "ឱ! ព្រះរាជាម្ចាស់អើយ!....." ។
- វឌ្ឍមានវិធី : រលកសមុទ្រធ្វើឱ្យប៉ូលនិងវីរហ្សីនីព្រាត់គ្នាអស់មួយជីវិត ។
- ទារុណវិធី : ប៉ូលទទួលរងការឈឺចាប់ទាំងផ្លូវកាយផ្លូវចិត្តរហូតបាត់បង់ជីវិត ។
- ឧបមានវិធី : រលកមួយធំដូចជាភ្នំរមៀលមកលើនាវា ។
- វចនវិធី : ប្រើពាក្យសាមញ្ញ ងាយយល់ ស្ដាប់បាន ។
- រចនាវិធី : សរសេរជាពាក្យរាយ ឃ្លាល្បះមានភាពអណ្ដែតអណ្ដូងគួរឱ្យអាណិតអាសូរ ។

+ អត្ថរសនៅក្នុងអត្ថបទដកស្រង់នេះគឺ

- ប្រលោមរស : តម្លៃរឿងស្ថិតនៅលើសកម្មភាពតួអង្គនាងវីរហ្សីនីបង្ហាញកិរិយាគួរឱ្យអាណិតមុនពេលស្លាប់ ហើយសកម្មភាពរបស់ប៉ូលដែលពោលពីការព្រាត់ប្រាសរវាងខ្លួននិងវីរហ្សីនី ។
- តថរស : តម្លៃរឿងស្ថិតនៅការពិតមួយដែលមនុស្សភាគ

ច្រើននៅប្រកាន់វណ្ណៈ ហើយក៏មានអ្នកដែលស្រឡាញ់ទ្រព្យសម្បត្តិជាងសាច់ញាតិរបស់ខ្លួនផងដែរ ។ ម្យ៉ាងទៀតរឿងនេះក៏បានលើកពីធាតុពិតនៃឥទ្ធិពលស្នេហាដែលមានចំពោះយុវជនប៉ូល និងនាងវីរហ្សីនីដែលជារឿងពិតរបស់មនុស្សនៅលើពិភពលោក ។

- នាដ្យរស : តម្លៃនៃរឿងស្ថិតនៅលើការរៀបរាប់ពីទុក្ខ-សោកសង្រេងរបស់តួអង្គប៉ូលដែលស្រឡាញ់នាងវីរហ្សីនីយ៉ាងខ្លាំងរហូតដល់ស្លាប់ខ្លួន ។
- វីររស : តម្លៃរឿងស្ថិតនៅត្រង់ប៉ូលបានប្តូរជីវិតក្នុងព្យុះកំណាចទៅជួយនាងវីរហ្សីនី ។
- កុសលរស : តម្លៃរឿងស្ថិតនៅត្រង់គុណធម៌ដ៏វិសេសវិ-សាលបំផុតដែលនាងវីរហ្សីនីសុខចិត្តលះបង់ជីវិត តែមិនអនុញ្ញាតឱ្យបុរសជាកម្មករបានឃើញឬប៉ះពាល់រាងកាយរបស់នាងឡើយ ឬក៏អាចនិយាយបានថានាងរក្សាខ្លួនប្រាណនិងចិត្តរបស់នាងទុកសម្រាប់តែប៉ូលម្នាក់គត់ ។ ម្យ៉ាងអប់រំឱ្យមនុស្សចៀសវាងភាពលោភលន់បែបម្តាយមីងអ្នកស្រីដឺឡាទួ ។

៥. ចំពោះមរណភាពរបស់តួអង្គប៉ូលនិងវីរហ្សីនី គឺបង្ហាញពីមនោ-សញ្ចេតនាដែលអ្នកទាំងពីរមានជាមួយគ្នា ធ្លាប់សន្យាគ្នាថានឹងនៅ

ជាមួយគ្នា ទោះបីជារស់ឬស្លាប់ក៏ដោយ ។ អ្នកទាំងពីរមានអនុស្សាវរីយ៍រាប់មិនអស់តាំងពីនាងវីរហ៊្សនីចេះនិយាយរហូតធំពេញរូបរាង គឺមិនដែលបែកឃ្លាតពីគ្នាម្តងណាឡើយ ។ យើងអាចនិយាយម្យ៉ាងទៀតបានដែរ គឺដោយសារតែចិត្តអមនុស្សធម៌របស់ម្តាយមីងអ្នកស្រីដឹឡាទួ ដែលមានចិត្តទុរយសបញ្ជូននាងវីរហ៊្សនីមកកោះវិញក្នុងរដូវខ្យល់ព្យុះ ។

៦. (ចម្លើយអាស្រ័យលើសិស្ស)

ចប់